នៅក្នុងពេលចោទប្រកាន់ដាច់ពីគ្នា កាលបើជនជាប់ចោទត្រូវបានរកឃើញថា មានពិរុទ្ធពីបទល្មើសច្រើន ទោសដែលត្រូវប្រកាស ត្រូវអនុវត្តត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ។ ប៉ុន្តែ តុលាការចុងក្រោយដែលត្រូវសម្រេច អាចប្រកាសឱ្យមានការដាក់ទោសស្រួបបញ្ចូលគ្នាទាំងមូល ឬ មួយផ្នែកនៃទោសដែលមានប្រភេទដូចគ្នា ។

ដើម្បីអនុវត្តមាត្រានេះ នៅក្នុងករណីទោសដែលច្បាប់កំណត់ជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ត្រូវបានកំណត់ដាក់ពន្ធនាគារត្រឹម ៣០ (សាមសិប) ឆ្នាំ ប្រសិនបើជនជាប់ចោទមិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតទេ ។

ការលើកលែងទោសទាំងមូល ឬ មួយផ្នែកនៃទោសដែលប្រកាសចំពោះបទល្មើសដែលត្រូតគ្នានេះ មិនអាចជាឧបសគ្គដល់ការអនុវត្តទោសនៃប្រភេទដូចគ្នាដែលគ្មានការលើកលែងទោសទេ ។

## ផ្នែកទី ២
## វិធានដោយឡែក

**មាត្រា ១៣៩.–** អានុភាពនៃការលើកលែងទោស និងការបន្ធូរបន្ថយទោសលើការស្រូបទោស

កាលបើទោសជាកម្មវត្ថុនៃវិធានការលើកលែងទោស និងបន្ធូរបន្ថយទោស ដូចមានចែងក្នុងមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវតែគិតគូរអំពីទោសដែលជាលទ្ធផលនៃការលើកលែងទោស និងបន្ធូរបន្ថយទោស ដើម្បីអនុវត្តវិធានស្តីពីការស្រូបបញ្ចូលគ្នានៃទោស ។

ថិរវេលានៃការបន្ធូរបន្ថយទោស ត្រូវរាប់បញ្ចូលទៅក្នុងថិរវេលានៃទោសទៅថ្ងៃមុខក្រោយការស្រូបទោស ។

**មាត្រា ១៤០.–** ការបូកបញ្ចូលគ្នានៃទោសពិន័យ

ជាបនិប្បញ្ញត្តិទៅលើបទប្បញ្ញត្តិមុន ការពិន័យដែលបានប្រកាសឡើង ចំពោះបទលហុច្រើននោះ ត្រូវបូកបញ្ចូលគ្នា ហើយត្រូវបូកផងដែរជាមួយទោសពិន័យ ដែលប្រកាសឡើងចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈិម ។

**មាត្រា ១៤១.–** ការមិនស្រូបចូលនៃទោសដែលត្រូវបានប្រកាសចំពោះករណីរត់ចេញពីពន្ធនាគារ

ក្នុងករណីផ្តន្ទាទោសពីបទរត់ចេញពីពន្ធនាគារ ទោសដែលប្រកាសពីបទនេះ ត្រូវបន្ថែមលើទោសដែលប្រកាសឡើង ចំពោះបទល្មើសដែលនាំឱ្យមានការឃុំខ្លួនជននោះ ដោយមិនអាចមានការស្រូបចូលគ្នា ។

## ជំពូកទី ៥
## មូលហេតុនានាដែលមានផលប៉ះពាល់ដល់ការអនុវត្តទោស
### ផ្នែកទី ១
### អាជ្ញាយុកាលនៃទោស

**មាត្រា ១៥២.-** អានុភាពនៃអាជ្ញាយុកាល

នៅពេលផុតអាជ្ញាយុកាលហើយ ទោសលែងអនុវត្តបានទៀតហើយ ។

**មាត្រា ១៥៣.-** ភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋមួយចំនួន

ទោសដែលប្រកាសពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និង បទឧក្រិដ្ឋសង្គ្រាម មិនអាចផុតរលត់អាជ្ញាយុកាលទេ ។

ក្រៅពីបទល្មើសខាងលើ ច្បាប់ពិសេសអាចកំណត់អំពីភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋផ្សេងទៀតបាន ។

**មាត្រា ១៥៤.-** អាជ្ញាយុកាលនៃទោស

ទោសដែលប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ (ម្ភៃ) ឆ្នាំ ។

ទោសដែលប្រកាសពីបទមជ្ឈិមមានអាជ្ញាយុកាល ៥ (ប្រាំ) ឆ្នាំ ។

ទោសដែលប្រកាសពីបទលហុមានអាជ្ញាយុកាល ១ (មួយ) ឆ្នាំ ។

**មាត្រា ១៥៥.-** ចំណុចចាប់ផ្តើមនៃថិរវេលា

ថិរវេលា ២០ (ម្ភៃ) ឆ្នាំ ៥ (ប្រាំ) ឆ្នាំ និង ១ (មួយ) ឆ្នាំ ខាងលើ ដែលមានចែងនៅក្នុងមាត្រា ១៥៤ (អាជ្ញាយុកាលនៃទោស) នៃក្រមនេះ ចាប់គិតពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោស បានក្លាយទៅជាស្ថាពរ ។

**មាត្រា ១៥៦.-** អាជ្ញាយុកាលនៃកាតព្វកិច្ចរដ្ឋប្បវេណីដែលកើតចេញពីសេចក្តីសម្រេចព្រហ្មទណ្ឌ

កាតព្វកិច្ចដែលមានប្រភេទជារដ្ឋប្បវេណី និងដែលមានប្រភពចេញមកពីសេចក្តីសម្រេចព្រហ្មទណ្ឌដែលក្លាយជាស្ថាពរ ផុតអាជ្ញាយុកាលតាមវិធាននៃក្រមរដ្ឋប្បវេណី ។

## ផ្នែកទី ២
## ការអនុគ្រោះទោស

**មាត្រា ១៤៧.-** អានុភាពនៃការអនុគ្រោះទោស

ការអនុគ្រោះទោសដោយការបន្ធូរបន្ថយទោស ឬ ការលើកលែងទោស ដោយអនុលោមតាមមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លើកលែងឱ្យទណ្ឌិតរួចផុតពីការអនុវត្តទោសដែលអនុគ្រោះនោះ ។

**មាត្រា ១៤៨.-** ការជួសជុលការខូចខាតដល់ជនរងគ្រោះក្នុងករណីនៃការអនុគ្រោះទោស

ការអនុគ្រោះទោសមិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលសំណងជួសជុលការខូចខាតទេ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយនៃព្រះរាជក្រឹត្យដែលពាក់ព័ន្ធនឹងការអនុគ្រោះទោសនោះ។

## ផ្នែកទី ៣
## ការលើកលែងទោសជាទូទៅ

**មាត្រា ១៤៩.-** អានុភាពនៃការលើកលែងទោសជាទូទៅ

ការលើកលែងទោសជាទូទៅដូចមានចែងក្នុងមាត្រា ៩០ ថ្មី (ពីរ) វាក្យខណ្ឌទី ៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លុបបំបាត់ចោលនូវទណ្ឌកម្មដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

ទោសមិនអាចយកមកអនុវត្តទេ ។

ទោសដែលកំពុងអនុវត្ត ត្រូវបានបញ្ឈប់ ។

ប៉ុន្តែ ចំពោះប្រាក់ពិន័យ និងប្រាក់ប្រដាប់ក្តី ដែលបានបង់រួចហើយ មិនអាចទារសំណងពីរដ្ឋវិញបានទេ ។

**មាត្រា ១៥០.-** ការលើកលែងទោសជាទូទៅ និងការដកការព្យួរទោស

កាលបើការព្យួរទោសពីមុន ត្រូវបានដកហូតដោយអានុភាពនៃការផ្តន្ទាទោសខាងក្រោយ ការលើកលែងទោសជាទូទៅចំពោះទោសខាងក្រោយនេះ បង្កើតឡើងវិញនូវផលប្រយោជន៍នៃការព្យួរទោសដែលមានពីមុន ។

**មាត្រា ១៥១.-** ការផ្តល់សំណងការខូចខាតដល់ជនរងគ្រោះក្នុងករណីនៃការលើកលែងទោសជាទូទៅ

លើកលែងតែបទប្បញ្ញត្តិផ្ទុយនៃច្បាប់ ការលើកលែងទោសជាទូទៅ មិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលសំណងការជួសជុលនៃការខូចខាតឡើយ ។

## ផ្នែកទី ៤

## ការរៀបចំទោស និងការលុបចោលទោសបន្ថែមខ្លះៗ

**មាត្រា ១៥២.-** លក្ខខណ្ឌនៃការកែប្រែទោសបន្ថែមខ្លះៗ

ក្នុងករណីផ្តន្ទាទោសបន្ថែមដែលមានចែងនៅក្នុងចំណុច ១, ២, ៣, ៤, ៥, ៦, ៧, ១៤, ១៥ និង ១៦ នៃមាត្រា ៥៣(ប្រភេទនៃទោសបន្ថែម) នៃក្រមនេះ តុលាការអាចបង្គាប់ឱ្យរៀបចំកែប្រែ ឬ លុបចោលទោសមួយ ឬ ច្រើន ប្រសិនបើលក្ខខណ្ឌដូចតទៅនេះ ត្រូវបានបំពេញ :

-ភាពច្របូកច្របល់ដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបណ្តាលមកពីបទល្មើសបានបញ្ឈប់

-ព្យសនកម្ម ត្រូវបានជួសជុល និង

-សេចក្តីសម្រេចរៀបចំកែប្រែ ឬលុបចោល មានលក្ខណៈអនុគ្រោះឱ្យធ្វើការបញ្ចូលជនល្មើសទៅរស់នៅក្នុងសង្គមវិញ ។

តុលាការទទួលពាក្យប្តឹងពីអយ្យការតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ឬ តាមពាក្យប្តឹងរបស់ទណ្ឌិត ។ តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់យោបល់របស់តំណាងអយ្យការ ទណ្ឌិត និងជាយថាហេតុ មេធាវីរបស់ជននេះ ។

**មាត្រា ១៥៣.-** ការធ្វើឱ្យមានឡើងវិញនូវសិទ្ធិពលរដ្ឋទាំងអស់ ឬ ខ្លះៗ

ក្នុងករណីដកសិទ្ធិពលរដ្ឋ តុលាការអាចធ្វើឱ្យមានឡើងវិញនូវសិទ្ធិពលរដ្ឋទាំងអស់ដែលរៀបរាប់នៅមាត្រា ៥៥ (សិទ្ធិពលរដ្ឋដែលអាចដកបាន) នៃក្រមនេះ ឬ ក៏សិទ្ធិខ្លះក្នុងចំណោមសិទ្ធិទាំងនេះ ។

**មាត្រា ១៥៤.-** ការរៀបចំកែប្រែ ឬ ការលុបចោលនូវការហាមឃាត់

តុលាការអាចរៀបចំកែប្រែ ឬ លុបចោលនូវ :

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ ឬ សកម្មភាពសង្គម ។

២-ការហាមឃាត់ចំពោះការបើកបរយានយន្ត ។

**មាត្រា ១៥៥.–** ការប្រគល់ឱ្យវិញនូវលិខិតបើកបរ

ក្នុងករណីព្យួរលិខិតបើកបរ តុលាការអាចបង្គាប់ឱ្យប្រគល់លិខិតបើកបរនេះទៅម្ចាស់វិញ ។

**មាត្រា ១៥៦.–** ការកែប្រែវិធានការនៃការហាមឃាត់ចំពោះការស្នាក់នៅ

ក្នុងករណីផ្តន្ទាទោសហាមឃាត់ចំពោះការស្នាក់នៅ តុលាការអាចកែប្រែបែបបទនៃវិធានការតាមដាន ។

ក្នុងករណីបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យស្នាក់នៅជាបណ្តោះអាសន្ន សម្រាប់រយៈពេលដែលមិនអាចលើសពី ៨ (ប្រាំបី) ថ្ងៃ នៅក្នុងទីកន្លែងដែលហាមឃាត់ ។ ព្រះរាជអាជ្ញាជូនព័ត៌មានអំពីកិច្ចនេះដល់តុលាការ ។

សេចក្តីសម្រេចរបស់តុលាការ និងព្រះរាជអាជ្ញា ត្រូវបានជូនដំណឹងដល់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ។

**មាត្រា ១៥៧.–** ការកែប្រែការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា

តុលាការអាចលុបចោលការហាមឃាត់ ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ តុលាការអាចគ្រោងទុកនូវលក្ខខណ្ឌនានា ប្រសិនបើយល់ឃើញថាជាការចាំបាច់ ។

**មាត្រា ១៥៨.–** ការកែប្រែការហាមឃាត់ការចូលមកក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា

តុលាការអាចលុបចោលការហាមឃាត់ចំពោះការស្នាក់នៅ និងការចូលក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាដល់ទណ្ឌិតបរទេស ។

ប៉ុន្តែ ជាបឋម ព្រះរាជអាជ្ញាត្រូវតែទទួលយោបល់ពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជូនដំណឹងអំពីយោបល់នេះទៅតុលាការ ។

យោបល់នេះមិនបង្ខំឱ្យតុលាការត្រូវតែអនុវត្តតាមទេ ។

**មាត្រា ១៥៩.–** ការកែប្រែការបណ្តេញចេញ ការបិទ ការហាមឃាត់ការធ្វើអាជីវកម្ម

តុលាការអាចរៀបចំកែប្រែទោស ឬ បញ្ចប់នូវទោសដូចខាងក្រោមនេះ :

១-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

២-ការបិទគ្រឹះស្ថាន ។

៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថានដែលបើកចំហ ដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន ។

## ជំពូកទី ៦
## ទោសដែលអាចអនុវត្តចំពោះអនីតិជន
### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦០.-** មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ

កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ :

១-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។

២-ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

៣-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ ។

៤-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬ តិចជាង ៥ (ប្រាំ)ឆ្នាំនោះ បទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល ។

**មាត្រា ១៦១.-** ទោសបន្ថែម

មានតែទោសបន្ថែមដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជន :

១-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

២-ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

**មាត្រា ១៦២.-** ទោសការងារសហគមន៍

ទោសដែលជាការងារសហគមន៍ អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦ (ដប់ប្រាំមួយ) ឆ្នាំ ប៉ុន្តែថិរវេលានៃការងារមិនអាចលើសពី ១០០ (មួយរយ)ម៉ោង ។

ការងារសហគមន៍ត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈជាការបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ ។

**មាត្រា ១៦៣.-** ការមិនអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល

បទប្បញ្ញត្តិស្តីពីការមិនរាងចាល មិនអនុវត្តទៅលើអនីតិជនទេ ។

**មាត្រា ១៦៤.-** ការទទួលប្រយោជន៍នៃស្ថានសម្រាលទោស

ស្ថានសម្រាលទោសត្រូវអនុវត្តទៅលើអនីតិជន ។

កាលបើតុលាការបានសម្រេចឱ្យមានស្ថានសម្រាលទោស អប្បបរមានៃមូលទោសលើអនីតិជនពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ត្រូវបន្ថយតាមខ្នាតដោយឡែកដូចតទៅ :

១-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ១ (មួយ) ឆ្នាំ ។

២-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ៥ (ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ ។

៣-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ២ (ពីរ) ឆ្នាំ និងតិចជាង ៥ (ប្រាំ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៣ (បី) ខែ ។

៤-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬ លើសពី ៦ (ប្រាំមួយ) ខែ និងតិចជាង ២ (ពីរ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយត្រឹម ១ (មួយ) ថ្ងៃ ។

៥-អប្បបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

**មាត្រា ១៦៥.-** កាតព្វកិច្ចដោយឡែកក្នុងករណីនៃការព្យួរទោសសាកល្បង

នៅក្នុងករណីនៃការព្យួរទោសសាកល្បង មានតែកាតព្វកិច្ចដោយឡែកដូចតទៅនេះប៉ុណ្ណោះដែលអាចអនុវត្តទៅលើអនីតិជន :

១-ទទួលការបង្ហាត់បង្រៀន ឬ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

២-ស្ថិតនៅទីកន្លែងមួយជាកំណត់ ។

៣-ដាក់ខ្លួនឱ្យពេទ្យពិនិត្យ ឬ ព្យាបាល ។

៤-ជួសជុលល្មើសនកម្មដែលបណ្តាលមកអំពីបទល្មើស ទៅតាមធនធានរបស់ខ្លួន ។

៥-បង្ហាញភស្តុតាងបញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយ តាមលទ្ធភាពនៃធនធានរបស់ខ្លួន បន្ទាប់ពីការផ្តន្ទាទោស ។

៦-មិនត្រូវបង្ហាញមុខនៅទីកន្លែងខ្លះ ។

៧-មិនត្រូវសេពគប់ ទីកន្លែងលក់ភេសជ្ជៈស្រវឹង ។

៨-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ដោយឡែកជាមួយសហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬ ជនរងគ្រោះនៃបទល្មើស ។

៩-មិនត្រូវកាន់កាប់ ឬ យកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

## ផ្នែកទី ២
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៦៦.-** លក្ខខណ្ឌនៃការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារ

អនីតិជនដែលជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅទីកន្លែងពិសេស ខណ្ឌដាច់ពីនីតិជន ។ អនីតិជនស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គល ដែលជាទីកន្លែងសម្រាប់អប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

របបឃុំឃាំងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ៧

## ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល

### ផ្នែកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦៧.–** ទោសដែលត្រូវរងដោយនីតិបុគ្គល

ទោសជាយថាប្រភេទដែលត្រូវរងដោយនីតិបុគ្គលមានដូចតទៅ :

១-ទោសពិន័យក្នុងឋានៈជាមូលទោស ។

២-ទោសបន្ថែមដែលរៀបរាប់នៅក្នុងមាត្រា ១៦៨(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមនេះ ។

### ផ្នែកទី ២

### ទោសបន្ថែម

**មាត្រា ១៦៨.–** ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល

ទោសបន្ថែមត្រូវអនុវត្តទៅលើនីតិបុគ្គលមានដូចតទៅ :

១-ការរំលាយចោល ។

២-ការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ ។

៣-ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬ ច្រើន ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ ។

៦-ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបាន ដែលកំណត់ដោយធនាគារ ។

៧-ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់ ។

៨-ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬ ប្រព្រឹត្តបទល្មើស ។

៩-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬ ដែលបានប្រើប្រាស់ដោយសាធារណជន ។

១០-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្ត

ROYAUME DU CAMBODGE MINISTRE DU PALAIS ROYAL

បទល្មើស ឬ ដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស ។

១១-ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

១២-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

១៣-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត ។

១៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បទប្បញ្ញត្តិដោយឡែកអាចបង្កើតទោសបន្ថែមដទៃទៀតបាន ។

**មាត្រា ១៦៩.-** លក្ខខណ្ឌនៃការសម្រេចអំពីទោសបន្ថែម

ទោសបន្ថែមអាចនឹងប្រកាសបានដោយតុលាការ ប្រសិនបើទោសនោះត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសដែលចោទប្រកាន់ ។

**មាត្រា ១៧០.-** ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល

សេចក្តីសម្រេចដែលបង្គាប់ឱ្យរំលាយនីតិបុគ្គល នាំឱ្យមានការបញ្ជូននីតិបុគ្គលនេះទៅតុលាការមានសមត្ថកិច្ច ដើម្បីធ្វើការជម្រះបញ្ជី ។

**មាត្រា ១៧១.-** ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ

ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការមិនអាចលើសពី ៥ (ប្រាំ) ឆ្នាំទេ ។ សេចក្តីសម្រេចដាក់ការត្រួតពិនិត្យតាមដានរបស់តុលាការនាំឱ្យមានការចាត់តាំងអាណត្តិគាហកតុលាការដែលតុលាការបញ្ជាក់បេសកកម្ម ។ ជារៀងរាល់ ៦ (ប្រាំមួយ) ខែ យ៉ាងតិច អាណត្តិគាហកតុលាការធ្វើរបាយការណ៍ ជូនព្រះរាជអាជ្ញាអំពីដំណើរការនៃបេសកកម្មរបស់ខ្លួន ។

ក្រោយពីបានឃើញរបាយការណ៍របស់អាណត្តិគាហកតុលាការ ព្រះរាជអាជ្ញាអាចប្តឹងទៅតុលាការដែលបានប្រកាសឱ្យធ្វើការដាក់ក្រោមការតាមដានរបស់តុលាការ ។ តុលាការអាចប្រកាសនូវទោសថ្មីមួយ ។

តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់យោបល់របស់អយ្យការ អាណត្តិគាហកតុលាការ និងជាយថាហេតុ មេធាវីរបស់នីតិបុគ្គលនោះ ។

**មាត្រា ១៧២.–** ការហាមឃាត់ចំពោះការធ្វើសកម្មភាព

ការហាមឃាត់ចំពោះការធ្វើសកម្មភាព អាចជាស្ថាពរ ឬ ជាបណ្តោះអាសន្ន សម្រាប់ចិរវេលា ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

តុលាការបញ្ជាក់អំពីសកម្មភាពដែលត្រូវហាមឃាត់ ។

**មាត្រា ១៧៣.–** ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ

ទោសបណ្តេញចេញពីលទ្ធកម្មសាធារណៈ នាំឱ្យមានការហាមឃាត់ចំពោះការចូលរួម ដោយផ្ទាល់ ឬ ដោយប្រយោលនៅក្នុងគ្រប់លទ្ធកម្មសាធារណៈដែលរៀបចំដោយ :

១-រដ្ឋ ។

២-រដ្ឋបាលថ្នាក់ក្រោមជាតិ ។

៣-គ្រឹះស្ថានសាធារណៈ ។

៤-សហគ្រាសដែលទទួលសម្បទានពីរដ្ឋ ឬ ពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬ ដែលត្រួតពិនិត្យដោយរដ្ឋ ឬ ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ទោសនេះ អាចជាស្ថាពរ ឬ ជាបណ្តោះអាសន្ន សម្រាប់ចិរវេលាមួយមិនលើសពី ៥ (ប្រាំ) ឆ្នាំ ។

**មាត្រា ១៧៤.–** ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ

ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ឱ្យធ្វើការដាក់ប្រាក់សន្សំ អាចជាស្ថាពរ ឬ ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

ការហាមឃាត់នេះ នាំឱ្យមានការហាមឃាត់ដល់នីតិបុគ្គលចំពោះការអំពាវនាវដើម្បីឱ្យដាក់ឧបករណ៍អាចជួញដូរបានរបស់ខ្លួនទៅក្នុងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬ ក្រុមហ៊ុនមូលបត្រ ។

ការហាមឃាត់នេះនាំឱ្យមានការហាមឃាត់ចំពោះការផ្សព្វផ្សាយជាសាធារណៈដែរ ។

**មាត្រា ១៧៥.–** ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន

ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន អាចជាស្ថាពរ ឬ ជាបណ្តោះអាសន្ន សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

ចំពោះការហាមឃាត់ប្រើប្រាស់បណ្ណទូទាត់ ក៏ដូចគ្នាដែរ ។

**មាត្រា ១៧៦.-** ការបិទគ្រឹះស្ថាន

ទោសបិទគ្រឹះស្ថាន នាំឱ្យមានការហាមឃាត់ចំពោះការប្រព្រឹត្តនៅក្នុងគ្រឹះស្ថាននេះ នូវសកម្មភាពដែលបទល្មើសបានកើតឡើងនៅក្នុងឱកាសដែលធ្វើសកម្មភាពនេះ។

ទោសនេះអាចជាស្ថាពរ ឬ ជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ១៧៧.-** ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន

ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានមួយ ដែលបើកចំហដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន អាចជាស្ថាពរ ឬ ជាបណ្តោះអាសន្នក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

**មាត្រា ១៧៨.-** ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស

កាលបើការរឹបអូសក្លាយជាស្ថាពរ វត្ថុរឹបអូសក្លាយជាកម្មសិទ្ធិរបស់រដ្ឋ លើកលែងតែបទប្បញ្ញត្តិដោយឡែកបានចែងអំពីការប្រគល់ផ្សេងទៀត ។

រដ្ឋអាចលក់ ឬ បំផ្លាញចោលវត្ថុរឹបអូសនៅក្នុងទម្រង់ដែលមានចែងសម្រាប់ការលក់ទ្រព្យសម្បត្តិរបស់រដ្ឋ ។ ច្បាប់អាចចែងអំពីការបំផ្លាញចោលនូវវត្ថុខ្លះផងដែរ ។

កាលបើវត្ថុរឹបអូសមិនត្រូវបានចាប់យកទេ ហើយនិងមិនអាចប្រគល់ឱ្យបានទេនោះ ទណ្ឌិតត្រូវចេញសងតម្លៃនៃវត្ថុរឹបអូសនេះ ។ តម្លៃនេះត្រូវបានកំណត់ដោយតុលាការ ។ វិធានការដើម្បីប្រមូលប្រាក់នេះ ត្រូវធ្វើឡើងដូចក្នុងរឿងបង្ខិតបង្ខំដល់រូបកាយដែរ ។

**មាត្រា ១៧៩.-** ការរឹបអូស និងសិទ្ធិតតិយជន

ការរឹបអូសអាចធ្វើទៅលើវត្ថុដូចខាងក្រោមនេះ :

១-ឧបករណ៍ សម្ភារៈ ឬ វត្ថុអ្វីមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស ។

២-វត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

៤-ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុនៅទីកន្លែងដែលបទល្មើសបានកើត

ក៏ប៉ុន្តែ ការរឹបអូសមិនអាចត្រូវប្រកាសបានទេ ប្រសិនបើការរឹបអូសនោះប៉ះពាល់ដល់សិទ្ធិរបស់តតិយជន ។

**មាត្រា ១៨០.-** ការបិទផ្សាយសេចក្តីសម្រេច

ការបិទផ្សាយសេចក្តីសម្រេច ត្រូវអនុវត្តនៅទីកន្លែងដែលចង្អុលប្រាប់ដោយតុលាការ និងសម្រាប់រយៈពេលមួយដែលកំណត់ឡើងដោយតុលាការ ។ ការបិទផ្សាយមិនអាចលើសពី ២ (ពីរ) ខែ ។ ការបិទផ្សាយ អាចទាំងស្រុងតាមសម្រង់ ឬ តាមនិទ្ទេសធម្មតា ។ សោហ៊ុយនៃការបិទផ្សាយជាបន្ទុករបស់នីតិបុគ្គលដែលត្រូវផ្តន្ទាទោស ។

ក្នុងករណីដែលដកបំបាត់ចេញ លាក់បំបាំង ឬ ហែកចោលសេចក្តីប្រកាសបិទផ្សាយនោះ ត្រូវធ្វើការបិទផ្សាយជាថ្មីម្តងទៀត ។ សោហ៊ុយនៃការបិទផ្សាយនេះ ត្រូវចេញដោយជនល្មើសដែលជាអ្នកដកបំបាត់ចោល លាក់បំបាំង ឬ ហែកចោល ។

**មាត្រា ១៨១.-** ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍

ទោសផ្សាយសេចក្តីសម្រេច តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ត្រូវអនុវត្តតាមបែបបទដែលកំណត់ឡើងដោយតុលាការ ។ ការផ្សាយនេះ មិនអាចលើសពី ៨ (ប្រាំបី) ថ្ងៃ ។ ការផ្សាយនេះ អាចផ្សាយទាំងស្រុងតាមសម្រង់ ឬ តាមនិទ្ទេស ។ សោហ៊ុយនៃការផ្សាយជាបន្ទុករបស់នីតិបុគ្គលដែលត្រូវផ្តន្ទាទោស ។

ទោសផ្សព្វផ្សាយសេចក្តីសម្រេចរបស់តុលាការត្រូវចុះផ្សាយក្នុងសារព័ត៌មានសរសេរ តាមបែបបទ និងក្នុងចិរវេលាដែលកំណត់ដោយតុលាការ ។ សោហ៊ុយក្នុងការចុះផ្សាយជាបន្ទុករបស់នីតិបុគ្គល ។ បើតុលាការបានបង្គាប់ការផ្សព្វផ្សាយសេចក្តីសម្រេច សារព័ត៌មានមិនអាចបដិសេធការចុះផ្សាយនេះបានទេ ។

**មាត្រា ១៨២.-** ការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងរូបវន្តបុគ្គល និងនីតិបុគ្គល

បទប្បញ្ញត្តិនៃមាតិកាទី ១ មាតិកាទី ២ និងមាតិកាទី ៣ នៃគន្ថីទី ១ នៃក្រមនេះ ដែលទាក់ទងនឹងរូបវន្តបុគ្គល ត្រូវអនុវត្តទៅលើនីតិបុគ្គលក្នុងកម្រិតដែលបទប្បញ្ញត្តិនេះ មិនផ្ទុយនឹងបទប្បញ្ញត្តិនៃជំពូកនេះ ។

# គន្ថីទី ២
# បទល្មើសប្រឆាំងនឹងបុគ្គល
## មាតិកាទី ១
## បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋសង្គ្រាម
### ជំពូកទី ១
### បទឧក្រិដ្ឋប្រល័យពូជសាសន៍

**មាត្រា ១៨៣.-** បទឧក្រិដ្ឋប្រល័យពូជសាសន៍

បទឧក្រិដ្ឋប្រល័យពូជសាសន៍ គឺជាអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនេះត្រូវបានប្រព្រឹត្តក្នុងគោលបំណងបំផ្លាញទាំងមូល ឬ មួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា ៖

១-ឃាតកម្មលើសមាជិកនៃក្រុម ។

២-ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើបូរណភាពខាងរូបកាយ ឬ សតិបញ្ញារបស់សមាជិកនៃក្រុម ។

៣-ការដាក់ឱ្យសមាជិកនៃក្រុមរស់នៅក្នុងលក្ខខណ្ឌ ដែលនាំឱ្យវិនាសអន្តរាយទាំងស្រុង ឬ មួយផ្នែកនៃក្រុម ។

៤-វិធានការដោយបង្ខំ ឬ មធ្យោបាយដោយមិនបង្ខំ សំដៅរារាំងកំណើតទារកនៅក្នុងក្រុម ។

៥-ជម្លៀសដោយបង្ខំនូវកុមារពីក្រុមមួយទៅក្រុមមួយផ្សេងទៀត ។

**មាត្រា ១៨៤.-** ទោសដែលត្រូវទទួល

បទឧក្រិដ្ឋប្រល័យពូជសាសន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ១៨៥.-** បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋប្រល័យពូជសាសន៍

ការចូលរួមក្នុងក្រុមណាមួយដែលបង្កើតឡើង ឬចូលរួមក្នុងសន្ធិដ្ឋិភាពដែលធ្វើឡើងដើម្បីរៀបចំអំពើឧក្រិដ្ឋប្រល័យពូជសាសន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

បទត្រៀមរៀបចំត្រូវមានលក្ខណៈសំគាល់ដោយអំពើជាក់ស្តែងមួយ ឬ ច្រើន ។

**មាត្រា ១៨៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ១៨៧.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទ-

ROYAUME DU CAMBODGE
SECRETARIAT DU PALAIS ROYAL

ល្មើសដែលបញ្ញត្តក្នុងមាត្រា ១៨៣ (បទឧក្រិដ្ឋប្រល័យពូជសាសន៍) និង មាត្រា ១៨៥(បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋប្រល័យពូជសាសន៍) នៃក្រមនេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០.០០០.០០០ (ហាសិបលាន) រៀល ទៅ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចតទៅនេះ :

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០(ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ ។

២-ការដាក់ឱ្យស្ថិតនៅក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការតាមបែបបទកំណត់ដោយមាត្រា ១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬ ច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២(ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា ១៧៣(ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃតាមបែបបទកំណត់ដោយមាត្រា ១៧៤(ការហាមឃាត់ចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) នៃក្រមនេះ ។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០(ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ជំពូកទី ២

## បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

**មាត្រា ១៨៨.-** បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ គឺជាអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនេះត្រូវបានប្រព្រឹត្តទៅក្នុងក្របខ័ណ្ឌនៃការវាយលុកជាទូទៅ ឬ ជាប្រព័ន្ធ សំដៅប្រឆាំងប្រជាជនស៊ីវិល ៖

១-ឃាតកម្ម ។

២-ការសម្លាប់រង្គាល ។

៣-ការធ្វើឱ្យទៅជាទាសករ ។

៤-ការនិរទេស ឬ ជម្លៀសប្រជាជនដោយបង្ខំ ។

៥-ការដាក់ពន្ធនាគារ ឬ គ្រប់រូបភាពដទៃទៀតនៃការដកហូតយ៉ាងធ្ងន់ធ្ងរនូវសេរីភាពដោយបំពានទៅលើបទប្បញ្ញត្តិគ្រឹះនៃនីតិអន្តរជាតិ ។

៦-ការធ្វើទារុណកម្ម ។

៧-ការចាប់បង្ខំរំលោភសេពសន្ថវៈ ការធ្វើទាសកម្មខាងផ្លូវភេទ ពេស្យាចារដោយបង្ខំ ការមានគភ៌ដោយបង្ខំ វណ្ណកម្មដោយបង្ខំ និងគ្រប់រូបភាពផ្សេងទៀតនៃអំពើហិង្សាខាងផ្លូវភេទ ដែលមានទម្ងន់ប្រហាក់ប្រហែលគ្នា ។

៨-ការធ្វើទុក្ខបុកម្នេញលើក្រុម ឬ សមូហភាពដោយមូលហេតុនយោបាយ ពូជសាសន៍ ក្រុមជាតិ ជាតិពន្ធុ វប្បធម៌ សាសនា ឬ ភេទ ។

៩-ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ។

១០-ការអនុវត្តនយោបាយប្រកាន់ពូជសាសន៍ជាប្រព័ន្ធតាមបែបអាផាថេដ ។

១១-គ្រប់អំពើអមនុស្សធម៌ផ្សេងទៀត ដែលបង្កឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬ ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើបូរណភាពខាងរូបកាយ ។

**មាត្រា ១៨៩.-** ទោសដែលត្រូវទទួល

បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

**មាត្រា ១៩០.-** បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ

ការចូលរួមក្នុងក្រុមដែលបង្កើតឡើង ឬ សន្ធិដ្ឋិភាពដែលធ្វើឡើងដើម្បីរៀបចំអំពើ

ឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

ការត្រៀមរៀបចំ ត្រូវមានលក្ខណៈសំគាល់ដោយអំពើជាក់ស្តែងមួយ ឬ ច្រើន ។

**មាត្រា ១៩១.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ដល់ជនបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

មាត្រា ១៩២.- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ១៨៨ (បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ) និងមាត្រា ១៩០ (បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ) នៃក្រមនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០.០០០.០០០ (ហាសិបលាន)រៀលទៅ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចតទៅនេះ :

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០(ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ ។

២-ការដាក់ឱ្យស្ថិតនៅក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការតាមបែបបទ កំណត់ដោយមាត្រា ១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬ ច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២(ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ ដោយមាត្រា ១៧៣(ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤ (ការហាមឃាត់ចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) នៃក្រមនេះ ។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០(ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ជំពូកទី ៣
## បទឧក្រិដ្ឋសង្គ្រាម

**មាត្រា ១៩៣.–** បទឧក្រិដ្ឋសង្គ្រាម

បទឧក្រិដ្ឋសង្គ្រាម គឺជាអំពើណាមួយក្នុងចំណោមអំពើដែលរៀបរាប់ខាងក្រោមនេះ កាលបើអំពើនោះត្រូវបានប្រព្រឹត្តប្រឆាំងនឹងបុគ្គល ឬ ទ្រព្យសម្បត្តិ ដែលការពារដោយអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ ៖

១-ឃាតកម្ម ។

២-ទារុណកម្ម ឬ គ្រប់អំពើអមនុស្សធម៌ រួមបញ្ចូលទាំងការពិសោធជីវសាស្ត្រ ។

៣-អំពើបង្កដោយចេតនានូវការឈឺចាប់ ឬ ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បូរណភាពខាងរូបកាយ ឬ សុខភាព ។

៤-ការបំផ្លាញ ឬ ការធ្វើឱ្យខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិ ដោយគ្មានហេតុផលចាំបាច់ខាងយោធា និងក្នុងទ្រង់ទ្រាយធំដោយខុសច្បាប់ និងតាមទំនើងចិត្ត ។

៥-អំពើបង្ខំឈ្លើយសឹក ឬ ជនស៊ីវិល ឱ្យបម្រើក្នុងកងកម្លាំងប្រដាប់អាវុធរបស់សត្រូវ ។

៦-អំពើដកហូតសិទ្ធិរបស់ឈ្លើយសឹក ឬ ជនស៊ីវិល ក្នុងការទទួលការវិនិច្ឆ័យដោយត្រឹមត្រូវ និងឥតលំអៀង ។

៧-ជម្លៀស ការបញ្ជូន ឬ ការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់ ។

៨-ការចាប់ជនស៊ីវិលជាចំណាប់ខ្មាំង ។

**មាត្រា ១៩៤.–** បទឧក្រិដ្ឋសង្គ្រាមផ្សេងទៀត

អំពើណាមួយដូចមានចែងខាងក្រោមនេះ គឺជាបទឧក្រិដ្ឋសង្គ្រាមដែរ កាលបើអំពើនោះ ត្រូវបានប្រព្រឹត្តក្នុងនិកាសជម្លោះប្រដាប់អាវុធជាលក្ខណៈអន្តរជាតិ ឬ មិនមែនអន្តរជាតិ ៖

១-ការប្រើប្រាស់អាវុធដែលមានជាតិពុល ឬ អាវុធដែលស្ថាបនាឡើងដើម្បីបង្កការឈឺចាប់ឥតប្រយោជន៍ ។

២-អំពើវាយប្រហារ ឬ ទម្លាក់គ្រាប់បែកដោយចេតនា តាមមធ្យោបាយណាក៏ដោយទៅលើទីក្រុង ភូមិ ទីកន្លែងរស់នៅ ឬ អគារដែលមិនមានការការពារ និងដែលមិន

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ក្រសួងព្រះបរមរាជវាំង

មែនជាកម្មវត្ថុខាងយោធា ។

៣-អំពើវាយប្រហារដោយចេតនាទៅលើមនុស្ស ឬ សម្ភារៈដែលប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃបេសកកម្មមនុស្សធម៌ ដោយអនុលោមតាមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ។

៤-អំពើបង្កគ្រោះថ្នាក់ដោយចេតនា ដល់ប្រជាជនស៊ីវិល ដោយដកហូតនូវទ្រព្យសម្បត្តិចាំបាច់សម្រាប់បន្តការរស់រានមានជីវិតរបស់ជនស៊ីវិលទាំងនេះ ។

៥-អំពើប្រើប្រាស់ជនស៊ីវិល ដើម្បីបញ្ចៀសពីគោលដៅនៃប្រតិបត្តិការយោធាទៅលើអគារខ្លះ តំបន់ខ្លះនៃដែនដី ឬ កងកម្លាំងយោធាខ្លះ ។

៦-អំពើបំផ្លាញ ឬ ធ្វើឱ្យខូចខាតដោយចេតនានូវអគារសម្រាប់សាសនាសប្បុរសធម៌ អប់រំ សិល្បៈ និងវិទ្យាសាស្ត្រ វិមានប្រវត្តិសាស្ត្រ ស្នាដៃសិល្បៈ ឬ ស្នាដៃ ដែលមានលក្ខណៈវិទ្យាសាស្ត្រ ។

៧-អំពើបង្កដល់បរិស្ថានធម្មជាតិ នូវការខូចខាតដ៏ធំ យូរអង្វែង និងធ្ងន់ធ្ងរ ដែលមានលក្ខណៈហួសហេតុយ៉ាងជាក់ស្តែង បើប្រៀបទៅនឹងផលប្រយោជន៍ពិតប្រាកដ និង ផ្ទាល់ខាងផ្នែកយោធាដែលសង្ឃឹមទុក ។

៨-ការលួចប្លន់សម្បត្តិសាធារណៈ ឬ ឯកជន ។

**មាត្រា ១៩៥.–** ទោសដែលត្រូវទទួល

បទឧក្រិដ្ឋសង្គ្រាម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ១៩៦.–** បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋសង្គ្រាម

ការចូលរួមក្នុងក្រុមដែលបង្កើតឡើង ឬ សន្ធិដ្ឋិភាពដែលធ្វើឡើងដើម្បីរៀបចំអំពើឧក្រិដ្ឋសង្គ្រាម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

ការត្រៀមរៀបចំ ត្រូវមានលក្ខណៈសំគាល់ដោយអំពើជាក់ស្តែងមួយ ឬ ច្រើន ។

**មាត្រា ១៩៧.–** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានសម្រេច :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាង

ROYAUME DU CAMBODGE ព្រះរាជាណាចក្រកម្ពុជា ... ROYAL

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទឧក្រិដ្ឋត្រូវបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ដល់ទណ្ឌិតបរទេស ចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយនូវគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ១៩៨.- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ១៩៣ (បទឧក្រិដ្ឋសង្គ្រាម) មាត្រា ១៩៤ (បទឧក្រិដ្ឋសង្គ្រាមផ្សេងទៀត) និងមាត្រា ១៩៦ (បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋសង្គ្រាម) នៃក្រមនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០.០០០.០០០ (ហាសិបលាន) រៀលទៅ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចតទៅ

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះ



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ក្រសួងព្រះបរមរាជវាំង

1/24 Ksl

បញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ ។

២-ការដាក់ឱ្យស្ថិតនៅក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការតាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬ ច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤ (ការហាមឃាត់ចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) នៃក្រមនេះ ។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## មាតិកាទី ២

## ការប៉ះពាល់ដល់មនុស្ស

### ជំពូកទី ១

### ការប៉ះពាល់ដល់ជីវិតមនុស្ស

#### ផ្នែកទី ១

#### ការប៉ះពាល់ដោយចេតនាដល់ជីវិតមនុស្ស

មាត្រា ១៩៩.- បទឃាតកម្ម

អំពើសម្លាប់មនុស្សដោយចេតនា ដោយប្រើអាវុធ ឬ មិនប្រើអាវុធ ដោយគ្មានស្ថានទម្ងន់ណាមួយដូចបានកំណត់ក្នុងមាត្រា ២០០ (បទឃាតកម្មគិតទុកជាមុន) ដល់មាត្រា ២០៥

(បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬ អំពើរំលោភសេពសន្ថវៈ) នៃក្រមនេះ គឺជាឃាតកម្ម ។

ឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ២០០.–** បទឃាតកម្មគិតទុកជាមុន

ឃាតកម្មគិតទុកជាមុន គឺអំពើសម្លាប់មនុស្សដោយគិតទុកជាមុន ឬ ដោយការលួនស្ទាក់ ។

ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ ។

ការលួនស្ទាក់ គឺជាអំពើឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលមួយរយៈ ដើម្បីប្រព្រឹត្តអំពើបៀតបៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ ។

ឃាតកម្មគិតទុកជាមុន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ២០១.–** បទឃាតកម្មដោយការប្រើថ្នាំពុល

ឃាតកម្មដែលប្រព្រឹត្តដោយការប្រើថ្នាំពុល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ២០២.–** បទឃាតកម្មដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ

ឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្តទៅលើ :

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬ ពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

៤-អ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬ នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

**មាត្រា ២០៣.-** បទឃាតកម្មដែលមានស្ថានទម្ងន់ទោសដោយសារគោលដៅ

ឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្តទៅលើ :

១-ជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរារាំងជននេះកុំឱ្យប្តឹងបរិហារពីបទល្មើស ឬ សុំឱ្យធ្វើការជួសជុលព្យសនកម្ម ។

២-សាក្សី ដើម្បីរារាំងកុំឱ្យឆ្លើយផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬ នៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

៣-ជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះជននេះបានបរិហារពីបទល្មើស ឬ សុំឱ្យជួសជុលព្យសនកម្ម ។

៤-សាក្សី ដោយមូលហេតុសាក្សីនេះបានផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬ នៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

**មាត្រា ២០៤.-** បទឃាតកម្មប្រព្រឹត្តដោយអ្នករាជការសាធារណៈ

ឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្តដោយអ្នករាជការសាធារណៈនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬ នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

**មាត្រា ២០៥.-** បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬ អំពើរំលោភសេពសន្ថវៈ

ឃាតកម្មដែលកើតក្នុងពេល ឬ ក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម អំពើឃោរឃៅ ឬ អំពើរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ២០៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តនៅក្នុងពេលប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ជនបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២

## ការប៉ះពាល់ដោយអចេតនាដល់ជីវិតមនុស្ស

**មាត្រា ២០៧.-** បទមនុស្សឃាតដោយអចេតនា

បទមនុស្សឃាតដោយអចេតនា គឺជាអំពើបណ្តាលឱ្យស្លាប់អ្នកដទៃដោយ :

១-ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬ ការខ្ជីខ្ជា ។

២-ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬ កាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ ។

បទមនុស្សឃាតដោយអចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ២០៨.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាសចំពោះបទមនុស្សឃាតដោយអចេតនា :

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL *

នៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការបើកបរយានយន្ត ទោះបីជាប្រភេទណាក៏ដោយ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការលុបលិខិតបើកបរ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ សម្រាប់ រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ២០៩.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២០៧ (បទមនុស្សឃាតដោយអចេតនា) នៃក្រមនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចតទៅនេះ :

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ ។

២-ការដាក់ឱ្យស្ថិតនៅក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬ ច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

ROYAUME DU CAMBODGE SECRETARIAT DU PALAIS ROYAL

៤-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយមាត្រា ១៧៧ (ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) នៃក្រមនេះ ។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ជំពូកទី ២
## ការប៉ះពាល់ដល់បូរណភាពនៃបុគ្គល
### ផ្នែកទី ១
### ទារុណកម្ម និងអំពើឃោរឃៅ

**មាត្រា ២១០.-** បទទារុណកម្ម និងអំពើឃោរឃៅ

ទារុណកម្ម ឬអំពើឃោរឃៅដែលប្រព្រឹត្តទៅលើបុគ្គលណាមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ២១១.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ២១០ (បទទារុណកម្ម និងអំពើឃោរឃៅ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើនេះ ត្រូវបានប្រព្រឹត្តទៅលើ :

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើស

ត ទៅរាជកិច្ចលេខ ២



03/214
ksl

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬ ពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

**មាត្រា ២១២.-** ស្ថានទម្ងន់ទោសដោយសារគោលដៅ

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ២១០ (បទទារុណកម្ម និងអំពើឃោរឃៅ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើនេះ ត្រូវបានប្រព្រឹត្តទៅលើ :

១-ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរារាំងជននេះកុំឱ្យប្តឹងបរិហារពីបទល្មើស ឬ សុំឱ្យធ្វើការជួសជុលព្យសនកម្ម ។

២-សាក្សី ដើម្បីរារាំងកុំឱ្យឆ្លើយផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬ នៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

៣-ជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះជននេះបានបរិហារពីបទល្មើស ឬ សុំឱ្យជួសជុលព្យសនកម្ម ។

៤-សាក្សី ដោយមូលហេតុសាក្សីនេះបានផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬ នៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

**មាត្រា ២១៣.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងចារី

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ២១០ (បទទារុណកម្ម និងអំពើឃោរឃៅ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើបទឧក្រិដ្ឋនេះ ត្រូវបានប្រព្រឹត្តដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬ នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

**មាត្រា ២១៤.-** ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬ ពិការភាព

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ២១០ (បទទារុណកម្ម និងអំពើឃោរឃៅ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើបទឧក្រិដ្ឋនេះនាំឱ្យមានការកាត់អវយវៈ ឬឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ។

**មាត្រា ២១៥.-** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ២១០ (បទទារុណកម្ម និងអំពើឃោរឃៅ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើបទឧក្រិដ្ឋនេះ បណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់ ឬ នាំឱ្យមានអត្តឃាតរបស់ជននោះ ។

**មាត្រា ២១៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុផ្សេងទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ទស្សនៈទំនើប សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២
## អំពើហិង្សា

**មាត្រា ២១៧.-** បទហិង្សាដោយចេតនា

អំពើហិង្សាប្រព្រឹត្តដោយចេតនាលើអ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ២១៨.-** ស្ថានទម្ងន់ទោស

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំនិងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០(ដប់លាន) រៀល កាលបើអំពើហិង្សានេះបានប្រព្រឹត្ត :

១-ដោយមានការគិតទុកជាមុន ។

២-ដោយប្រើអាវុធ ឬ គំរាមកំហែងនឹងអាវុធ ។

៣-ដោយមានមនុស្សច្រើននាក់ក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត និង ជាអ្នកសមគំនិត ។

**មាត្រា ២១៩.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០(ដប់លាន) រៀល កាលបើអំពើហិង្សានេះត្រូវបានប្រព្រឹត្តទៅលើ :

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬ ពិការភាព ឬ ឱនភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

**មាត្រា ២២០.-** ស្ថានទម្ងន់ទោសដោយសារគោលដៅ

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើនេះ ត្រូវបានប្រព្រឹត្តទៅលើ :

១-ជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរារាំងជននេះកុំឱ្យប្តឹងបរិហារពីបទល្មើស ឬ សុំឱ្យធ្វើការជួសជុលព្យសនកម្ម ។

២-សាក្សី ដើម្បីរារាំងកុំឱ្យឆ្លើយផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬ នៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

៣-ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះជននេះបានបរិហារពីបទល្មើស ឬ សុំឱ្យជួសជុលព្យសនកម្ម ។

៤-សាក្សី ដោយមូលហេតុសាក្សីនេះបានផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬ នៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

**មាត្រា ២២១.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនល្មើស

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើហិង្សានេះ ត្រូវបានប្រព្រឹត្តដោយ អ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬ នៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ។

**មាត្រា ២២២.-** អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ ឬ អនីតិសង្វាសជន

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០(ដប់លាន) រៀល កាលបើអំពើហិង្សានេះ ត្រូវបានប្រព្រឹត្តដោយសហព័ទ្ធ ឬ ដោយអនីតិសង្វាសជនរបស់ជនរងគ្រោះ ។

**មាត្រា ២២៣.-** ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬ ពិការភាព

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០(ដប់) ឆ្នាំ កាលបើអំពើនេះនាំឱ្យមានការកាត់អវយវៈ ឬ ឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរង

**មាត្រា ២២៤.-** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះបណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់ ។

**មាត្រា ២២៥.-** ការចាត់ទុកការប្រើសារធាតុពុលដូចជាអំពើហិង្សាដោយចេតនា

អំពើដែលឱ្យអ្នកដទៃផឹក លេប ឬបញ្ចូលទៅក្នុងខ្លួនអ្នកដទៃ តាមមធ្យោបាយណាក៏ដោយ ដោយចេតនានូវសារធាតុពុលដែលបណ្តាលឱ្យខូចសុខភាព ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា ។

**មាត្រា ២២៦.-** ការចាត់ទុកការផ្តល់អាហារដែលមានសារធាតុពុល ដូចជាអំពើហិង្សាដោយចេតនា

អំពើលក់ ធ្វើអនុប្បទាន ឬ ឱ្យចំណី ឬ ភេសជ្ជៈ ដោយដឹងថាចំណី ឬ ភេសជ្ជៈនោះមានសារធាតុពុលនាំឱ្យខូចសុខភាពនោះ ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា ។

**មាត្រា ២២៧.-** ការចាត់ទុកការបញ្ចូលសារធាតុពុលក្នុងទឹកសម្រាប់បរិភោគដូចជាអំពើហិង្សាដោយចេតនា

អំពើប្រព្រឹត្តឡើងដោយចេតនា ដោយដាក់បញ្ចូលនូវសារធាតុពុលនាំឱ្យខូចសុខភាពទៅក្នុងទឹកសម្រាប់ហូបជាសាធារណៈ ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា ។

**មាត្រា ២២៨.-** បទហិង្សាស្រាល

អំពើប្រព្រឹត្តទៅលើអ្នកដទៃនូវហិង្សាស្រាល ដែលមិននាំឱ្យមានរបួសទេនោះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

**មាត្រា ២២៩.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសត្រូវបានប្រព្រឹត្ត

នៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំយ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ២៣០.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២២៦(ការចាត់ទុកការផ្តល់អាហារដែលមានសារធាតុពុលដូចជាអំពើហិង្សាដោយចេតនា) និងមាត្រា ២២៧(ការចាត់ទុកការបញ្ចូលសារធាតុពុលក្នុងទឹកសម្រាប់បរិភោគ ដូចជាអំពើហិង្សាដោយចេតនា) នៃក្រមនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចតទៅនេះ :

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ ។

២-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬ ច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤ (ការហាមឃាត់ចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) នៃក្រមនេះ ។

៦-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមនេះ ។

៧-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយមាត្រា ១៧៧ (ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) នៃក្រមនេះ ។

៨-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និង មាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៩-ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

១០-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសតាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

១១-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

១២-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍) នៃក្រម

## ផ្នែកទី ៣
## ការគំរាមកំហែង

**មាត្រា ២៣១.-** បទគំរាមកំហែង

អំពើគំរាមកំហែងថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមប្រឆាំងនឹងបុគ្គល កាលបើការគំរាមកំហែងនេះធ្វើឡើងម្តងហើយម្តងទៀត ឬ សម្តែងចេញតាមលិខិត រូបភាព ឬ វត្ថុអ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ២៣២.-** បទគំរាមកំហែងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ

ការគំរាមកំហែងក្រោមទម្រង់ណាក៏ដោយ ថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមប្រឆាំងនឹងបុគ្គល ប្រសិនបើការគំរាមកំហែងនេះត្រូវបានធ្វើឡើងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំនិងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ២៣៣.-** បទគំរាមកំហែងថានឹងសម្លាប់

ការគំរាមកំហែងថានឹងសម្លាប់ កាលបើការគំរាមកំហែងនេះធ្វើឡើងម្តងហើយ ម្តងទៀត ឬ សម្តែងចេញតាមលិខិត រូបភាព ឬ វត្ថុអ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ២៣៤.-** បទគំរាមកំហែងថានឹងសម្លាប់ ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ

ការគំរាមកំហែងថានឹងសម្លាប់ក្រោមទម្រង់ណាក៏ដោយ ប្រសិនបើការគំរាមកំហែងនេះ ត្រូវបានធ្វើឡើងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ២៣៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបាន

ROYAUME DU CAMBODGE
LE MINISTRE du PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង
រូបថតចម្លងត្រឹមត្រូវ
25/2010

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ៤

## ការបង្កឱ្យមានរបួសដោយអចេតនា

**មាត្រា ២៣៦.-** បទបង្កឱ្យមានរបួសដោយអចេតនា

បទល្មើសបង្កឱ្យមានរបួសដោយអចេតនា គឺជាអំពើដែលបណ្តាលឱ្យមានរបួសដល់អ្នកដទៃដោយ :

១-ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬ ការខ្ជីខ្ជាដែលបង្កឱ្យមានអសមត្ថភាពក្នុងការធ្វើការងារស្មើ ឬ លើសពី ៨ (ប្រាំបី) ថ្ងៃ ។

២-ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬ កាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ ។

បទបង្កឱ្យមានរបួសដោយអចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ២៣៧.–** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការបើកបរយានយន្ត ទោះបីជាប្រភេទណាក៏ដោយ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

៣-ការព្យួរលិខិតបើកបរ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ២៣៨.–** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២៣៦ (បទបង្កឱ្យមានរបួសដោយអចេតនា) នៃក្រមនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ [illegible]០.០០០ (ម្ភៃលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចតទៅនេះ :

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ ។

២-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬ ច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយមាត្រា ១៧៧ (ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) នៃក្រមនេះ ។

៦-ការបិទផ្សាយសេចក្ដីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្ដីសម្រេច) នៃក្រមនេះ ។

៧-ការផ្សាយសេចក្ដីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្ដីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ជំពូកទី ៣
## ការបំពានខាងផ្លូវភេទ
### ផ្នែកទី ១
### ការរំលោភសេពសន្ថវៈ

**មាត្រា ២៣៩.-** បទរំលោភសេពសន្ថវៈ

គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬ អំពើបញ្ចូលឧបករណ៍ណាមួយ ទៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬ មិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬ ដោយការឆក់ឱកាស គឺជាបទរំលោភសេពសន្ថវៈ ។



បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់)

នីតិភាពនៃការរួមភេទត្រូវបានកំណត់ចាប់ពីអាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ ។

**មាត្រា ២៤០.–** ស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬទាក់ទងនឹងជនល្មើស

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបទល្មើសនេះប្រព្រឹត្តឡើង ៖

១-ដោយការប្រើអាវុធ ឬ គំរាមកំហែងនឹងអាវុធ ។

២-ដោយការប្រើគ្រឿងញៀន ឬ គ្រប់វិធីដែលនាំឱ្យជនរងគ្រោះបាត់បង់ ឬ ចុះខ្សោយលទ្ធភាពទប់ទល់ ។

៣-ដោយបុគ្គលដែលមានអំណាចទៅលើជនរងគ្រោះ ។

៤-ដោយបុគ្គលដែលរំលោភអំណាចដែលមុខងាររបស់ខ្លួនបានប្រគល់ឱ្យ ។

៥-ដោយបុគ្គលច្រើនរូប ដែលប្រព្រឹត្តឡើងក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬ ជាអ្នកសមគំនិត ។

**មាត្រា ២៤១.–** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះប្រព្រឹត្តទៅលើ ៖

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬ ពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

**មាត្រា ២៤២.–** ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬ ពិការភាព

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើបទល្មើសនេះនាំឱ្យមានការកាត់អវយវៈ ឬ ពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ។

**មាត្រា ២៤៣.–** ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬ អំពើឃោរឃៅ

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ៣០(សាមសិប) ឆ្នាំ កាលបើបទល្មើសនេះប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬ ក្រោយពេលប្រព្រឹត្តអំពើ

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

ទារុណកម្ម ឬ អំពើឃោរឃៅ ។

**មាត្រា ២៥៤.-** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើបទល្មើសនេះបណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់ ។

**មាត្រា ២៥៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ជនទណ្ឌិតបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយនូវគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២
## ការបំពានខាងផ្លូវភេទដទៃទៀត

**មាត្រា ២៤៦.-** បទប្រទូស្តកេរខ្មាស

គ្រប់អំពើប៉ះពាល់ ស្ទាប អង្អែលកេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃ តែបុគ្គលនេះមិនស្ម័គ្រចិត្តទេ ឬ បង្ខំបុគ្គលដទៃឱ្យប្រព្រឹត្តអំពើនេះមកលើខ្លួន ឬ ទៅលើតតិយបុគ្គលក្នុងគោលបំណងធ្វើឱ្យរំជួល ឬ រីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស គឺជាអំពើប្រទូស្តកេរខ្មាស ។

អំពើប្រទូស្តកេរខ្មាសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ២៤៧.-** ស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬ ទាក់ទងនឹងចារី

បទល្មើសដែលមានចែងក្នុងមាត្រា ២៤៦ (បទប្រទូស្តកេរខ្មាស) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើនេះ ប្រព្រឹត្តឡើង ៖

១-ដោយការប្រើអាវុធ ឬ ការគំរាមកំហែងនឹងអាវុធ ។

២-ដោយការប្រើគ្រឿងញៀន ឬ គ្រប់វិធីដែលនាំឱ្យជនរងគ្រោះបាត់បង់ ឬ ចុះខ្សោយលទ្ធភាពតទល់ ។

៣-ដោយបុគ្គលដែលមានអំណាចទៅលើជនរងគ្រោះ ។

៤-ដោយបុគ្គលដែលរំលោភអំណាច ដែលមុខងាររបស់ខ្លួនបានប្រគល់ឱ្យ ។

៥-ដោយបុគ្គលច្រើនរូប ដែលប្រព្រឹត្តឡើងក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬ ជាអ្នកសមគំនិត ។

**មាត្រា ២៤៨.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

បទល្មើសដែលមានចែងក្នុងមាត្រា ២៤៦ (បទប្រទូស្តកេរខ្មាស) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើនេះប្រព្រឹត្តទៅលើ ៖

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬ ពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

**មាត្រា ២៤៩.-** បទបង្ហាញកេរភេទ

អំពើបង្ហាញកេរភេទដែលនាំឱ្យអ្នកដទៃមើលឃើញ នៅក្នុងទីកន្លែងមួយដែលសាធារណជនអាចមើលឃើញ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

**មាត្រា ២៥០.-** បទរុកកួនខាងផ្លូវភេទ

អំពើរុកកួនខាងផ្លូវភេទ គឺជាអំពើដែលបុគ្គលម្នាក់រំលោភអំណាចដែលមុខងាររបស់ខ្លួនប្រគល់ឱ្យធ្វើការគាបសង្កត់ម្តងហើយម្តងទៀតទៅលើអ្នកដទៃ ក្នុងគោលបំណងទទួលការអនុគ្រោះខាងផ្លូវភេទ ។

អំពើរុកកួនខាងផ្លូវភេទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

**មាត្រា ២៥១.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ២៥២.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាង

ROYAUME DU CAMBODGE
SECRETARIAT DU PALAIS ROYAL
82/264 K



Kol

ច្រើន ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៤

## ការប៉ះពាល់ដល់សេរីភាព

### ផ្នែកទី ១

### ការចាប់ ការឃុំឃាំង និងការបង្ខាំងដោយខុសច្បាប់

**មាត្រា ២៥៣.–** បទចាប់ ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់

បុគ្គលដែលចាប់ ដែលឃុំឃាំង ឬ ដែលបង្ខាំងបុគ្គលផ្សេងទៀត ដោយគ្មានបញ្ជាពីអាជ្ញាធរស្របច្បាប់ ឬ ក្រៅពីករណីដែលច្បាប់អនុញ្ញាត ត្រូវផ្តន្ទាទោស ៖

១-ដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ បើការចាប់ ការឃុំឃាំង ឬ ការបង្ខាំងខ្លួនមានរយៈពេលតិចជាង ៤៨ (សែសិបប្រាំបី) ម៉ោង ។

២-ដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ បើការចាប់ ការឃុំឃាំង ឬ ការបង្ខាំងខ្លួនមានរយៈពេលចាប់ពី ៤៨ (សែសិបប្រាំបី) ម៉ោង ដល់តិចជាង ១ (មួយ) ខែ ។

៣-ដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ បើការចាប់ ការឃុំឃាំង ឬការបង្ខាំងខ្លួនមានរយៈពេលស្មើ ឬលើសពី ១ (មួយ) ខែ ។

**មាត្រា ២៥៤.–** ស្ថានទម្ងន់ទោស

បុគ្គលដែលចាប់ ដែលឃុំឃាំង ឬ ដែលបង្ខាំងបុគ្គលផ្សេងទៀត ដោយគ្មានបញ្ជាពីអាជ្ញាធរស្របច្បាប់ ឬ ក្រៅពីករណីដែលច្បាប់អនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥

ROYAUME DU CAMBODGE ... PALAIS ROYAL
83/2014

(ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ក្នុងករណីដូចខាងក្រោម :

១-ដោយមានទារុណកម្ម ឬ អំពើឃោរឃៅ ។

២-បណ្តាលឱ្យមានមនុស្សស្លាប់ដោយគ្មានបំណងនឹងធ្វើឱ្យស្លាប់ ។

៣-ប្រព្រឹត្តក្នុងគោលដៅជំរិតយកទ្រព្យសម្បត្តិ ឬ ទាមទារឱ្យបំពេញលក្ខខណ្ឌអ្វីមួយ ។

**មាត្រា ២៥៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការហាមឃាត់ជនបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍

សោតទស្សន៍ សម្រាប់រយៈពេល ៥ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២

## ការប៉ះពាល់ដល់សេរីភាពដំណើរ

**មាត្រា ២៥៦.–** បទផ្តើមកាន់កាប់មធ្យោបាយដឹកជញ្ជូន

អំពើផ្តើមយក ឬ ត្រួតត្រាលើមធ្យោបាយដឹកជញ្ជូនដែលមានបុគ្គលច្រើនរូបជិះក្នុងនោះ ដោយហិង្សា ឬ ដោយការគំរាមកំហែងថានឹងប្រើហិង្សា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ២៥៧.–** ស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវៈ ឬ ពិការភាព

បទល្មើសដែលមានចែងក្នុងមាត្រា ២៥៦ (បទផ្តើមកាន់កាប់មធ្យោបាយដឹកជញ្ជូន) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ប្រសិនបើបទល្មើសនោះនាំឱ្យមានការកាត់អវយវៈ ឬ ឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ។

**មាត្រា ២៥៨.–** ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬ អំពើឃោរឃៅ

បទល្មើសដែលមានចែងក្នុងមាត្រា ២៥៦ (បទផ្តើមកាន់កាប់មធ្យោបាយដឹកជញ្ជូន) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើមានធ្វើទារុណកម្ម ឬ អំពើឃោរឃៅ នៅមុនពេល ក្នុងពេល ឬ ក្រោយពេលប្រព្រឹត្តបទល្មើស ។

**មាត្រា ២៥៩.–** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

បទល្មើសដែលមានចែងក្នុងមាត្រា ២៥៦ (បទផ្តើមកាន់កាប់មធ្យោបាយដឹកជញ្ជូន) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើបទល្មើសនេះបណ្តាលឱ្យមនុស្សស្លាប់ម្នាក់ ឬ ច្រើននាក់ ។

**មាត្រា ២៦០.–** ទោសបន្ថែម: ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបាន

១-ការដកសិទ្ធិខ្លះជាពលរដ្ឋជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅសម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុដទៃទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៥

## ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ

### ផ្នែកទី ១

### ការប៉ះពាល់ដល់ការគោរពដែលត្រូវធ្វើឱ្យមានចំពោះអ្នកស្លាប់

**មាត្រា ២៦១.-** បទប៉ះពាល់ដល់បូរណភាពនៃសាកសព

អំពើប៉ះពាល់ដល់បូរណភាពនៃសាកសព ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ២៦២.–** បទប្រមាថទីបញ្ចុះសព

អំពើប្រមាថតាមមធ្យោបាយណាមួយក៏ដោយ ទៅលើផ្នូរ ទីបញ្ចុះសព កោដ្ឋ ឬទៅលើសំណង់ដែលកសាងឡើង សម្រាប់រំលឹកវិញ្ញាណក្ខន្ធនៃអ្នកទទួលមរណភាព ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ២៦៣.–** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ២៦៤.–** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២
## ការរើសអើង

**មាត្រា ២៦៥.–** បទបដិសេធក្នុងការផ្តល់ទ្រព្យសម្បត្តិ ឬ សេវា

អំពើដែលមិនព្រមផ្តល់ទ្រព្យសម្បត្តិ ឬ សេវាដល់បុគ្គលណាម្នាក់ ត្រូវផ្តន្ទាទោសដាក់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ២៦៧.-** បទបដិសេធក្នុងការជួលបុគ្គលឱ្យធ្វើការ

ការមិនព្រមជួលបុគ្គលណាម្នាក់ឱ្យធ្វើការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១(មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល កាលបើការមិនព្រមជួលនេះផ្អែកលើមូលហេតុណាមួយដូចមានចែងនៅចំណុចទី ១ ដល់ចំណុចទី ៨ នៃមាត្រា ២៦៥(បទបដិសេធក្នុងការផ្តល់ទ្រព្យសម្បត្តិ ឬ សេវា) នៃក្រមនេះ ។

**មាត្រា ២៦៨.-** បទជួលបុគ្គលឱ្យធ្វើការដោយមានលក្ខខណ្ឌ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើដែលដាក់ការផ្តល់ការងារឱ្យស្ថិតនៅក្រោមលក្ខខណ្ឌណាមួយដូចមានចែងនៅចំណុចទី ១ ដល់ចំណុចទី ៨ នៃមាត្រា ២៦៦(បទផ្តល់ទ្រព្យសម្បត្តិ ឬ សេវាដោយមានលក្ខខណ្ឌ) នៃក្រមនេះ ។

**មាត្រា ២៦៩.-** បទបណ្តេញចេញ ឬ ដកហូតដោយមូលហេតុនៃការរើសអើង

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០(មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើបណ្តេញចេញ ឬ ដកហូតបុគ្គលណាម្នាក់ ដោយផ្អែកលើមូលហេតុណាមួយ ដូចមានចែងនៅចំណុចទី ១ ដល់ចំណុចទី ៨ នៃមាត្រា ២៦៥(បទបដិសេធក្នុងការផ្តល់ទ្រព្យសម្បត្តិ ឬ សេវា) នៃក្រមនេះ ។

**មាត្រា ២៧០.-** បទបដិសេធក្នុងការផ្តល់សិទ្ធិដោយអ្នករាជការសាធារណៈដោយមូលហេតុនៃការរើសអើង

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល អំពើដែលប្រព្រឹត្តដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន ឬ ក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ដោយបដិសេធចំពោះបុគ្គលណាម្នាក់នូវការទទួលសិទ្ធិណាមួយ កាលបើការបដិសេធនោះផ្អែកលើមូលហេតុណាមួយ ដូចមានចែងនៅចំណុចទី ១ ដល់ចំណុចទី ៨ នៃមាត្រា ២៦៥(បទបដិសេធក្នុងការផ្តល់ទ្រព្យសម្បត្តិ ឬ សេវា) នៃក្រមនេះ ។

ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល កាលបើការមិនព្រមនេះ ផ្អែកលើមូលហេតុណាមួយដូចតទៅ :

១-ការដែលបុគ្គលនោះជាសមាជិក ឬ មិនមែនជាសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ឬ ពូជសាសន៍ណាមួយជាកំណត់ ។

២-ការដែលបុគ្គលនោះជាសមាជិក ឬ មិនមែនជាសមាជិកនៃសាសនាណាមួយជាកំណត់ ។

៣-និន្នាការនយោបាយរបស់បុគ្គល ។

៤-សកម្មភាពសហជីពរបស់បុគ្គល ។

៥-ស្ថានភាពគ្រួសាររបស់បុគ្គល ។

៦-ភេទរបស់បុគ្គល ។

៧-ស្ថានភាពសុខភាពបុគ្គល ។

៨-ពិការភាពរបស់បុគ្គល ។

**មាត្រា ២៦៦.-** បទផ្តល់ទ្រព្យសម្បត្តិ ឬ សេវាដោយមានលក្ខខណ្ឌ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើដែលផ្តល់ទ្រព្យសម្បត្តិ ឬ សេវាឱ្យដល់បុគ្គលណាម្នាក់ ដោយមានលក្ខខណ្ឌណាមួយដូចតទៅ :

១-ការដែលបុគ្គលនោះជាសមាជិក ឬ មិនមែនជាសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ឬ ពូជសាសន៍ណាមួយជាកំណត់ ។

២-ការដែលបុគ្គលនោះជាសមាជិក ឬ មិនមែនជាសមាជិកនៃសាសនាណាមួយជាកំណត់ ។

៣-និន្នាការនយោបាយរបស់បុគ្គល ។

៤-សកម្មភាពសហជីពរបស់បុគ្គល ។

៥-ស្ថានភាពគ្រួសាររបស់បុគ្គល ។

៦-ភេទរបស់បុគ្គល ។

៧-ស្ថានភាពសុខភាពបុគ្គល ។

៨-ពិការភាពរបស់បុគ្គល ។

**មាត្រា ២៧១.-** ការរើសអើងដែលអនុញ្ញាតដោយច្បាប់

បទល្មើសដែលកំណត់នៅក្នុងផ្នែកនេះ មិនមានធាតុផ្សំគ្រប់គ្រាន់ទេ ក្នុងករណីដែលការរើសអើងត្រូវបានអនុញ្ញាតដោយច្បាប់ ។

បទប្បញ្ញត្តិផ្នែកនេះ មិនអនុវត្តចំពោះករណីដូចខាងក្រោម :

១-ការរើសអើងដែលមានមូលដ្ឋានលើស្ថានភាពសុខភាព កាលបើការរើសអើងនេះមានគោលដៅបង្ការភយន្តរាយដល់បូរណភាពបុគ្គល សមត្ថភាពការងារ ឬ ពិការភាព ។

២-ការរើសអើងដែលមានមូលដ្ឋានលើស្ថានភាពសុខភាព ឬពិការភាព កាលបើការរើសអើងនេះ ជាការបដិសេធមិនផ្តល់ឱ្យធ្វើការងារ ការបណ្តេញចេញពីការងារ ដោយមូលហេតុអសមត្ថភាពបញ្ជាក់តាមផ្លូវវេជ្ជសាស្ត្រ ។

៣-ក្នុងរឿងផ្តល់ឱ្យធ្វើការងារ ការរើសអើងដែលមានមូលដ្ឋានលើភេទ កាលបើលក្ខខណ្ឌខាងភេទ ជាលក្ខខណ្ឌចាំបាច់ដើម្បីធ្វើការងារ ឬ សកម្មភាពវិជ្ជាជីវៈអ្វីមួយ ។

**មាត្រា ២៧២.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ២៧៣.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទ

ល្មើសដែលបញ្ញត្តក្នុងមាត្រា ២៦៥ (បទបដិសេធក្នុងការផ្តល់ទ្រព្យសម្បត្តិ ឬ សេវា) និង មាត្រា ២៦៩ (បទបណ្តេញចេញ ឬ ដកហូតដោយមូលហេតុនៃការរើសអើង) នៃក្រមនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចតទៅនេះ :

១-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃក្រមនេះ ។

២-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬ ច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៣-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ផ្នែកទី ៣

## លក្ខខណ្ឌការងារប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស

**មាត្រា ២៧៤.-** បទដាក់ឱ្យស្ថិតនៅក្នុងលក្ខខណ្ឌនៃការងារប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស

អំពើដែលដាក់បុគ្គលណាម្នាក់ ដោយរំលោភលើភាពទន់ខ្សោយ ឬ លើស្ថានភាពនៃអនិស្សរភាពរបស់បុគ្គលនោះ ឱ្យស្ថិតនៅក្នុងលក្ខខណ្ឌនៃការងារដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និង ពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ២៧៥.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងមាត្រា ២៧៤ (បទដាក់ឱ្យស្ថិតនៅក្នុងលក្ខខណ្ឌនៃការងារប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) នៃក្រមនេះ ត្រូវផ្តន្ទាទោសដូច

គ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ២៧៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ២៧៧.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២៧៤ (បទដាក់ឱ្យស្ថិតនៅក្នុងលក្ខខណ្ឌនៃការងារប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស) នៃក្រមនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចតទៅនេះ :

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ ។

២-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២(ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា ១៧៣(ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤(ការហាមឃាត់ចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) នៃក្រមនេះ ។

៦-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមនេះ ។

៧-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយមាត្រា ១៧៧(ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) នៃក្រមនេះ ។

៨-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨(ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និង មាត្រា ១៧៩(ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៩-ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨(ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩(ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

១០-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨(ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩(ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

១១-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០(ការបិទផ្សាយសេចក្ដីសម្រេច) នៃក្រមនេះ ។

១២-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

១៨១ (ការក្ស័យសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ផ្នែកទី ៤
## អំពើពុករលួយនៃនិយោជិត និងអភិបាល ជាអាទិ៍

**មាត្រា ២៧៨.-** បទស៊ីសំណូកនៃនិយោជិត

អំពើប្រព្រឹត្តដោយនិយោជិតដែលសុំ ឬ យល់ព្រមទទួលអំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍ណាមួយ ដើម្បីបំពេញ ឬ មិនបំពេញកិច្ចណាមួយនៃមុខងាររបស់ខ្លួនដោយនិយោជកមិនបានដឹង និងគ្មានការព្រមព្រៀងពីនិយោជកទេនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ២៧៩.-** បទសូកប៉ាន់ដល់និយោជិត

បុគ្គលដែលប្រគល់ឱ្យនិយោជិតនូវអំណោយ ឬ ជូនជំនូន ធ្វើការសន្យាជាមួយ ឬយល់ព្រមឱ្យអត្ថប្រយោជន៍អ្វីមួយដល់និយោជិត ដើម្បីឱ្យបំពេញ ឬ មិនបំពេញកិច្ចអ្វីមួយនៃមុខងាររបស់ខ្លួនដោយនិយោជកមិនបានដឹង និងគ្មានការព្រមព្រៀងពីនិយោជកទេនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ២៨០.-** បទស៊ីសំណូករបស់អភិបាល ជាអាទិ៍

១-បើបុគ្គលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ នៃមាត្រា ៣៩៣ (បទរំលោភលើទំនុកចិត្តពិសេស ដោយអភិបាល ឬ បុគ្គលផ្សេងទៀត) នៃក្រមនេះ ឬអធិការបានទទួលផលប្រយោជន៍ជាទ្រព្យសម្បត្តិ ឬ បានទាមទារ ឬ បានសន្យាទទួលផលប្រយោជន៍នោះដោយបានទទួលការពឹងពាក់ខុសច្បាប់ បុគ្គលនោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

២-បទប្បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះបុគ្គលដែលបានផ្តល់ផលប្រយោជន៍ដូចបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើ នោះ ឬបានផ្តល់ ឬសន្យាផ្តល់ផលប្រយោជន៍នោះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
94/2011



kl

៣- ផលប្រយោជន៍ជាទ្រព្យសម្បត្តិដូចបានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវដកហូត ។ បើមិនអាចដកហូតទាំងមូល ឬ ផ្នែកខ្លះនៃផលប្រយោជន៍នោះ ភាគដែលមិនអាចដកហូតយកបានត្រូវទារយកជាប្រាក់។

**មាត្រា ២៨១.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងនៅក្នុងមាត្រា ២៧៨(បទស៊ីសំណូកនៃនិយោជិត) និងមាត្រា ២៧៩(បទសូកប៉ាន់ចំពោះនិយោជិត) នៃក្រមនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ២៨២.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ២៨៣.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ២៧៩ (បទសូកប៉ាន់ចំពោះនិយោជិត) នៃក្រមនេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចតទៅនេះ :

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០(ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ ។

២-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬ ច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២(ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា ១៧៣(ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤(ការហាមឃាត់ចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) នៃក្រមនេះ ។

៦-ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨(ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩(ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ។

៧-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ផ្នែកទី ៥

## សញ្ញារកម្ម

**មាត្រា ២៨៤.-** បទសញ្ញារកម្ម

សញ្ញារកម្ម គឺជាអំពើ :

១-ទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់អ្នកដទៃ ។

២-ជួយ ឬ ការពារអំពើពេស្យាចាររបស់អ្នកដទៃ ឬ រៀបចំតាមគ្រប់មធ្យោបាយនូវសកម្មភាពពេស្យាចារ ។

៣-ជ្រើសរើស ពង្រត់ ឬ អូសទាញបុគ្គលណាមួយឱ្យធ្វើអំពើពេស្យាចារ ។

៤-ធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីឱ្យបុគ្គលនោះធ្វើពេស្យាចារ ។

សញ្ចារកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ២៨៥.–** បទអន្តរការរវាងបុរស ឬស្ត្រីពេស្យា និងសញ្ចារិក ឬសញ្ចារិកា

អំពើធ្វើជាអន្តរការី រវាងបុរស ឬ ស្ត្រីពេស្យា និងសញ្ចារិក ឬ សញ្ចារិកា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ២៨៦.–** ធនធានដែលបានមកពីសញ្ចារកម្ម

អំពើរបស់ជនណាដែលបានជួយសម្រួល ឬបិទបាំងនូវធនធានដែលខ្លួនបានដឹងថាបានមកពីអំពើសញ្ចារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដូចគ្នាផងដែរ ចំពោះបុគ្គលដែលមិនអាចបញ្ជាក់អំពីប្រភពធនធានរបស់ខ្លួន ដោយរស់នៅជាមួយជនដែលធ្វើសកម្មភាពពេស្យាចារជាប្រចាំ ឬ ដោយសារមានទំនាក់ទំនងជាទម្លាប់ជាមួយជនម្នាក់ ឬ ច្រើននាក់ដែលធ្វើសកម្មភាពពេស្យាចារ ។

**មាត្រា ២៨៧.–** បទរារាំងដល់ការបង្ការអំពើពេស្យាចារ

អំពើរារាំងដល់ការបង្ការ ការជួយ ឬ ការអប់រំជាថ្មី ដោយសេវាសាធារណៈ ឬ ដោយអង្គការឯកជនដែលមាននីតិសម្បទា ដែលធ្វើឡើងដើម្បីអនុគ្រោះដល់បុគ្គលដែលប្រព្រឹត្តពេស្យាចារ ឬ កំពុងមានគ្រោះថ្នាក់ដោយការធ្វើពេស្យាចារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ២៨៨.–** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

សញ្ញារកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ក្នុងករណីដូចខាងក្រោមនេះ :

១-កាលបើសញ្ញារិក សញ្ញារិកា ឬ ជនជាមេពេស្យាជាបុព្វញាតិ ឬ បច្ឆាញាតិរបស់បុគ្គលដែលធ្វើពេស្យាចារ ។

២-កាលបើសញ្ញារិក សញ្ញារិកា ឬ ជនជាមេពេស្យារំលោភអំណាចដែលមុខងាររបស់ខ្លួនផ្តល់ឱ្យទៅលើបុគ្គលដែលធ្វើពេស្យាចារ ។

៣-កាលបើសញ្ញារិក សញ្ញារិកា ឬ ជនជាមេពេស្យាប្រើហិង្សា ឬ ការបង្ខិតបង្ខំចំពោះបុគ្គលដែលធ្វើពេស្យាចារ ។

៤-កាលបើសញ្ញារកម្មត្រូវបានប្រព្រឹត្តជាក្រុមមានការចាត់តាំង ។

៥-កាលបើសញ្ញារកម្មត្រូវបានប្រព្រឹត្តលើបុគ្គលច្រើននាក់ធ្វើពេស្យាចារ ។

**មាត្រា ២៨៩.–** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

សញ្ញារកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបុគ្គលដែលធ្វើពេស្យាចារនោះជាអនីតិជន ។

**មាត្រា ២៩០.–** ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬ អំពើឃោរឃៅ

សញ្ញារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើសញ្ញារិក សញ្ញារិកា ឬ ជនជាមេពេស្យាបានប្រើប្រាស់ទារុណកម្ម ឬ អំពើឃោរឃៅចំពោះបុគ្គលដែលធ្វើពេស្យាចារ ។

**មាត្រា ២៩១.–** បទដឹកនាំគ្រប់គ្រងគ្រឹះស្ថានសម្រាប់ធ្វើពេស្យាចារ

អំពើគ្រប់គ្រង ធ្វើអាជីវកម្ម ដឹកនាំ ធ្វើឱ្យដំណើរការ ឬ ចេញប្រាក់ឱ្យគ្រឹះស្ថានពេស្យាចារដោយផ្ទាល់ ឬ តាមរយៈអន្តរការី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ២៩២.–** បទយល់ព្រមឱ្យធ្វើសកម្មភាពពេស្យាចារនៅក្នុងគ្រឹះស្ថាន

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី

ROYAUME DU CAMBODGE LE MINISTERE DU PALAIS ROYAL ព្រះបរមរាជវាំង



kol

៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល គំពើរបស់អ្នកដែលគ្រប់គ្រង ធ្វើអាជីវកម្ម ដឹកនាំ ឬ ធ្វើឱ្យដំណើរការនូវគ្រឹះស្ថានណាមួយដែលបើកចំហដល់សាធារណជន ដោយផ្ទាល់ ឬ តាមរយៈអន្តរការី បានយល់ព្រម ឬ បានអនុគ្រោះ :

១-ឱ្យបុគ្គលណាម្នាក់ប្រព្រឹត្តជាប្រចាំនូវពេស្យាចារនៅក្នុងគ្រឹះស្ថាន ឬ នៅក្នុងឧបសម្ព័ន្ធរបស់គ្រឹះស្ថាន ។

២-ឱ្យបុគ្គលណាម្នាក់រកជាប្រចាំនូវភ្ញៀវ ដើម្បីធ្វើពេស្យាចារនៅក្នុងគ្រឹះស្ថាន ឬ នៅក្នុងឧបសម្ព័ន្ធរបស់គ្រឹះស្ថាន ។

**មាត្រា ២៩៣.-** បទដាក់ឱ្យប្រើប្រាស់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ចំពោះបុគ្គលដែលលក់ ឬ ដាក់ឱ្យបុគ្គលណាម្នាក់ប្រើប្រាស់ទីកន្លែងដែលមិនមែនប្រើប្រាស់ដោយសាធារណជន ដោយដឹងជាក់ច្បាស់ថា បុគ្គលនោះនឹងប្រើប្រាស់ទីកន្លែងនោះ សម្រាប់ធ្វើសកម្មភាពពេស្យាចារ ។

**មាត្រា ២៩៤.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងនៅក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ២៩៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការហាមឃាត់ដល់ជនបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៧-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៨-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបានប្រព្រឹត្តឡើង ។

៩-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

១០-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

១១-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់គ្រៀម ឬ ប្រព្រឹត្តបទល្មើស ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១២-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជនជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៣-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ២៩៦.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចតទៅនេះ :

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ ។

២-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬ ច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយមាត្រា ១៧៧ (ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) នៃក្រមនេះ ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និង មាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ។

៧-ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៨-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសតាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោល វត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

**ផ្នែកទី ៦**

**ការប៉ះពាល់ផ្សេងទៀតដល់សេចក្តីថ្លៃថ្នូរ**

**មាត្រា ២៩៧.-** បទស្រវឹងជាក់ស្តែង

បុគ្គលណាដែលស្ថិតនៅក្នុងសភាពស្រវឹងយ៉ាងជាក់ស្តែងនៅលើផ្លូវសាធារណៈ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀល ទៅ ១០.០០០ (មួយម៉ឺន) រៀល ។

**មាត្រា ២៩៨.-** បទហៅអ្នកដទៃនៅទីសាធារណៈ

បុគ្គលណាដែលហៅអ្នកដទៃនៅទីសាធារណៈ ដើម្បីញុាំងឱ្យមានទំនាក់ទំនងផ្លូវភេទ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀល ទៅ ៥០.០០០ (ប្រាំម៉ឺន) រៀល ។

**ជំពូកទី ៦**

**ការប៉ះពាល់ដល់បុគ្គលភាព**

**ផ្នែកទី ១**

**ការប៉ះពាល់ដល់ជីវភាពឯកជន**

**មាត្រា ២៩៩.-** បទរំលោភលើលំនៅឋាន

អំពើប្រព្រឹត្តដោយមានហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬឧបាយកលចូលទៅក្នុងលំនៅឋានអ្នកដទៃនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល លើកលែងតែករណីដែលច្បាប់អនុញ្ញាត ។

**មាត្រា ៣០០.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជាតិ

អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន ឬ ក្នុងឱកាសបំពេញមុខងាររបស់ខ្លួន ចូលទៅក្នុងលំនៅឋានរបស់អ្នកដទៃដោយគ្មានការយល់ព្រម



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ពីម្ចាស់ផ្ទះទេនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល លើកលែងតែករណីដែលច្បាប់អនុញ្ញាត ។

**មាត្រា ៣០១.-** បទស្តាប់ ឬថតពាក្យសំដីឯកជន

អំពើស្តាប់ ឬថតសំដីដែលនិយាយជាឯកជន ឬជាការសម្ងាត់ ដោយគ្មានការយល់ព្រមពីបុគ្គលដែលមានការពាក់ព័ន្ធនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល លើកលែងតែករណីដែលច្បាប់អនុញ្ញាត ។

ត្រូវបានសន្មតជាការព្រមព្រៀង ប្រសិនបើបុគ្គលដែលពាក់ព័ន្ធនេះបានទទួលដំណឹងអំពីការស្តាប់ ឬ ថតហើយ បុគ្គលនោះមិនបានជំទាស់ទេនោះ ។

**មាត្រា ៣០២.-** បទប៉ះពាល់ដល់សិទ្ធិខាងរូបភាពនៃបុគ្គល

អំពើថតរូបភាពនៃបុគ្គលនៅក្នុងទីកន្លែងឯកជន ដោយគ្មានការព្រមព្រៀងពីបុគ្គលនេះទេ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល លើកលែងតែករណីដែលច្បាប់អនុញ្ញាត ។

ត្រូវបានសន្មតជាការព្រមព្រៀង ប្រសិនបើបុគ្គលដែលពាក់ព័ន្ធនេះបានទទួលដំណឹងអំពីការថតហើយ បុគ្គលនេះមិនបានជំទាស់ទេនោះ ។

**មាត្រា ៣០៣.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៣០៤.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត

នៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២
## ការបរិហារកេរ្តិ៍ និងការជេរប្រមាថ

**មាត្រា ៣០៥.-** បទបរិហារកេរ្តិ៍ជាសាធារណៈ

គ្រប់ការអះអាងបំផ្លើស ឬ ការទំលាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយ ដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស ឬ កិត្តិស័ព្ទនៃបុគ្គល ឬ នៃស្ថាប័ន គឺជាការបរិហារកេរ្តិ៍ ។

ត្រូវពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល បទបរិហារកេរ្តិ៍ដែលប្រព្រឹត្តតាមមធ្យោបាយណាមួយ ដូចតទៅ :

១-តាមសំដី ទោះជាប្រភេទណាក៏ដោយដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងសាលប្រជុំសាធារណៈ ។

២-តាមលិខិត ឬគំនូរ ទោះជាប្រភេទណាក៏ដោយដែលផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬ ដាក់តាំងឱ្យសាធារណជនមើល ។

៣-តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន ។

**មាត្រា ៣០៦.-** អំពើបរិហារកេរ្តិ៍តាមសារព័ត៌មាន

ការបរិហារកេរ្តិ៍ដែលប្រព្រឹត្តតាមសារព័ត៌មាន ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសារព័ត៌មាន ។

**មាត្រា ៣០៧.-** បទជេរប្រមាថជាសាធារណៈ

គ្រប់ពាក្យប្រមាថ គ្រប់ពាក្យមើលងាយ ឬ គ្រប់ពាក្យទ្រគោះ ដែលគ្មានការទំលាក់កំហុសលើអំពើណាមួយ គឺជាការជេរប្រមាថ ។

ត្រូវពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល បទជេរប្រមាថដែលប្រព្រឹត្តឡើងតាមមធ្យោបាយណាមួយដូចតទៅ :

១-តាមពាក្យសំដី ទោះជាប្រភេទណាក៏ដោយដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងពេលប្រជុំសាធារណៈ ។

២-តាមលិខិត ឬ គំនូរ ទោះជាប្រភេទណាក៏ដោយ ដែលផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬ ដាក់តាំងឱ្យសាធារណជនមើល ។

៣-តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន ។

**មាត្រា ៣០៨.-** អំពើជេរប្រមាថតាមសារព័ត៌មាន

ការជេរប្រមាថដែលប្រព្រឹត្តតាមសារព័ត៌មាន ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសារព័ត៌មាន ។

**មាត្រា ៣០៩.-** នីតិវិធីបណ្តឹងចំពោះបទបរិហារកេរ្តិ៍ និងបទជេរប្រមាថ

ក្នុងករណីដែលមានការបរិហារកេរ្តិ៍ ឬ ការជេរប្រមាថ ចំពោះសមាជិករាជរដ្ឋាភិបាល មន្ត្រីរាជការសាធារណៈ ឬ ពលរដ្ឋដែលទទួលបន្ទុកបេសកកម្មសាធារណៈ ឬ អាណត្តិសាធារណៈ ការចោទប្រកាន់នឹងត្រូវធ្វើឡើងតាមបណ្តឹងរបស់សាមីខ្លួន ឬ បណ្តឹងរបស់ប្រធានស្ថាប័នសាមី ។

ក្នុងករណីដែលមានការបរិហារកេរ្តិ៍ ឬ ការជេរប្រមាថ ចំពោះបុគ្គលឯកជន ការចោទប្រកាន់នឹងត្រូវធ្វើឡើងតាមបណ្តឹងរបស់សាមីខ្លួនដែលទទួលរងនូវការបរិហារកេរ្តិ៍ ឬ ការជេរប្រមាថនោះ ។

ពាក្យប្តឹងរបស់សាមីខ្លួន ឬ ប្រធានស្ថាប័នសាមី ដែលមានចែងក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ គឺជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ដោយអយ្យការ ហើយការដកពាក្យប្តឹងវិញរបស់អ្នកប្តឹង នាំឱ្យបណ្តឹងអាជ្ញារលត់។

ក៏ប៉ុន្តែ ការចោទប្រកាន់អាចនឹងត្រូវធ្វើឡើងដោយស្វ័យប្រវត្តដោយព្រះរាជអាជ្ញា កាលបើការបរិហារកេរ្តិ៍ ឬ ជេរប្រមាថនោះ ត្រូវបានធ្វើឡើងប្រឆាំងនឹងបុគ្គលម្នាក់ ឬ បុគ្គលមួយក្រុម ដោយមូលហេតុដើមកំណើត ជាតិពន្ធុ ពូជសាសន៍ សញ្ជាតិ ឬ សាសនារបស់

បុគ្គលនោះ ។ ក្នុងករណីនេះ នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា ៣១០.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស ។

២-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

៣-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន។

## ផ្នែកទី ៣
## ការប្ដឹងបរិហារបង្កាច់កេរ្តិ៍

**មាត្រា ៣១១.-** បទប្ដឹងបរិហារបង្កាច់កេរ្តិ៍

ការប្ដឹងបរិហារបង្កាច់កេរ្តិ៍ គឺជាអំពើប្ដឹងបរិហារអំពីអំពើដែលគេដឹងថា មិនពិត ហើយដែលនាំឱ្យមានទណ្ឌកម្មព្រហ្មទណ្ឌ ឬវិន័យ កាលបើការប្ដឹងបរិហារនេះ ត្រូវបានធ្វើទៅដល់ :

-អាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់ការ ដូចជាចៅក្រម មន្ត្រីនគរបាលយុត្តិធម៌ ឬនិយោជក ឬ

-បុគ្គលដែលមានអំណាចប្ដឹងទៅអាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា ៣១២.-** ទោសដែលត្រូវអនុវត្ត និងលក្ខខណ្ឌនៃការចោទប្រកាន់

ការប្ដឹងបរិហារបង្កាច់កេរ្តិ៍ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១(មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

បណ្ដឹងអាជ្ញានៃបទល្មើសនេះ ផុតអាជ្ញាយុកាលក្នុងរយៈពេល ១ (មួយ) ឆ្នាំ ។ ចំណុចចាប់ផ្ដើមនៃអាជ្ញាយុកាលនេះ ត្រូវចាប់គិតពីថ្ងៃដែលបណ្ដឹងបរិហារបង្កាច់កេរ្តិ៍ ត្រូវបានទៅដល់ ឬថ្ងៃដែលពាក្យប្ដឹងបានដាក់មកអាជ្ញាធរមានសមត្ថកិច្ច ។

ក្នុងករណីដែលអំពើប៉ះពាល់បរិហារបង្កាច់កេរ្តិ៍នេះ នាំឱ្យមានការចោទប្រកាន់ខាងព្រហ្ម-ទណ្ឌ នីតិវិធីដែលផ្តើមអំពីបទប៉ះពាល់បរិហារបង្កាច់កេរ្តិ៍នោះ នាំឱ្យផ្អាកអាជ្ញាយុកាលរហូតដល់ពេលបញ្ចប់កិច្ចចោទប្រកាន់ ។

**មាត្រា ៣១៣.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

២-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ៤

## ការប៉ះពាល់ដល់អាថ៌កំបាំងខាងវិជ្ជាជីវៈ

**មាត្រា ៣១៤.-** បទប៉ះពាល់ដល់អាថ៌កំបាំងខាងវិជ្ជាជីវៈ

បុគ្គលដែលកាន់កាប់ព័ត៌មានដែលមានលក្ខណៈអាថ៌កំបាំង ដោយមូលហេតុនៃស្ថាន-ភាព មុខរបរ មុខងារ ឬ បេសកកម្មរបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ប្រសិនបើបុគ្គលនោះបង្ហាញព័ត៌មាននេះ ដល់បុគ្គលដែលគ្មានសមត្ថកិច្ចដើម្បីដឹងពីព័ត៌មាននេះ ។

មិនមែនជាបទល្មើសទេ ក្នុងករណីដែលច្បាប់អនុញ្ញាត ឬតម្រូវឱ្យបង្ហាញអាថ៌កំបាំង ។

**មាត្រា ៣១៥.-** បដិប្បញ្ញត្តិនឹងមាត្រា ៣១៤

មិនត្រូវបានចាត់ទុកថាជាបទល្មើសតាមមាត្រា ៣១៤(បទប៉ះពាល់ដល់អាថ៌កំបាំងខាងវិជ្ជាជីវៈ) នៃក្រមនេះទេ ប្រសិនបើបុគ្គលណាម្នាក់បានដឹងហេតុនេះ ក្នុងនិកាសប្រកប [illegible]របស់ខ្លួន ហើយបង្ហាញដល់អាជ្ញាធរតុលាការ រដ្ឋបាល ឬ វេជ្ជសាស្ត្រ អំពីការធ្វើ[illegible]អនីតិជនអាយុតិចជាង ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ៣១៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ៥
## ការប៉ះពាល់ដល់ការសម្ងាត់នៃការឆ្លងឆ្លើយតាមលិខិត និងទូរគមនាគមន៍

**មាត្រា ៣១៧.-** បទប៉ះពាល់ដល់ការឆ្លើយឆ្លងតាមលិខិត

អំពើបើក បំបាត់ចោល ធ្វើឱ្យយឺតយ៉ាវ ឬ បង្វែរលិខិតឆ្លើយឆ្លងដែលផ្ញើទៅតតិយជនដោយគំនិតទុច្ចរិត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

ត្រូវផ្តន្ទាទោសដូចគ្នា ចំពោះអំពើប្រព្រឹត្តដោយទុច្ចរិត មើលលិខិតឆ្លើយឆ្លងដែលផ្ញើទៅតតិយជន ។

**មាត្រា ៣១៨.-** បទប៉ះពាល់ដល់ការសម្ងាត់នៃការសន្ទនាតាមទូរស័ព្ទ

អំពើប្រព្រឹត្តដោយគំនិតទុច្ចរិត ស្តាប់ ឬ ធ្វើឱ្យប្រឡូកប្រឡល់ការសន្ទនាតាមទូរស័ព្ទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ខែ ទៅ ១(មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

ត្រូវផ្តន្ទាទោសដូចគ្នា ចំពោះអំពើប្រព្រឹត្តដោយទុច្ចរិត ចាប់ ធ្វើឱ្យប្រឡូកប្រឡល់ ឬ ស្តាប់សារដែលផ្សាយចេញតាមផ្លូវទូរគមនាគមន៍ ។

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

**មាត្រា ៣១៩.–** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៣២០.–** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុឯទៀត ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៣-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ទស្សនីសម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## មាតិកាទី ៣
## ការប៉ះពាល់ដល់អនីតិជន និងគ្រួសារ
### ជំពូកទី ១
### អំពើបោះបង់អនីតិជន

**មាត្រា ៣២១.–** បទបោះបង់អនីតិជន

អំពើរបស់បុគ្គលមានអំណាចថែរក្សា ដែលបោះបង់អនីតិជនអាយុតិចជាង ១៥ (ដប់ប្រាំ) ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ប្រសិនបើអំពើបោះបង់នោះបណ្តាលឱ្យអន្តរាយដល់សុខភាព ឬ សន្តិសុខរបស់អនីតិជននោះ។

**មាត្រា ៣២២.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៣២៣.-** ទោសបន្ថែម: ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស:

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## ការបោះបង់គ្រួសារ

**មាត្រា ៣២៤.-** បទបោះបង់គ្រួសារ

ការមិនគោរពតាមសេចក្តីសម្រេចស្ថាពររបស់តុលាការ ដោយមិនព្រមបង់ក្នុងរយៈពេល ២ (ពីរ) ខែ យ៉ាងតិច នូវអាហារកាតព្វកិច្ចដល់សហព័ទ្ធ ឬ អតីតសហព័ទ្ធរបស់ខ្លួន ដល់កូនជាអនីតិជន ដល់បច្ឆាញាតិ ឬ បុព្វញាតិ ឬ ដល់ញាតិផ្សេងទៀតរបស់ខ្លួននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៣២៥.-** ទោសបន្ថែម: ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបាន

ROYAUME DU CAMBODGE * LE MINISTÈRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង
0 /264

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៣
## ការប៉ះពាល់ដល់ការថែរក្សាអនីតិជន

**មាត្រា ៣២៦.-** បទមិនព្រមប្រគល់អនីតិជន

អំពើប្រព្រឹត្តដោយគំនិតទុច្ចរិត មិនព្រមប្រគល់អនីតិជនឱ្យទៅបុគ្គលដែលមានសិទ្ធិទាមទារនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៣២៧.-** បទដកយកអនីតិជន

អំពើដកយកអនីតិជនដោយផ្ទុយច្បាប់ ពីបុគ្គលដែលថែរក្សាស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

បទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន)រៀល ប្រសិនបើអនីតិជនត្រូវបានរក្សាទុកនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣២៨.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ។

**មាត្រា ៣២៩.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបាន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៤
## ការប៉ះពាល់ដល់បុត្តភាព

**មាត្រា ៣៣០.-** បទញុះញង់ឱ្យបោះបង់ទារក

អំពើនៅក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ដល់ឪពុកម្តាយ ឬ ដល់ឪពុក ឬ ម្តាយឱ្យបោះបង់ទារកដែលកើតមកហើយ ឬ ដែលនឹងកើត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៣៣១.-** បទអន្តរការរវាងអ្នកសុំកូន និងអ្នកបោះបង់កូន

អំពើប្រព្រឹត្តនៅក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងបុគ្គលម្នាក់ ឬប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹម និងឪពុកម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬ ដែលនឹងកើត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៣៣២.-** បទអន្តរការរវាងអ្នកសុំកូន និងស្ត្រីពពោះ

អំពើប្រព្រឹត្តនៅក្នុងគោលបំណងចង់បានកម្រៃ ធ្វើជាអន្តរការីរវាងបុគ្គលម្នាក់ ឬ ប្តីប្រពន្ធ ដែលចង់សុំកូនយកមកចិញ្ចឹម និងស្ត្រីម្នាក់យល់ព្រមពពោះ ដើម្បីនឹងប្រគល់កូននោះឱ្យទៅអ្នកសុំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៣៣៣.-** បទជំនួស ក្លែង ឬ លាក់បំបាំងអត្តភាពនៃទារក

អំពើដែលយកទារកមួយជំនួសទារកមួយទៀត ក្លែង ឬ លាក់បំបាំងអត្តភាពនៃទារក

កាលបើអំពើនេះនាំឱ្យមានការខ្វែងបន្ទំអគ្រានុក្កលដ្ឋាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀលទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៣៣៤.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងការប្រព្រឹត្តបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៣៣៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ៣៣៦.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៣៣០ (បទញុះញង់ឱ្យបោះបង់ទារក) មាត្រា ៣៣១ (បទអន្តរការរវាងអ្នកសុំកូន និងអ្នកបោះបង់កូន) និងមាត្រា ៣៣២ (បទអន្តរការរវាងអ្នកសុំកូន និងស្ត្រីពពោះ) នៃក្រមនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចតទៅនេះ :

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចតទៅនេះ :

១-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទដែលមានចែងក្នុងមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

២-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៣-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមនេះ ។

៤-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសតាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៥-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ជំពូកទី ៥
## ការដាក់អនីតិជនឱ្យស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់
### ផ្នែកទី ១
### ការប៉ះពាល់ដល់សុខភាព និងចិត្តសាស្ត្រ

**មាត្រា ៣៣៧.-** បទបង្អត់អាហារឬគ្មានការថែទាំអនីតិជនអាយុតិចជាង ១៥ ឆ្នាំ

អំពើរបស់ជនគ្រប់រូប ដែលមានអំណាចទៅលើអនីតិជនអាយុតិចជាង ១៥ (ដប់ប្រាំ) ឆ្នាំ ដែលបង្អត់អាហារ ឬគ្មានការថែទាំរហូតដល់ខូចសុខភាពអនីតិជននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៣៣៨.-** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

បទល្មើសដែលមានចែងក្នុងមាត្រា ៣៣៧ (បទបង្អត់អាហារ ឬគ្មានការថែទាំអនីតិជនអាយុតិចជាង ១៥ ឆ្នាំ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ

ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបទល្មើសនេះនាំឱ្យជនរងគ្រោះស្លាប់ ។

**មាត្រា ៣៣៩.-** បទដាក់អនីតិជនឱ្យស្ថិតក្នុងលក្ខខណ្ឌនៃការងារដែលបណ្តាលឱ្យខូចសុខភាព

អំពើដែលដាក់អនីតិជនឱ្យស្ថិតនៅក្នុងលក្ខខណ្ឌនៃការងារ បណ្តាលឱ្យខូចដល់សុខភាព ឬការលូតលាស់ដល់រាងកាយរបស់អនីតិជននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០(បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៣៤០.-** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃអនីតិជន

បទល្មើសដែលមានចែងនៅក្នុងមាត្រា ៣៣៩ (បទដាក់អនីតិជនឱ្យស្ថិតនៅក្នុងលក្ខ-ខណ្ឌការងារដែលបណ្តាលឱ្យខូចសុខភាព) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបទល្មើសនោះនាំឱ្យជនរងគ្រោះស្លាប់ ។

**មាត្រា ៣៤១.-** បទអាសប្រព្រឹត្តទៅលើអនីតិជនអាយុតិចជាង ១៥ ឆ្នាំ

អំពើអាស គឺជាអំពើនៃការប៉ះពាល់ ឬ ការបង្ហាញកេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់ជនដទៃ ឬ ការឱ្យជនដទៃប៉ះពាល់កេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់ជនល្មើសខ្លួនឯង ឬ របស់តតិយជន ក្នុងគោលបំណងធ្វើឱ្យរំជួល ឬរីករាយ ដល់ចំណង់ផ្លូវភេទរបស់ជនល្មើស ។

ជនណាដែលប្រព្រឹត្តអំពើអាសទៅលើអនីតិជនអាយុតិចជាង ១៥ (ដប់ប្រាំ) ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៣៤២.-** ស្ថានទម្ងន់ទោស

បទល្មើសដែលមានចែងក្នុងមាត្រា ៣៤១(បទអាសប្រព្រឹត្តទៅលើអនីតិជនអាយុតិចជាង ១៥ ឆ្នាំ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើបទល្មើសនេះបានប្រព្រឹត្ត ៖

១-ដោយបុព្វញាតិ ។

២-ដោយបុគ្គលដែលមានអំណាចលើអនីតិជន ។

ROYAUME DU CAMBODGE · SECRETARIAT DU PALAIS ROYAL

៣-ដោយបុគ្គលច្រើនរូប ដែលធ្វើសកម្មភាពក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬ ជាអ្នកសមគំនិត ។

៤-ដោយការបង់លាភការ ។

## ផ្នែកទី ២

## ការញុះញង់អនីតិជនឱ្យប្រព្រឹត្តអំពើខុសច្បាប់ ឬអំពើគ្រោះថ្នាក់

**មាត្រា ៣៤៣.–** បទញុះញង់អនីតិជនឱ្យបរិភោគគ្រឿងស្រវឹង

អំពើញុះញង់អនីតិជនដោយផ្ទាល់ឱ្យបរិភោគជាប្រចាំ និងយ៉ាងច្រើននូវគ្រឿងស្រវឹង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៣៤៤.–** បទញុះញង់អនីតិជនឱ្យសុំទាន

អំពើញុះញង់អនីតិជនដោយផ្ទាល់ឱ្យសុំទាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០(មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៣៤៥.–** បទញុះញង់អនីតិជនឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិម

អំពើញុះញង់អនីតិជនដោយផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៣៤៦.–** បទរៀបចំបង្ហាញភេទ ឬ ទំនាក់ទំនងខាងផ្លូវភេទដោយមានការចូលរួមរបស់អនីតិជន

អំពើរបស់នីតិជនដែលរៀបចំការជួបជុំ ដែលរួមមានការបង្ហាញភេទ ឬ មានទំនាក់ទំនងខាងផ្លូវភេទ ដោយមានអនីតិជនបានមើល ឬ ចូលរួមផងនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

## ផ្នែកទី ៣
## ការរំលោភអំណាចមេបា

**មាត្រា ៣៤៧.–** បទរំលោភអំណាចមេបា

អំពើរបស់អ្នកមានអំណាចមេបា ឬ អ្នកមានអំណាចអាណាព្យាបាល ដែលដកហូតសេរីភាពរបស់អនីតិជន ដោយរំលោភអំណាចរបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល កាលបើអំពើនេះធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សុខភាព សុវត្ថិភាព ផ្លូវចិត្ត ឬ ការអប់រំរបស់អនីតិជននោះ ។

## ផ្នែកទី ៤
## ការប៉ុនប៉ង និងទណ្ឌកម្ម

**មាត្រា ៣៤៨.–** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៣៤៩.–** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

ROYAUME du CAMBODGE MINISTRE du PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៦

## ការប៉ះពាល់ផ្សេងទៀតដល់គ្រួសារ

**មាត្រា ៣៥០.-** បទទ្វេពន្ធភាព

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើដែលចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មី មុនការរំលាយអាពាហ៍ពិពាហ៍ចាស់ ។

ត្រូវផ្តន្ទាទោសដូចគ្នា ចំពោះមន្ត្រីអត្រានុកូលដ្ឋានដែលដឹងហេតុការណ៍នោះច្បាស់ នៅតែអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ ឬ ចុះបញ្ជីអាពាហ៍ពិពាហ៍នេះ មុនការរំលាយអាពាហ៍ពិពាហ៍ចាស់ ។

**មាត្រា ៣៥១.-** បទរួមភេទជាមួយអនីតិជន ដោយបុព្វញាតិ

អំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើចារីជាបុព្វញាតិរបស់អនីតិជននោះ ។

**មាត្រា ៣៥២.-** បទរួមភេទរវាងញាតិលោហិត ឬ ញាតិពន្ធ

អំពើរួមភេទរវាងញាតិលោហិត ឬ ញាតិពន្ធក្នុង ៣ (បី) ថ្នាក់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០(មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

មិនត្រូវចាត់ទុកជាបទល្មើសតាមកថាខណ្ឌទី ១ ខាងលើទេ ប្រសិនបើសហព័ទ្ធណាម្នាក់ស្លាប់ ហើយសហព័ទ្ធដែលនៅរស់រួមភេទជាមួយសាខាញាតិពន្ធ ថ្នាក់ទី ២ ឬ ថ្នាក់ទី ៣ ។

# គន្ថីទី ៣

# បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ

## មាតិកាទី ១

## ការយកទ្រព្យសម្បត្តិអ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយទុច្ចរិត

### ជំពូកទី ១

### ការលួច និងបទល្មើសប្រហាក់ប្រហែល

#### ផ្នែកទី ១

#### ការលួច

**មាត្រា ៣៥៣.-** និយមន័យនៃអំពើលួច

អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬ វត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។

**មាត្រា ៣៥៤.-** អំពើលួចថាមពល

ត្រូវចាត់ទុកជាអំពើលួច អំពើប្រើប្រាស់ដោយទុច្ចរិតនូវថាមពល ដែលនាំឱ្យខូចប្រយោជន៍អ្នកដទៃ ។

**មាត្រា ៣៥៥.-** អភ័យឯកសិទ្ធិគ្រួសារ

មិនអាចត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបានទេ :

១-អំពើលួចទ្រព្យសម្បត្តិរបស់បុព្វញាតិ ឬបច្ឆាញាតិ ។

២-អំពើលួចទ្រព្យសម្បត្តិរបស់សហព័ទ្ធ ។

**មាត្រា ៣៥៦.-** ទោសដែលត្រូវអនុវត្ត

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៣៥៧.-** ស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ក្នុងករណី

១-អំពើលួចនេះ ប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬ ក្រោយពេលប្រើហិង្សា ។

២-អំពើលួចនេះ ប្រព្រឹត្តដោយការកាប់គាស់ទម្លុះទម្លាយ ។

**មាត្រា ៣៥៨.-** ស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវៈ ឬ ពិការភាព

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុនពេល ក្នុងពេល ឬ ក្រោយពេលប្រើហិង្សាដែលនាំឱ្យមានការកាត់អវយវៈ ឬ ពិការភាពជាអចិន្ត្រៃយ៍ ។

**មាត្រា ៣៥៩.-** ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬ អំពើឃោរឃៅ

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុនពេល ក្នុងពេល ឬ ក្រោយពេលប្រើទារុណកម្ម ឬ អំពើឃោរឃៅ ។

**មាត្រា ៣៦០.-** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

អំពើលួចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុនពេល ក្នុងពេល ឬ ក្រោយពេលប្រើហិង្សា ដែលបណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់ ។

**មាត្រា ៣៦១.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៣៦២.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែម ដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៥-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

៨-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៩-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបានប្រព្រឹត្ត ។

១០-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

១១-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១២-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ត្រៀម ឬ ប្រព្រឹត្តបទល្មើស ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២

## ការកំហែងយក

**មាត្រា ៣៦៣.-** និយមន័យនៃការកំហែងយក

អំពើកំហែងយក គឺជាអំពើដែលប្រព្រឹត្តដោយការប្រើហិង្សា ការគំរាមកំហែងថានឹងប្រើហិង្សា ឬ ដោយការបង្ខិតបង្ខំ ដើម្បីទទួលបាននូវ :

១-ហត្ថលេខា ឬ ស្នាមម្រាមដៃ ។

២-ការសន្យា ឬ ការបោះបង់ចោលអ្វីមួយ ។

៣-ការបង្ហាញអាថ៌កំបាំងណាមួយ ។

៤-ការប្រគល់មូលនិធិ តម្លៃ ឬ ទ្រព្យសម្បត្តិអ្វីមួយ ។

**មាត្រា ៣៦៤.-** ទោសដែលត្រូវអនុវត្ត

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៣៦៥.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើអំពើនេះបានប្រព្រឹត្តទៅលើ :

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ ត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬ ពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

**មាត្រា ៣៦៦.-** ស្ថានទម្ងន់ទោសដោយសារការប្រើប្រាស់អាវុធ

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបទល្មើសនេះប្រព្រឹត្តដោយមានការប្រើប្រាស់អាវុធ ឬ ដោយការគំរាមកំហែង

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL

**មាត្រា ៣៦៧.-** ស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវៈ ឬ ពិការភាព

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុនពេល ក្នុងពេល ឬ ក្រោយពេលប្រើហិង្សាដែលនាំឱ្យមានការកាត់អវយវៈ ឬ ពិការភាពជាអចិន្ត្រៃយ៍ ។

**មាត្រា ៣៦៨.-** ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬ អំពើឃោរឃៅ

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តមុនពេល ក្នុងពេល ឬ ក្រោយពេលប្រើទារុណកម្ម ឬ អំពើឃោរឃៅ ។

**មាត្រា ៣៦៩.-** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

អំពើកំហែងយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ប្រសិនបើអំពើនេះប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬ ក្រោយពេលប្រើហិង្សាដែលបណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់ ។

**មាត្រា ៣៧០.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៣៧១.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

៧-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៨-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបានប្រព្រឹត្ត ។

៩-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

១០-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

១១-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១២-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ៣
## ការគំរាមកំហែងហែកកេរ្តិ៍

**មាត្រា ៣៧២.-** និយមន័យនៃការគំរាមកំហែងហែកកេរ្តិ៍

អំពើគំរាមកំហែងហែកកេរ្តិ៍ គឺជាអំពើប្រព្រឹត្តដោយគំរាមកំហែងបើកកកាយ ឬចោទម្រាក់កំហុសទៅលើអំពើដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស ឬ ការរាប់អាន ដើម្បីទទួលបាននូវ ៖

១-ហត្ថលេខា ឬ ស្នាមម្រាមដៃ ។

២-ការសន្យា ឬ ការបោះបង់ចោលអ្វីមួយ ។

៣-ការបង្ហាញអាថ៌កំបាំងណាមួយ ។

៤-ការប្រគល់មូលនិធិ តម្លៃ ឬ ទ្រព្យសម្បត្តិអ្វីមួយ ។

**មាត្រា ៣៧៣.-** ទោសដែលត្រូវអនុវត្ត

អំពើគំរាមកំហែងបែបនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៣៧៤.-** ស្ថានទម្ងន់ទោសដោយសារការអនុវត្តជាក់ស្តែងនូវការគំរាមកំហែង

កាលបើអំពើគំរាមកំហែងបែបនេះ ឬ ការទម្លាក់កំហុសដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស ឬ ការរាប់អាន ត្រូវបានសម្តែងចេញជាអំពើជាក់ស្តែង ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៣៧៥.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៣៧៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការហាមឃាត់ដល់ជនបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង



5/201 ..... Ksl

៦-ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

៧-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៨-ការរឹបអូសឧបភោគភណ្ឌ សង្ហារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបានប្រព្រឹត្ត ។

៩-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

១០-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

១១-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១២-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## ការឆបោក និងអំពើប្រហាក់ប្រហែល
### ផ្នែកទី ១
### ការឆបោក

**មាត្រា ៣៧៧.-** និយមន័យនៃការឆបោក

អំពើឆបោក គឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយ ដោយប្រើឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬ ដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះ ដែលនាំឱ្យខូចប្រយោជន៍របស់បុគ្គលនេះ ឬ របស់តតិយជននូវ :

១-ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ។

២-ការផ្តល់ផ្គង់សេវា ។

៣-ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ច ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ៣៧៨.-** ទោសដែលត្រូវអនុវត្ត

អំពើឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និង ពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។

**មាត្រា ៣៧៩.-** ស្ថានទម្ងន់ទោសដែលទាក់ទងទៅនឹងជនរងគ្រោះ

អំពើឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ កាលបើ អំពើនេះបានប្រព្រឹត្តទាំឱ្យខូចប្រយោជន៍ :

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ ត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬ ពិការភាព កាលបើស្ថានភាពបុគ្គលនោះត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង។

**មាត្រា ៣៨០.-** ស្ថានទម្ងន់ទោសផ្សេងទៀត

អំពើឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ កាលបើ បទល្មើសនេះបានប្រព្រឹត្ត :

១-ដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

២-ដោយបុគ្គលដែលតាំងខ្លួនជាអ្នករាជការសាធារណៈ ។

៣-ដោយបុគ្គលដែលធ្វើការអំពាវនាវដល់សាធារណជន ដើម្បីបោះពុម្ពចេញឱ្យប្រើប្រាស់នូវមូលបត្រ ។

៤-ដោយបុគ្គលដែលធ្វើការអំពាវនាវដល់សាធារណជន ដើម្បីអង្គាសមូលនិធិសម្រាប់ជាជំនួយមនុស្សធម៌ ឬ សង្គមកិច្ច ។

៥-ជាក្រុមមានការចាត់តាំង ។

**មាត្រា ៣៨១.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទល្មើសសម្រេចដែរ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៣៨២.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការហាមឃាត់ជនជាតិបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៦-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

៧-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៨-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបានប្រព្រឹត្ត ។

៩-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

១០-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១១-ការបិទផ្សាយសេចក្ដីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១២-ការផ្សាយសេចក្ដីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៣-ការផ្សាយសេចក្ដីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## បទល្មើសប្រឆាំងប្រព័ន្ធនឹងការឆបោក
### កថាភាគទី ១
### ការទាញយកប្រយោជន៍ដោយរំលោភលើភាពទន់ខ្សោយ

**មាត្រា ៣៨៣.–** បទរំលោភលើភាពល្ងង់ខ្លៅ ឬ ភាពទន់ខ្សោយ

អំពើទាញយកប្រយោជន៍ដោយចេតនាដោយរំលោភលើភាពល្ងង់ខ្លៅ ឬ ភាពទន់ខ្សោយនៃបុគ្គលដែលបណ្តាលមកពីអាយុ ស្ថានភាពមានគភ៌ ជំងឺ ឬ ពិការភាព ដោយបង្ខំបុគ្គលនេះ ឱ្យប្រព្រឹត្តអំពើ ឬ មិនប្រព្រឹត្តអំពើដែលធ្វើឱ្យខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងររបស់បុគ្គលនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

### កថាភាគទី ២
### ការបន្លំ

**មាត្រា ៣៨៤.–** បទបន្លំ

អំពើបន្លំ គឺជាអំពើរបស់បុគ្គលដែលដឹងខ្លួនថាគ្មានលទ្ធភាពដាច់ខាតនឹងបង់ថ្លៃ ឬ ដែលសម្រេចចិត្តមិនបង់ថ្លៃ :

១-ឱ្យគេបម្រើម្ហូបអាហារ ឬ ភេសជ្ជៈនៅក្នុងវង្គសាល ភោជនីយដ្ឋាន ឬ នៅក្នុងគ្រឹះស្ថានដទៃទៀត ដែលបើកចំហដល់សាធារណជន ។

២-ឱ្យគេប្រគល់បន្ទប់មួយ និងកាន់កាប់បន្ទប់នេះនៅក្នុងសណ្ឋាគារ ឬ គ្រឹះស្ថានដទៃទៀត ដែលបើកចំហដល់សាធារណជន ។

៣-ឱ្យគេដឹកជញ្ជូនខ្លួនតាមត្រីចក្រយាន តាមរថយន្តឈ្នួល ឬ តាមមធ្យោបាយដឹកជញ្ជូនផ្សេងទៀត ។

អំពើបន្លំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

**មាត្រា ៣៨៥.–** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងកថាភាគនេះ ត្រូវផ្តន្ទាទោសដូចបទមជ្ឈិមខាងលើដែរ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
149/2644

**មាត្រា ៣៨៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងនៅក្នុងកថាភាគនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៥-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## កថាភាគទី ៣
## ការរំលោភលើសេរីភាពនៃការលក់ដេញថ្លៃ

**មាត្រា ៣៨៧.-** បទដេញថ្លៃមិនត្រឹមត្រូវ

អំពើប្រព្រឹត្ត នៅក្នុងការលក់ជាសាធារណៈ តាមការដេញថ្លៃ ដើម្បីកម្ចាត់អ្នកដេញថ្លៃ ឬ ធ្វើឱ្យខូចការដេញថ្លៃដោយអំណោយ ការសន្យា ការព្រមព្រៀង ឬ តាមគ្រប់មធ្យោបាយទុច្ចរិតដទៃទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៣៨៨.-** បទធ្វើជាឧបសគ្គដល់សេរីភាពនៃការលក់ដេញថ្លៃ

អំពើប្រព្រឹត្តនៅក្នុងការលក់ជាសាធារណៈតាមការដេញថ្លៃ ដើម្បីធ្វើជាឧបសគ្គដល់សេរីភាពនៃការដេញថ្លៃ ដោយប្រើហិង្សា ឬ ដោយការគំរាមកំហែង ត្រូវផ្តន្ទាទោសដាក់

ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៣៨៩.- ការប៉ុនប៉ង**

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៣៩០.- ទោសបន្ថែម : ប្រភេទ និងរយៈពេល**

ចំពោះបទមជ្ឈិមដែលមានចែងនៅក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋជាស្ថាពរ ឬសម្រាប់រយៈពេល ៥(ប្រាំ)ឆ្នាំយ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣- ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

៥-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់រយៈពេល៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៣
## ការរំលោភលើទំនុកចិត្ត និងអំពើប្រមាថប្រមើល
### ផ្នែកទី ១
### ការរំលោភលើទំនុកចិត្ត

**មាត្រា ៣៩១.- និយមន័យនៃការរំលោភលើទំនុកចិត្ត**

ការរំលោភលើទំនុកចិត្ត គឺជាអំពើដែលបំបាត់មូលនិធិ តម្លៃ ឬ ទ្រព្យសម្បត្តិអ្វីមួយ ទាំ



ត ទៅរាជកិច្ចលេខ ៣

ឱ្យខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបានប្រគល់ឱ្យបុគ្គលនោះ ហើយបុគ្គលនោះ បានយល់ព្រមដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬ យកមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់ ។

**មាត្រា ៣៩២.-** ទោសដែលត្រូវអនុវត្ត

អំពើរំលោភលើទំនុកចិត្ត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៣៩៣.-** បទរំលោភលើទំនុកចិត្តពិសេស ដោយអភិបាល ឬ បុគ្គលផ្សេងទៀត

គ្រប់អភិបាល ឬ អ្នកត្រួតពិនិត្យរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលមូលនិធិ ឬ បុគ្គលដែលត្រូវបានតុលាការជ្រើសតាំងឱ្យធ្វើជំនួសនូវកិច្ចការរបស់អ្នកទាំងនេះ ឬ និយោជិតដែលទទួលអាណត្តិពីនីតិបុគ្គល ដែលប្រព្រឹត្តអំពើណាមួយដែលជាការរំលោភលើទំនុកចិត្ត ក្នុងគោលបំណងទទួលផលប្រយោជន៍ដល់ខ្លួន ឬ តតិយជន ឬ ក្នុងគោលបំណងធ្វើឱ្យខូចខាតដល់នីតិបុគ្គល ហើយបានបណ្តាលឱ្យមានការខូចខាតទ្រព្យសម្បត្តិរបស់នីតិបុគ្គលនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

បទប្បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកជម្រះបញ្ជីរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលមូលនិធិ ឬ បុគ្គលដែលត្រូវបានតុលាការជ្រើសតាំងឱ្យធ្វើជំនួសនូវកិច្ចការរបស់អ្នកជម្រះបញ្ជី បានប្រព្រឹត្តអំពើដូចបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ហើយបានបណ្តាលឱ្យមានការខូចខាតទ្រព្យសម្បត្តិរបស់នីតិបុគ្គលនោះ ។

ការប៉ុនប៉ងប្រព្រឹត្តបទល្មើសដែលបានកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ នឹងត្រូវផ្តន្ទាទោសដូចគ្នាដែរ ។

**មាត្រា ៣៩៤.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនល្មើស

អំពើរំលោភលើទំនុកចិត្ត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើបទល្មើសនេះបានប្រព្រឹត្តឡើង :

១-ដោយបុគ្គលណាម្នាក់ដែលបានធ្វើការអំពាវនាវដល់សាធារណជន ដើម្បីទទួលបានមូលនិធិ ឬ តម្លៃសម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន ឬ ជាផលប្រយោជន៍របស់សហគ្រាសឧស្សាហកម្ម ពាណិជ្ជកម្ម ។

២-ដោយអាណត្តិគាហករបស់តុលាការ ឬ អ្នកជំនួយរបស់តុលាការនៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន ឬ នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

៣-ដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់ខ្លួន ឬ នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

**មាត្រា ៣៩៥.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៣៩៦.-** ទោសបន្ថែមៈ ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាសៈ

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៤-ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

៥-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៦-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបានប្រព្រឹត្ត ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ

យ៉ាងច្រើន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២
## ការបង្វែរវត្ថុរឹបអូស ឬដាក់ធានា

**មាត្រា ៣៩៧.-** បទបង្វែរវត្ថុរឹបអូស ឬវត្ថុដាក់ធានា

អំពើរបស់កូនបំណុលដែលកែបំបាត់ ឬ បំផ្លាញវត្ថុដែលបានឃាត់ទុក ឬរឹបអូស ដោយអាជ្ញាធរមាននីតិសម្បទា ឬ ដាក់ដើម្បីធានានូវសិទ្ធិលើបំណុល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន)រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៣៩៨.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

## ជំពូកទី ៤
## បទល្មើសបំពេញបន្ថែម
## ផ្នែកទី ១
## ការទទួលផលចោរកម្ម

**មាត្រា ៣៩៩.-** និយមន័យនៃការទទួលផលចោរកម្ម

អំពើទទួលផលចោរកម្ម គឺជាអំពើទទួល លាក់បំបាំង រក្សាទុក ឬ បញ្ជូនវត្ថុអ្វីមួយ ដោយដឹងថាវត្ថុនោះបានមកពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ។

ត្រូវចាត់ទុកជាអំពើទទួលផលចោរកម្មផងដែរ :

១-អំពើធ្វើជាអន្តរការីដើម្បីបញ្ជូនវត្ថុអ្វីមួយ ដោយដឹងថារបស់នោះបានមកពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ។

២-អំពើដែលបានទទួលផលពីផលនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដោយបានដឹងហេតុការណ៍ច្បាស់ ។

**មាត្រា ៤០០.-** ទោសដែលត្រូវអនុវត្ត

អំពើទទួលផលចោរកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០(ដប់លាន) រៀល ។

**មាត្រា ៤០១.-** ស្ថានទម្ងន់ទោស

អំពើទទួលផលចោរកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០(ដប់) ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្តឡើង :

១-ជាទម្លាប់ ។

២-ដោយប្រើប្រាស់ភាពងាយស្រួលដែលការប្រកបសកម្មភាពវិជ្ជាជីវៈផ្តល់ឱ្យ ។

៣-ជាក្រុមមានការចាត់តាំង ។

**មាត្រា ៤០២.-** អតិបរមានៃទោសពិន័យ

អតិបរមានៃទោសពិន័យ អាចស្មើនឹងតម្លៃវត្ថុនៃអំពើទទួលផលចោរកម្ម ។

**មាត្រា ៤០៣.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាង

ច្រើន ចំពោះបទឧក្រិដ្ឋ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៥-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

៨-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៩-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបានប្រព្រឹត្ត ។

១០-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

១១-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

១២-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ត្រៀម ឬ ប្រព្រឹត្តបទល្មើសជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២

## ការសំអាតប្រាក់

**មាត្រា ៤០៤.-** និយមន័យនៃការសំអាតប្រាក់

ការសំអាតប្រាក់ ជាអំពើផ្តល់ឱ្យតាមគ្រប់មធ្យោបាយនូវយុត្តិកម្មកុហក ដើម្បីលាក់

បំបាំងអត្តប្រយោជន៍ផ្ទាល់ ឬ ប្រយោលនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម ។

ត្រូវចាត់ជាការសំអាតប្រាក់ផងដែរ អំពើជួយដល់ប្រតិបត្តិការនៃការបណ្តាក់ទុន ការលាក់បំបាំង ឬ ការផ្លាស់ប្តូរផលផ្ទាល់ ឬ ប្រយោលនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម ។

**មាត្រា ៤០៥.- ទោសដែលត្រូវអនុវត្ត**

ការសំអាតប្រាក់ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល រហូតស្មើនឹងតម្លៃមូលនិធិ ឬ តម្លៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការសំអាតប្រាក់ ។

ក្នុងករណីបទល្មើសដែលជាប្រភពនៃទ្រព្យសម្បត្តិ ឬ មូលនិធិដែលជាកម្មវត្ថុនៃការសំអាតប្រាក់ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារធ្ងន់ជាងទោសដាក់ពន្ធនាគារ ដែលមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើនោះ ការសំអាតប្រាក់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារដូចបទល្មើសដែលជនល្មើសបានដឹង ហើយក្នុងករណីបទល្មើសមានភ្ជាប់មកជាមួយនូវស្ថានទម្ងន់ទោសច្រើននោះ ជនល្មើសត្រូវទទួលទណ្ឌកម្ម ដោយយោងទៅតាមស្ថានទម្ងន់ទោសដែលខ្លួនបានដឹងប៉ុណ្ណោះ។

**មាត្រា ៤០៦.- ស្ថានទម្ងន់ទោស**

ការសំអាតប្រាក់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្ត :

១-ជាទម្លាប់ ។

២-ដោយប្រើភាពងាយស្រួល ដែលការប្រកបនូវសកម្មភាពវិជ្ជាជីវៈផ្តល់ឱ្យ ។

៣-ជាក្រុមមានការចាត់តាំង ។

**មាត្រា ៤០៧.- ការប៉ុនប៉ង**

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៤០៨.- ទោសបន្ថែម : ប្រភេទ និងរយៈពេល**

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបាន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ក្រសួងព្រះបរមរាជវាំង



1377/2011
Ksl

១-ការដកសិទ្ធិខ្លះជាពលរដ្ឋជាស្ថាពរ ឬសម្រាប់រយៈពេល ៥(ប្រាំ)ឆ្នាំយ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលៈបើបទល្មើសនេះបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៤-ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

៥-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៦-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបានប្រព្រឹត្ត ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ៤០៩.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៤០៤(និយមន័យនៃការសំអាតប្រាក់) នៃក្រមនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០.០០០ (មួយរយលាន) រៀល ទៅ ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើនដូចតទៅនេះ :

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០(ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ ។

២-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬ ច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃតាមបែបបទកំណត់ដោយមាត្រា ១៧៤(ការហាមឃាត់ចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) នៃក្រមនេះ ។

៦-ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨(ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩(ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៧-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨(ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩(ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## មាតិកាទី ២

## ការប៉ះពាល់ដល់ទ្រព្យសម្បត្តិ

## ជំពូកទី ១

## ការបំផ្លិចបំផ្លាញ ការធ្វើឱ្យខូចខាត និងការធ្វើឱ្យខូចខាត

## ផ្នែកទី ១

## ការបំផ្លិចបំផ្លាញ ការធ្វើឱ្យទ្រុឌទ្រោម និងការធ្វើឱ្យខូចខាត

**មាត្រា ៤១០.-** បទធ្វើឱ្យខូចខាតដោយចេតនា

អំពើប្រព្រឹត្តដោយចេតនា ដោយបំផ្លិចបំផ្លាញ ធ្វើឱ្យទ្រុឌទ្រោម ឬ ធ្វើឱ្យខូចខាតទ្រព្យ

សម្បត្តិរបស់អ្នកដទៃនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល លើកលែងតែការខូចខាតមានលក្ខណៈស្រាល ។

**មាត្រា ៤១១.-** ស្ថានទម្ងន់ទោស

បទល្មើសដែលមានចែងក្នុងមាត្រា ៤១០(បទធ្វើឱ្យខូចខាតដោយចេតនា) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល នៅក្នុងករណីដូចតទៅ :

១-កាលបើបទល្មើសនេះ បានប្រព្រឹត្តដោយបុគ្គលច្រើនរូបធ្វើសកម្មភាពក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត ។

២-កាលបើបទល្មើសនេះ បានប្រព្រឹត្តនៅក្នុងទីកន្លែងជាលំនៅឋាន ។

៣-កាលបើបទល្មើសនេះ បានប្រព្រឹត្តនៅក្នុងទីកន្លែង សម្រាប់តម្កល់មូលនិធិ តម្លៃ ទំនិញ ឬ សម្ភារៈ ។

៤-កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឱ្យខូចប្រយោជន៍ដល់សំណង់គ្រឹះស្ថានសាធារណៈ ឬ ផ្លូវសាធារណៈ ។

៥-កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឱ្យខូចប្រយោជន៍ដល់ដំណាំ ឬកសិផល ។

៦-កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឱ្យខូចបង្គោលព្រំដែនអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤១២.-** ស្ថានទម្ងន់ទោសដែលទាក់ទងទៅនឹងជនរងគ្រោះ

បទល្មើសដែលមានចែងក្នុងមាត្រា ៤១០(បទធ្វើឱ្យខូចខាតដោយចេតនា) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល នៅក្នុងករណីដូចតទៅ :

១-កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឱ្យខូចប្រយោជន៍របស់ចៅក្រម អ្នកសាធារណៈ ឬ មេធាវី ដើម្បីជះឥទ្ធិពលដល់ការបំពេញមុខងាររបស់ខ្លួន ។

២-កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឱ្យខូចប្រយោជន៍ជនរងគ្រោះ ឬ ដើម

បណ្តឹងរដ្ឋប្បវេណី ដើម្បីឃាត់កុំឱ្យប្តឹងពីបទល្មើស ឬ សុំធ្វើការជួសជុលការខូចខាត ។

៣-កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឱ្យខូចប្រយោជន៍របស់សាក្សី ដើម្បីឃាត់កុំឱ្យផ្តល់ភស្តុតាងក្នុងពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬ នៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ឬដើម្បីធ្វើឱ្យមានឥទ្ធិពលទៅលើសក្ខីកម្មនេះ ។

៤-កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឱ្យខូចប្រយោជន៍ជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះបុគ្គលនេះបានប្តឹងពីបទល្មើស ឬ បានសុំឱ្យធ្វើការជួសជុលនូវការខូចខាត ។

៥-កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឱ្យខូចប្រយោជន៍របស់សាក្សី ដោយមូលហេតុភស្តុតាង ដែលសាក្សីនេះបានផ្តល់នៅក្នុងពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬ នៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

**មាត្រា ៤១៣.-** ស្ថានទម្ងន់ទោសដោយសារការប្រើប្រាស់វិធីគ្រោះថ្នាក់ដល់បុគ្គល

អំពើប្រព្រឹត្តដោយចេតនា ដើម្បីបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាតទ្រុឌទ្រោម ឬ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ដោយអានុភាពនៃគ្រឿងផ្ទុះ នៃអគ្គីភ័យ ឬ គ្រប់វិធីដទៃទៀត ដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់បុគ្គល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០(បួនលាន)រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤១៤.-** ស្ថានទម្ងន់ទោសដោយសារការបង្ករបួសស្នាមដល់អ្នកដទៃ

បទល្មើសដែលបញ្ញត្តដោយមាត្រា ៤១៣ (ស្ថានទម្ងន់ទោសដោយសារការប្រើប្រាស់វិធីគ្រោះថ្នាក់ដល់បុគ្គល) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើអំពើនេះបង្កឱ្យមានរបួសដល់អ្នកដទៃ ។

**មាត្រា ៤១៥.-** ស្ថានទម្ងន់ទោសដោយសារមានការកាត់អវយវៈ ឬ ពិការភាព

បទល្មើសដែលបញ្ញត្តដោយមាត្រា ៤១៣ (ស្ថានទម្ងន់ទោសដោយសារការប្រើប្រាស់វិធីគ្រោះថ្នាក់ដល់បុគ្គល) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះនាំឱ្យមានការកាត់អវយវៈ ឬ ពិការភាពជាអចិន្ត្រៃយ៍ ។

**មាត្រា ៤១៦.-** ស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តបទល្មើសដោយមានការចាត់តាំង

បទល្មើសដែលមានចែងនៅក្នុងមាត្រា ៤១៣ (ស្ថានទម្ងន់ទោសដោយសារការប្រើប្រាស់វិធីគ្រោះថ្នាក់ដល់បុគ្គល) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះ ត្រូវបានប្រព្រឹត្តឡើងជាក្រុមមានការចាត់តាំង ។

**មាត្រា ៤១៧.-** ស្ថានទម្ងន់ទោសដោយសារមរណភាពរបស់អ្នកដទៃ

បទល្មើសដែលមានចែងនៅក្នុងមាត្រា ៤១៣ (ស្ថានទម្ងន់ទោសដោយសារការប្រើប្រាស់វិធីគ្រោះថ្នាក់ដល់បុគ្គល) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើនេះ បណ្តាលឱ្យអ្នកដទៃស្លាប់ ដោយគ្មានចេតនាសម្លាប់។

**មាត្រា ៤១៨.-** បទធ្វើឱ្យមានការខូចខាតស្រាល

អំពើប្រព្រឹត្តដោយចេតនា ដើម្បីបំផ្លិចបំផ្លាញ ធ្វើឱ្យទ្រុឌទ្រោម ឬ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ថ្ងៃ ទៅ ៦ (ប្រាំមួយ) ថ្ងៃ និងពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ប្រសិនបើការខូចខាតមានលក្ខណៈស្រាល ។

បទប្បញ្ញត្តិនៃមាត្រានេះ មិនត្រូវអនុវត្តទៅលើទ្រព្យសម្បត្តិវប្បធម៌សាធារណៈ ឬ ឯកជន ដែលជាផ្នែកនៃបេតិកភណ្ឌជាតិរបស់ព្រះរាជាណាចក្រកម្ពុជាទេ ។

**មាត្រា ៤១៩.-** បទធ្វើឱ្យខូចខាតផ្សេងទៀត ដោយការខ្វះការប្រុងប្រយ័ត្ន ឬ ការមិនគោរពបទបញ្ជា

អំពើបំផ្លិចបំផ្លាញ ធ្វើឱ្យទ្រុឌទ្រោម ឬ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ដោយអានុភាពនៃគ្រឿងផ្ទុះ ឬ អគ្គិភ័យ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល កាលបើអំពើនេះ បណ្តាលមកពី :

១-ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា។

២-ការរំលោភបំពានលើកាតព្វកិច្ចសន្តិសុខ ឬ កាតព្វកិច្ចប្រុងប្រយ័ត្នដែល

ROYAUME DU CAMBODGE
MINISTÈRE DU PALAIS ROYAL

1264



KSL

**មាត្រា ៤២០.- បទធ្វើឱ្យខូចខាតបណ្ណប្រកាស ឬសេចក្តីជូនដំណឹងជាផ្លូវការ**

អំពើប្រព្រឹត្តដោយចេតនាដោយបំផ្លិចបំផ្លាញ ធ្វើឱ្យទ្រុឌទ្រោម ឬ ធ្វើឱ្យខូចខាតបណ្ណប្រកាស ឬ សេចក្តីជូនដំណឹងជាផ្លូវការរបស់រដ្ឋបាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ថ្ងៃ ទៅ ៦(ប្រាំមួយ) ថ្ងៃ និងពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

**មាត្រា ៤២១.- ការប៉ុនប៉ង**

លើកលែងតែបទល្មើសដែលកំណត់ក្នុងមាត្រា ៤១៩(បទធ្វើឱ្យខូចខាតផ្សេងទៀតដោយការខ្វះការប្រុងប្រយ័ត្ន ឬ ការមិនគោរពបទបញ្ជា) នៃក្រមនេះ ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៤២២.- ទោសបន្ថែម: ប្រភេទ និងរយៈពេល**

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស:

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការស្នាក់នៅសម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៥-ការហាមឃាត់ជនបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL
143/2011



Kol

៧-ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

៨-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៩-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបានប្រព្រឹត្ត ។

១០-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬច្រើនគ្រឿង ។

១១-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

១២-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់គ្រៀម ឬ ប្រព្រឹត្តបទល្មើសជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៤-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១៥-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៦-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយនូវគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២

## ការគំរាមកំហែងថានឹងធ្វើការបំផ្លិចបំផ្លាញ ធ្វើឱ្យខូចគ្រោះថ្នាក់ ឬ ធ្វើឱ្យខូចខាត

**មាត្រា ៤២៣.-** បទគំរាមកំហែងថានឹងធ្វើឱ្យខូចខាត

អំពើគំរាមកំហែងថានឹងប្រព្រឹត្តការបំផ្លិចបំផ្លាញ ការធ្វើឱ្យគ្រុនគ្រោម ឬ ការធ្វើឱ្យខូចខាត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ប្រសិនបើការគំរាមកំហែងនេះបានធ្វើម្ដងហើយម្ដងទៀត ឬ ដោយបានសម្ដែងចេញតាមលិខិត តាមរូបភាព ឬ វិធីផ្សេងទៀត ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្នុងករណីដែលទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃអំពើគំរាមកំហែង ថានឹងបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាត ឬ ធ្វើឱ្យខូចខាត មានតម្លៃតិចតួច ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

**មាត្រា ៤២៤.-** បទគំរាមកំហែងថានឹងធ្វើឱ្យខូចខាតដែលភ្ជាប់នូវបញ្ជាអ្វីមួយ

អំពើគំរាមកំហែង តាមមធ្យោបាយណាក៏ដោយ ថានឹងប្រព្រឹត្តការបំផ្លិចបំផ្លាញ ការធ្វើឱ្យខូចខាត ឬ ការធ្វើឱ្យខូចខាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន) រៀល ទៅ ៤.០០០.០០០(បួនលាន) រៀល ប្រសិនបើការគំរាមកំហែងនេះមានភ្ជាប់នូវបញ្ជាឱ្យបំពេញ ឬ មិនបំពេញកិច្ចអ្វីមួយ ។

**មាត្រា ៤២៥.-** បទក្លែងព័ត៌មាន

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល អំពើផ្តល់ ឬ បើកកកាយព័ត៌មានក្លែង ដើម្បីធ្វើឱ្យជឿថា នឹងកើតមានឡើងនូវការបំផ្លិចបំផ្លាញ ការធ្វើឱ្យខូចខាត ឬ ការធ្វើឱ្យខូចខាត ប្រកបដោយគ្រោះថ្នាក់ចំពោះមនុស្ស ។

**មាត្រា ៤២៦.-** ទោសបន្ថែម: ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស:

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៥-ការហាមឃាត់មិនឱ្យជនបរទេសចូល ឬ ការស្នាក់នៅក្នុងដែនដី

នៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

៨-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៩-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបានប្រព្រឹត្ត ។

១០-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

១១-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

១២-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ត្រៀម ឬ ប្រព្រឹត្តបទល្មើសជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៣-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

១៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២

## បទល្មើសក្នុងវិស័យព័ត៌មានវិទ្យា

**មាត្រា ៤២៧.-** បទចូលទៅដល់ ឬ ស្ថិតនៅនឹងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ

អំពើចូលទៅដល់ ឬស្ថិតនៅនឹងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ ដោយទុច្ចរិត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

កាលបើអំពើនោះជាហេតុបណ្ដាលឱ្យមានការលុបបំបាត់ ឬ កែប្រែទិន្នន័យដែលមាននៅក្នុងប្រព័ន្ធ ឬ ឱ្យមានការខូចខាតនូវដំណើរការនៃប្រព័ន្ធ បទល្មើសនេះត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៤២៨.-** បទបង្កើតជាឧបសគ្គដល់ដំណើរការនៃប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ

អំពើបង្កើតជាឧបសគ្គ ធ្វើឱ្យខូចដំណើរការនៃប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ទៅ ២(ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៤២៩.-** បទបញ្ចូល លុបបំបាត់ ឬ កែប្រែដោយទុច្ចរិតនូវទិន្នន័យ

អំពើបញ្ចូល លុបបំបាត់ ឬ កែប្រែដោយទុច្ចរិតនូវទិន្នន័យទៅក្នុងប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្ត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៤៣០.-** បទចូលរួមក្នុងក្រុមប្រមូលផ្ដុំ ឬ ក្នុងសន្និធិភាពដើម្បីរៀបចំប្រព្រឹត្តបទល្មើស

អំពើចូលរួមទៅក្នុងក្រុមប្រមូលផ្ដុំ ឬទៅក្នុងសន្និធិភាព ដែលបង្កើតឡើងដើម្បីរៀបចំប្រព្រឹត្តបទល្មើសដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៤៣១.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្ដន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៤៣២.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបាន

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៤-ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

៥-ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៦-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបានប្រព្រឹត្ត ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៨-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## គន្ថីទី ៤

## បទល្មើសប្រឆាំងនឹងជាតិ

## មាតិកាទី ១

## ការប៉ះពាល់ដល់ស្ថាប័នចម្បងរបស់រដ្ឋ

## ជំពូកទី ១

## ការបំពានដល់អង្គព្រះមហាក្សត្រ

**មាត្រា ៤៣៣.-** បទរាជឃាតកម្ម

រាជឃាតកម្ម គឺជាឃាតកម្មចំពោះអង្គព្រះមហាក្សត្រ ។

រាជឃាតកម្ម ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ៤៣៤.-** បទធ្វើទារុណកម្ម ឬ អំពើឃោរឃៅចំពោះអង្គព្រះមហាក្សត្រ

ទារុណកម្ម ឬ អំពើឃោរឃៅចំពោះអង្គព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ។

**មាត្រា ៤៣៥.-** បទហិង្សាចំពោះអង្គព្រះមហាក្សត្រ

អំពើហិង្សាប្រព្រឹត្តដោយចេតនាចំពោះអង្គព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ៤៣៦.-** ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬ ពិការភាព

អំពើហិង្សាប្រព្រឹត្តដោយចេតនាចំពោះអង្គព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើនេះនាំឱ្យមានការកាត់អវយវៈ ឬ ពិការភាពជាអចិន្ត្រៃយ៍ដល់អង្គព្រះមហាក្សត្រ ។

**មាត្រា ៤៣៧.-** ស្ថានទម្ងន់ទោសដោយសារការចូលទិវង្គត

អំពើហិង្សាប្រព្រឹត្តដោយចេតនាចំពោះអង្គព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើអំពើនេះ នាំឱ្យមានការចូលទិវង្គតដោយគ្មានចេតនានឹងធ្វើឱ្យមានការចូលទិវង្គតទេ។

**មាត្រា ៤៣៨.-** ទោសបន្ថែម: ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL ព្រះបរមរាជវាំង 141/2010

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ដល់ជនបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## ការប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ
### ផ្នែកទី ១
### អំពើក្បត់ជាតិ និងចារកម្ម

**មាត្រា ៤៣៩.-** អំពើក្បត់ជាតិ និងចារកម្ម

បទល្មើសដែលមានចែងក្នុងផ្នែកនេះ ជាអំពើក្បត់ជាតិ កាលបើបទល្មើសប្រព្រឹត្តដោយពលរដ្ឋខ្មែរ ឬ ដោយយោធិនខ្មែរ និងជាចារកម្ម កាលបើបទល្មើសនេះប្រព្រឹត្តដោយបុគ្គលដទៃទៀត ។

**មាត្រា ៤៤០.-** បទប្រគល់ឱ្យរដ្ឋបរទេសនូវដែនដីជាតិទាំងស្រុង ឬ មួយផ្នែក

ការប្រគល់ឱ្យរដ្ឋបរទេស ឬ ភ្នាក់ងារបរទេស នូវដែនដីជាតិទាំងស្រុង ឬ មួយផ្នែក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ៤៤១.-** បទប្រគល់ឱ្យរដ្ឋបរទេសនូវកងយោធពលខេមរភូមិន្ទ

អំពើប្រគល់ឱ្យរដ្ឋបរទេស ឬ ភ្នាក់ងារបរទេស នូវកងយោធពលខេមរភូមិន្ទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ៤៤២.-** បទប្រគល់ឱ្យរដ្ឋបរទេសនូវសម្ភារៈ ជាអាទិ៍សម្រាប់ការពារជាតិ

អំពើប្រគល់ឱ្យរដ្ឋបរទេស ឬ ភ្នាក់ងារបរទេស នូវគ្រឿង សម្ភារៈ សំណង់ បរិក្ខារ ឋបនីយកណ្ឌ ឬ គ្រឿងយន្តសម្រាប់ការពារជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ៤៤៣.-** បទសន្ធិដ្ឋិភាពជាមួយបរទេស

បទសន្ធិដ្ឋិភាពជាមួយបរទេស គឺជាអំពើត្រូវរៀវន្ធាដោយសម្ងាត់ជាមួយរដ្ឋបរទេស ឬ ភ្នាក់ងារបរទេស ដើម្បីបង្កើតឱ្យមានអំពើប្រទូស្តរ៉ាយ ឬ ឱ្យមានអំពើឈ្លានពានប្រឆាំងនឹងព្រះរាជាណាចក្រកម្ពុជា ។

បទសន្ធិដ្ឋិភាពជាមួយបរទេស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ៤៤៤.-** បទប្រគល់ឱ្យរដ្ឋបរទេសនូវមធ្យោបាយធ្វើការប្រទូស្តរ៉ាយ ឬ ឈ្លានពាន

អំពើប្រគល់ឱ្យរដ្ឋបរទេស ឬ ភ្នាក់ងារបរទេស នូវមធ្យោបាយសម្រាប់ធ្វើការប្រទូស្តរ៉ាយ ឬ ឈ្លានពានប្រឆាំងនឹងព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ៤៤៥.-** បទប្រគល់ឱ្យរដ្ឋបរទេសនូវព័ត៌មាន ជាអាទិ៍ដែលអាចធ្វើឱ្យអន្តរាយការការពារជាតិ

អំពើប្រគល់ ឬ ធ្វើឱ្យងាយស្រួលធ្លាក់ដល់ដៃរដ្ឋបរទេស ឬ ភ្នាក់ងារបរទេសនូវព័ត៌មាន វិធី វត្ថុ ឯកសារ ទិន្នន័យព័ត៌មានវិទ្យា ឬ សំណាកបត្រដែលអាចធ្វើឱ្យអន្តរាយការការពារជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ៤៤៦.-** បទប្រមូលផ្តុំព័ត៌មាន ជាអាទិ៍ដែលអាចធ្វើឱ្យអន្តរាយការការពារជាតិ

អំពើទទួល ឬ ប្រមូលផ្តុំដើម្បីផ្តល់ទៅឱ្យរដ្ឋបរទេស ឬ ភ្នាក់ងារបរទេសនូវព័ត៌មាន វិធី វត្ថុ ឯកសារ ទិន្នន័យព័ត៌មានវិទ្យា ឬ សំណាកបត្រដែលអាចធ្វើឱ្យអន្តរាយការការពារ

LE MINISTRE DU PALAIS ROYAL

ជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៤៤៧.–** បទបំផ្លិចបំផ្លាញ ជាអាទិ៍នូវសម្ភារៈដែលអាចធ្វើឱ្យអន្តរាយការការពារជាតិ

អំពើបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាត ឬ កែបំបាត់ស្បៀង ឯកសារ សម្ភារៈ សំណង់ បរិក្ខារ ឋបនីយភណ្ឌ គ្រឿងយន្ត គ្រឿងសព្វាវុធ គ្រឿងបន្ទាស់បច្ចេកទេស ឬ គ្រឿងគាំពារខាងបច្ចេកទេសផ្សេងទៀត ឬ ប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ ឬ អំពើធ្វើឱ្យរាំងស្ទះដល់ដំណើរការជាប្រក្រតីរបស់ឧបករណ៍ទាំងនោះ កាលបើអំពើនេះ អាចនាំឱ្យអន្តរាយការការ-ពារជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ៤៤៨.–** បទផ្តល់ព័ត៌មានមិនពិត

អំពើផ្តល់ដល់អាជ្ញាធរស៊ីវិល ឬ យោធាខ្មែរនូវព័ត៌មានមិនពិតដែលអាចធ្វើឱ្យអន្តរាយការការពារជាតិ ដើម្បីបម្រើផលប្រយោជន៍នៃរដ្ឋបរទេស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤៤៩.–** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងក្នុងមាត្រា ៤៤៨ (បទផ្តល់ព័ត៌មានមិនពិត) ត្រូវបានផ្តន្ទាទោសដូចបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៤៥០.–** ទោសបន្ថែមៈ ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាសៈ

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

ROYAUME du CAMBODGE LE MINISTRE du PALAIS ROYAL

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២
## ឧបឃាត និងការរួមគំនិតក្បត់

**មាត្រា ៤៥១.-** បទឧបឃាត

ឧបឃាត គឺជាការប្រព្រឹត្តអំពើហិង្សាមួយ ឬ ច្រើន ក្នុងគោលបំណងបង្កឱ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ឬ នាំឱ្យមានការប៉ះពាល់ដល់បូរណភាពនៃដែនដីជាតិ ។

បទឧបឃាត ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១៥(ដប់ប្រាំ) ឆ្នាំ ទៅ ៣០(សាមសិប) ឆ្នាំ ។

**មាត្រា ៤៥២.-** ស្ថានទម្ងន់ទោសដែលទាក់ទងទៅនឹងជនល្មើស

ឧបឃាតត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត កាលបើអំពើនេះត្រូវបានប្រព្រឹត្តដោយជនដែលជាភ្នាក់ងារសាធារណៈ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា ៤៥៣.-** បទរួមគំនិតក្បត់

អំពើរួមគំនិតក្បត់ គឺជាគម្រោងដែលបង្កើតឡើងដោយមនុស្សច្រើននាក់ដើម្បីប្រព្រឹត្ត ឧបឃាត កាលបើគម្រោងនេះ ត្រូវបានសម្តែងចេញជារូបរាងច្បាស់លាស់ ដោយអំពើជាក់ស្តែងមួយ ឬ ច្រើន ។

ការរួមគំនិតក្បត់ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ប្រសិនបើបទល្មើសនេះ ត្រូវបានប្រព្រឹត្តដោយអ្នករាជការសាធារណៈ ។

**មាត្រា ៤៥៤.-** ការលើកលែងឱ្យរួចផុតពីទោស

បុគ្គលណាដែលបានចូលរួមក្នុងអំពើរួមគំនិតក្បត់ ត្រូវលើកលែងឱ្យរួចផុតពីការទទួលទោស ប្រសិនបើមុនការចោទប្រកាន់ បុគ្គលនោះបានបង្ហាញប្រាប់ដល់អាជ្ញាធរមានសមត្ថកិច្ច ពីអត្ថិភាពនៃអំពើនេះ ហើយបាននាំឱ្យស្គាល់អត្តសញ្ញាណនៃអ្នកចូលរួមដទៃទៀត ។

**មាត្រា ៤៥៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ដល់ជនបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ៣

## កុបកម្ម

**មាត្រា ៤៥៦.-** និយមន័យនៃកុបកម្ម

កុបកម្ម គឺជាអំពើហិង្សាជាសមូហភាព ដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ឬ នាំឱ្យមានការប៉ះពាល់ដល់បូរណភាពនៃដែនដីជាតិ ។

**មាត្រា ៤៥៧.-** ទោសដែលត្រូវអនុវត្ត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ អំពើចូលរួមនៅក្នុងចលនាកុបកម្ម :

១-ដោយសាងសង់គ្រឿងរាំងផ្លូវ គ្រឿងការពារ ឬ ដោយធ្វើការងារ ដែលមានគោលបំណងរារាំងសកម្មភាពកម្លាំងសាធារណៈ ។

២-ដោយកាន់កាប់អគារ ឬ ឋបនីយកណ្ឌដោយកម្លាំង ឬ ដោយកលល្បិច ។

៣-ដោយបំផ្លិចបំផ្លាញអគារ ឬ ឋបនីយកណ្ឌ ។

៤-ដោយរាំងការដឹកជញ្ជូន ឬ ការផ្គត់ផ្គង់ពស្តុភារឱ្យកុបករ ។

៥-ដោយញុះញង់ដោយផ្ទាល់ឱ្យមានការប្រមូលផ្តុំកុបករ ។

៦-ដោយមានការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

គ្រប់ប្រភេទ ។

៧-ដោយតាំងខ្លួនជំនួសអាជ្ញាធរស្របច្បាប់ ។

**មាត្រា ៤៥៨.-** ស្ថានទម្ងន់ទោសនៃកុបកម្ម

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ អំពើចូលរួមនៅក្នុងចលនាកុបកម្ម :

១-ដោយប្រើកម្លាំងដណ្តើមយកនូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ឬ សារធាតុដទៃទៀត ដែលមានគ្រោះថ្នាក់ដល់បុគ្គល ។

២-ដោយផ្តល់ដល់កុបករនូវអាវុធ គ្រាប់រំសេវ គ្រឿងផ្ទុះ ឬ សារធាតុដទៃទៀត ដែលមានគ្រោះថ្នាក់ដល់បុគ្គល ។

**មាត្រា ៤៥៩.-** បទដឹកនាំកុបកម្ម

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ អំពើដឹកនាំចលនាកុបកម្ម ។

**មាត្រា ៤៦០.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ដល់ជនបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ៤
## ការដណ្តើមយកអំណាចបញ្ជា និងការបង្កើតកងកម្លាំងប្រដាប់អាវុធ

**មាត្រា ៤៦១.-** បទដណ្តើមយកអំណាចបញ្ជាយោធា

អំពើដណ្តើមយកអំណាចបញ្ជាយោធា ដោយគ្មានសិទ្ធិ ឬ គ្មានការអនុញ្ញាតពីអាជ្ញាធរស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥(ដប់ប្រាំ) ឆ្នាំ ទៅ ៣០(សាមសិប) ឆ្នាំ ។

**មាត្រា ៤៦២.-** បទរក្សាទុកដោយខុសច្បាប់នូវអំណាចបញ្ជាយោធា

អំពើរក្សាទុកអំណាចបញ្ជាយោធា ប្រឆាំងនឹងបញ្ជារបស់អាជ្ញាធរស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ៤៦៣.-** បទបង្កើតដោយខុសច្បាប់នូវកម្លាំងប្រដាប់អាវុធ

អំពើបង្កើតកម្លាំងប្រដាប់អាវុធដោយគ្មានសិទ្ធិ ឬ គ្មានការអនុញ្ញាតពីអាជ្ញាធរស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ៤៦៤.-** បទញុះញង់ឱ្យប្រជាពលរដ្ឋកាន់អាវុធប្រឆាំងនឹងអាជ្ញាធរស្របច្បាប់

អំពើញុះញង់ដោយផ្ទាល់ឱ្យប្រជាពលរដ្ឋកាន់អាវុធប្រឆាំងនឹងអាជ្ញាធរស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



156/260

កាលបើការញុះញង់នេះបានសម្រេចផល បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ៤៦៥.-** បទញុះញង់ឱ្យប្រជាពលរដ្ឋកាន់អាវុធប្រឆាំងនឹងប្រជាពលរដ្ឋមួយផ្នែកទៀត

អំពើញុះញង់ដោយផ្ទាល់ ឱ្យប្រជាពលរដ្ឋកាន់អាវុធប្រឆាំងនឹងប្រជាពលរដ្ឋមួយផ្នែកទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

កាលបើការញុះញង់នេះបានសម្រេចផល បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ៤៦៦.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៤៦៧.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ជនជាតិបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
SECRETARIAT DU PALAIS ROYAL

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨(ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ៥
## ការប៉ះពាល់ដល់សន្តិសុខនៃកងយោធពលខេមរភូមិន្ទ

**មាត្រា ៤៦៨.-** បទញុះញង់ឱ្យយោធិនចូលបម្រើរដ្ឋបរទេស ឬ ភ្នាក់ងារបរទេស

អំពើញុះញង់ដោយផ្ទាល់ឱ្យយោធិននៃកងយោធពលខេមរភូមិន្ទចូលបម្រើរដ្ឋបរទេស ឬ ភ្នាក់ងារបរទេស ដើម្បីធ្វើឱ្យខូចខាតការការពារជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៤៦៩.-** បទរាំងដំណើរការជាធម្មតានៃសម្ភារៈយោធា

អំពើរាំងដំណើរការជាធម្មតានៃសម្ភារៈយោធា ដើម្បីធ្វើឱ្យខូចខាតការការពារជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤៧០.-** បទរាំងចលនានៃយោធិន ឬ សម្ភារៈយោធា

អំពើរាំងចលនានៃយោធិន ឬ សម្ភារៈយោធា ដើម្បីធ្វើឱ្យខូចខាតការការពារជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤៧១.-** បទញុះញង់កុំឱ្យយោធិនស្តាប់បង្គាប់

អំពើញុះញង់ដោយផ្ទាល់កុំឱ្យយោធិនស្តាប់បង្គាប់ ដើម្បីធ្វើឱ្យខូចខាតការការពារជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤៧២.-** បទធ្វើឱ្យខូចទឹកចិត្តកងទ័ព

អំពើចូលរួមក្នុងការធ្វើឱ្យខូចទឹកចិត្តកងទ័ព ដើម្បីធ្វើឱ្យខូចខាតការការពារជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤៧៣.-** បទចូលដោយទុច្ចរិតក្នុងទីលានយោធា

អំពើចូលដោយទុច្ចរិតទៅក្នុងទីលាន សំណង់ ឬ ឧបករណ៍ ដែលប្រគល់ទៅឱ្យអាជ្ញាធរយោធា ឬ ដែលស្ថិតនៅក្រោមការត្រួតត្រារបស់អាជ្ញាធរយោធា ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៤៧៤.-** បទរាំងដំណើរការនៃសេវាពាក់ព័ន្ធនឹងការការពារជាតិ

អំពើប្រព្រឹត្ត ដើម្បីធ្វើឱ្យខូចខាតការការពារជាតិ ដោយរាំងដំណើរការធម្មតានៃសេវា គ្រឹះស្ថាន ឬ សហគ្រាសសាធារណៈ ឬឯកជន ដែលមានប្រយោជន៍ដល់ការការពារជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ទៅ ៣(បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៤៧៥.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៤៧៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបាន

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០(ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ៦

## ការប៉ះពាល់ដល់ការសម្ងាត់នៃការការពារជាតិ

**មាត្រា ៤៧៧.—** គោលការណ៍នៃការការពារសម្ងាត់នៃការការពារជាតិ

[illegible]មាន វិធី វត្ថុ ឯកសារ សំណុំបត្រ ឬ ទិន្នន័យព័ត៌មានវិទ្យា ដែលការបើកកកាយ[illegible]ខាងការការពារជាតិ អាចជាកម្មវត្ថុនៃវិធានការការពារ សម្រាប់កម្រិតការ

ផ្សព្វផ្សាយ ។

បែបបទនៃការរៀបចំវិធានការការពារនេះ ត្រូវកំណត់ដោយរាជក្រឹត្យ ។

**មាត្រា ៤៧៨.-** និយមន័យនៃការសម្ងាត់នៃការការពារជាតិ

មានលក្ខណៈជាការសម្ងាត់នៃការការពារជាតិគឺ ព័ត៌មាន វិធី វត្ថុ ឯកសារ សណាកបត្រ ឬ ទិន្នន័យព័ត៌មានវិទ្យា ដែលការផ្សព្វផ្សាយត្រូវបានកម្រិត ។

**មាត្រា ៤៧៩.-** បទលាតត្រដាងដោយចេតនា ឬ អចេតនានូវការសម្ងាត់នៃការការពារជាតិ

អំពើរបស់បុគ្គលគ្រប់រូបដែលកាន់កាប់ព័ត៌មាន វិធី វត្ថុ ឯកសារ សណាកបត្រ ឬ ទិន្នន័យព័ត៌មានវិទ្យា ដែលមានលក្ខណៈជាការសម្ងាត់នៃការការពារជាតិ ដោយមូលហេតុនៃស្ថានភាពរបស់ខ្លួន មុខរបរ មុខងារ ឬ នៃបេសកកម្មរបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ប្រសិនបើបុគ្គលនេះ បង្ហាញការសម្ងាត់នេះដល់បុគ្គលគ្មានសមត្ថកិច្ចដើម្បីដឹងទេ ។

កាលបើការប៉ះពាល់ដល់ការសម្ងាត់នៃការការពារជាតិ កើតចេញពីការមិនប្រុងប្រយ័ត្ន ការធ្វេសប្រហែស ឬការមិនគោរពបទបញ្ជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៤៨០.-** បទកាន់កាប់ការសម្ងាត់នៃការការពារជាតិដោយគ្មានសមត្ថកិច្ច

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល អំពើរបស់បុគ្គលគ្មានសមត្ថកិច្ចដែលកាន់កាប់ដោយចេតនានូវព័ត៌មាន វិធី វត្ថុ ឯកសារ សណាកបត្រ ឬ ទិន្នន័យព័ត៌មានវិទ្យា ដែលមានលក្ខណៈជាការសម្ងាត់នៃការការពារជាតិ ។

**មាត្រា ៤៨១.-** បទបំផ្លិចបំផ្លាញ ឬ ចម្លងការសម្ងាត់នៃការការពារជាតិ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល អំពើបំផ្លិចបំផ្លាញ ឬ ចម្លងព័ត៌មាន វិធី វត្ថុ ឯកសារ សណាកបត្រ ឬ ទិន្នន័យព័ត៌មានវិទ្យាដែលមានលក្ខណៈជាការសម្ងាត់នៃការការពារជាតិ ។

**មាត្រា ៤៨២.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៤៨៣.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៣
## ការប៉ះពាល់ដល់សន្តិសុខសាធារណៈ
### ផ្នែកទី ១
### ក្រុមជនប្រដាប់អាវុធ

**មាត្រា ៤៨៤.-** និយមន័យនៃក្រុមជនប្រដាប់អាវុធ

ក្រុមជនប្រដាប់អាវុធ គឺជាក្រុមបុគ្គលមានកាន់កាប់អាវុធដែលមានការចាត់តាំងជាលំដាប់ថ្នាក់ និងដែលអាចនាំឱ្យប្រឡូកប្របល់ដល់សណ្តាប់ធ្នាប់សាធារណៈ ។

**មាត្រា ៤៨៥.-** បទចូលរួមក្នុងក្រុមជនប្រដាប់អាវុធ

ការចូលរួមក្នុងក្រុមជនប្រដាប់អាវុធ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ



163/264

Kol

ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៤៨៦.- បទរៀបចំចាត់តាំងក្រុមជនប្រដាប់អាវុធ**

អំពើរៀបចំចាត់តាំងក្រុមជនប្រដាប់អាវុធ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំទៅ ៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០(បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤៨៧.- ទោសបន្ថែម : ប្រភេទ និងរយៈពេល**

ចំពោះបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :,

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២
## បទល្មើសក្នុងវិស័យអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

**មាត្រា ៤៨៨.-** បទផលិត ឬ ធ្វើពាណិជ្ជកម្មអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ

ការផលិត ការនាំចូល ការនាំចេញ និងសន្និធិអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

អាវុធ សំដៅដល់កាំភ្លើងគ្រប់ប្រភេទដែលផលិត ឬ កែច្នៃតឡើង និងដែលអាចប្រើប្រាស់ដើម្បីសម្លាប់ ឬធ្វើឱ្យរបួស ឬធ្វើឱ្យប៉ះពាល់ខូចខាតដល់ទ្រព្យសម្បត្តិ ។

គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ សំដៅដល់ឧបករណ៍ ឬ សម្ភារៈដែលគេផលិត ឬ កែច្នៃ ដែលអាចប្រើប្រាស់សម្លាប់ ឬ ធ្វើឱ្យរបួស ឬ ធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិ ។

អាវុធគីមី អាវុធជីវសាស្ត្រគ្រប់ប្រភេទ ឬ គ្រាប់ផ្សេងទៀត ដែលផ្ទុកជាតិគីមី ផ្ទុកជីវសាស្ត្រ សំដៅដល់សារធាតុ ដែលគេផលិត ឬ កែច្នៃតឡើង និងដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាព អាយុជីវិត ឬ ទ្រព្យសម្បត្តិ និងបរិស្ថាន ។

**មាត្រា ៤៨៩.-** បទផលិត ឬ ធ្វើពាណិជ្ជកម្មអាវុធសម្រាប់ប្រហារផ្សេងទៀត

ការផលិត ការនាំចូល ការនាំចេញ និងសន្និធិអាវុធសម្រាប់ប្រហារផ្សេងទៀតដូចជា ចំពុះទុង ដាវ ស្នាប់ដៃ ជាអាទិ៍ សម្រាប់សម្លាប់ ឬ ធ្វើឱ្យរបួស ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៤៩០.-** បទកាន់កាប់ ឬ ដឹកជញ្ជូនអាវុធ ដោយគ្មានការអនុញ្ញាត

គ្រប់បុគ្គលដែលនៅក្រៅលំនៅឋានរបស់ខ្លួន យកតាមខ្លួន ឬ ដឹកជញ្ជូននូវអាវុធ គ្រឿងផ្ទុះ ឬ គ្រាប់រំសេវគ្រប់ប្រភេទ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ) ខែ ទៅ ៣(បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

ត្រូវផ្តន្ទាទោសដូចគ្នា គ្រប់បុគ្គលដែលនៅក្រៅលំនៅឋានរបស់ខ្លួន យកតាមខ្លួន ឬ ដឹកជញ្ជូនអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា ៤៨៩ (បទផលិត ឬ ធ្វើពាណិជ្ជកម្មអាវុធ

សម្រាប់ប្រហារផ្សេងទៀត) នៃក្រមនេះ ។

**មាត្រា ៤៩១.-** បទបោះបង់អាវុធក្នុងទីកន្លែងសាធារណៈ

អំពើបោះបង់អាវុធ ឬ វត្ថុដទៃទៀតដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់បុគ្គល នៅក្នុងទីកន្លែងសាធារណៈ ឬ ទីកន្លែងដែលសាធារណជនអាចចូលទៅបាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ) ខែ ទៅ ៣(បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៤៩២.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៦-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ ឬ គ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL



60/2641

ksl

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ៤៩៣.-** ការរឹបអូសក្នុងករណីមានការបោះបង់អាវុធក្នុងទីកន្លែងសាធារណៈ

ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៤៩១ (បទបោះបង់អាវុធក្នុងទីកន្លែងសាធារណៈ) នៃក្រមនេះ តុលាការអាចប្រកាសរឹបអូសអាវុធ ឬ វត្ថុដែលអាចនាំឱ្យមានគ្រោះថ្នាក់ចំពោះបុគ្គល ។

## ជំពូកទី ៣
## ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស

**មាត្រា ៤៩៤.-** លក្ខខណ្ឌអត្ថិភាពនៃការញុះញង់

ដើម្បីអនុវត្តផ្នែកនេះ ការញុះញង់អាចត្រូវផ្តន្ទាទោស កាលបើអំពើនេះត្រូវបានប្រព្រឹត្ត :

១-ដោយសំដីតាមប្រភេទណាក៏ដោយ ដែលប្រកាសនៅក្នុងទីកន្លែងសាធារណៈ ឬ នៅក្នុងពេលប្រជុំជាសាធារណៈ ។

២-ដោយសំណេរ ឬ គំនូរ តាមប្រភេទណាក៏ដោយ ដែលត្រូវផ្សព្វផ្សាយ នៅក្នុងចំណោមសាធារណជន ឬ តាំងឱ្យសាធារណជនមើល ។

៣-ដោយគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន ។

**មាត្រា ៤៩៥.-** បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍

អំពើញុះញង់ដោយផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬ ប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម តាមមធ្យោបាយណាមួយ ក្នុងចំណោមមធ្យោបាយដែលមានចែងនៅក្នុងមាត្រា ៤៩៤ (លក្ខខណ្ឌអត្ថិភាពនៃការញុះញង់) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាពទេ ។

**មាត្រា ៤៩៦.-** បទញុះញង់ឱ្យមានការរើសអើង

អំពើញុះញង់ដោយផ្ទាល់តាមមធ្យោបាយណាមួយ ដែលមានចែងក្នុងមាត្រា ៤៩៤ (លក្ខខណ្ឌអត្ថិភាពនៃការញុះញង់) នៃក្រមនេះ ឱ្យប្រព្រឹត្តការរើសអើង ការគុំកួន ឬ ហិង្សា ចំពោះបុគ្គលណាម្នាក់ ឬ ក្រុមណាមួយ ដោយមូលហេតុបុគ្គលនេះ ជាសមាជិក ឬ មិនមែនជាសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬ នៃសាសនាណាមួយជាកំណត់នោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាពទេ ។

**មាត្រា ៤៩៧.-** អំពើញុះញង់ប្រព្រឹត្តតាមផ្លូវសារព័ត៌មាន

បទល្មើសដែលមានចែងក្នុងផ្នែកនេះ ដែលប្រព្រឹត្តតាមផ្លូវសារព័ត៌មាន ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសារព័ត៌មាន ។

**មាត្រា ៤៩៨.-** ទោសបន្ថែម: ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៣-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ៥
## សមាគមជនទុច្ចរិត

**មាត្រា ៤៩៩.-** បទចូលរួមសមាគមនៃជនទុច្ចរិត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ការចូលរួមក្នុងក្រុម ឬសន្និធិភាពដែលត្រូវបង្កើតឡើងដើម្បី :

១-ប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ឬ ច្រើន ប្រឆាំងនឹងបុគ្គលដែលមានចែងនៅក្នុងជំពូកទី ១ ស្តីពីការប៉ះពាល់ដល់ជីវិតមនុស្ស ដល់ជំពូកទី ៦ ស្តីពីការប៉ះពាល់ដល់បុគ្គល-ភាព ក្នុងមាតិកាទី ២ ស្តីពីការប៉ះពាល់ដល់មនុស្ស នៃគន្ថីទី ២ ស្តីពីបទល្មើសប្រឆាំងនឹងបុគ្គល នៃក្រមនេះ ។

២-ប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ឬ ច្រើន ប្រឆាំងនឹងទ្រព្យសម្បត្តិ ដែលមានចែងនៅក្នុងគន្ថីទី ៣ ស្តីពីបទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិនៃក្រមនេះ ។

**មាត្រា ៥០០.-** ការលើកលែងឱ្យរួចផុតពីទោស

បុគ្គលណាដែលបានចូលរួមនៅក្នុងក្រុម ឬ សន្និធិភាព ត្រូវបានលើកលែងឱ្យរួចពីការទទួលទោស ប្រសិនបើមុនការចោទប្រកាន់ បុគ្គលនោះបានបង្ហាញពីក្រុម ឬ សន្និធិភាពដល់អាជ្ញាធរមានសមត្ថកិច្ច ហើយបាននាំឱ្យស្គាល់អត្តសញ្ញាណនៃអ្នកចូលរួមដទៃទៀត ។

**មាត្រា ៥០១.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយនូវគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៤
## ការប៉ះពាល់ដល់អាជ្ញាធររបស់រដ្ឋ
## ផ្នែកទោល
## ការប្រមាថ និងការប្រឆាំងនឹងអ្នករាជការសាធារណៈ

**មាត្រា ៥០២.-** បទប្រមាថ

ការប្រមាថ គឺជាវាចា កាយវិការ សំណេរ គំនូរ ឬវត្ថុដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរនៃបុគ្គល ។

ការប្រមាថចំពោះអ្នករាជការសាធារណៈ ឬ ចំពោះពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬ នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ថ្ងៃ ទៅ ៦ (ប្រាំមួយ) ថ្ងៃ និងពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

**មាត្រា ៥០៣.-** បទប្រឆាំងនឹងអ្នករាជការសាធារណៈ

ការប្រឆាំងនឹងអ្នករាជការសាធារណៈ គឺជាអំពើប្រឆាំងដោយប្រើការតទល់ដោយហិង្សា នឹងអ្នករាជការសាធារណៈដែលធ្វើសកម្មភាពដើម្បីអនុវត្តច្បាប់ បញ្ជារបស់អាជ្ញាធរសាធារណៈ ឬ សេចក្តីសម្រេចរបស់តុលាការ ។

បទប្រឆាំងនឹងអ្នករាជការសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ [illegible] ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំ

សែន) រៀល ។

**មាត្រា ៥០៤.-** ស្ថានទម្ងន់ទោសនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ

ការប្រឆាំងនឹងអ្នករាជការសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែទៅ ១(មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល នៅក្នុងករណីដូចតទៅ :

១-ការប្រឆាំងនឹងអ្នករាជការសាធារណៈ បានប្រព្រឹត្តដោយបុគ្គលច្រើនរូប ធ្វើសកម្មភាពក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬ ជាអ្នកសមគំនិត ។

២-ចារីមានអាវុធ ។

**មាត្រា ៥០៥.-** បទញុះញង់ឱ្យប្រព្រឹត្តអំពើប្រឆាំងនឹងអ្នករាជការសាធារណៈ

ការញុះញង់ដោយផ្ទាល់ឱ្យប្រព្រឹត្តអំពើប្រឆាំងនឹងអ្នករាជការសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ថ្ងៃ ទៅ ១(មួយ) ខែ និងពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

**មាត្រា ៥០៦.-** បទប្រឆាំងនឹងការអនុវត្តការងារសាធារណៈ

អំពើប្រឆាំងដោយហិង្សាទៅលើការអនុវត្តការងារសាធារណៈ ឬ ការងារដែលមានប្រយោជន៍ជាសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

**មាត្រា ៥០៧.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍

សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៥

## ការប៉ះពាល់ដល់សាសនារបស់រដ្ឋ

### ផ្នែកទី ១

### បទល្មើសប៉ះពាល់ដល់ព្រះពុទ្ធសាសនា

**មាត្រា ៥០៨.-** បទស្លៀកដណ្តប់បែបព្រះពុទ្ធសាសនាដោយគ្មានសិទ្ធិ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ) ថ្ងៃ ទៅ ៣(បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល អំពើស្លៀកដណ្តប់ជាសាធារណៈ ដោយគ្មានសិទ្ធិនឹងស្លៀកដណ្តប់នូវស្បង់ ចីពរ សម្រាប់អ្នកបួសក្នុងព្រះពុទ្ធសាសនា ។

**មាត្រា ៥០៩.-** បទលួចបូជនីយវត្ថុក្នុងព្រះពុទ្ធសាសនា

ដោយមិនទាន់គិតដល់ទោសធ្ងន់ជាងគេដែលមានចែងក្នុងក្រមនេះ ការលួចបូជនីយវត្ថុក្នុងព្រះពុទ្ធសាសនា ដែលប្រព្រឹត្តនៅក្នុងបូជនីយដ្ឋានសាសនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥១០.-** បទធ្វើឱ្យខូចខាតដល់បូជនីយដ្ឋានសាសនា ឬ បូជនីយវត្ថុក្នុងព្រះពុទ្ធសាសនា

ដោយមិនទាន់គិតដល់ទោសធ្ងន់ជាងគេដែលមានចែងក្នុងក្រមនេះ អំពើដែលប្រព្រឹត្តដោយចេតនាបំផ្លាញ ធ្វើឱ្យទ្រុឌទ្រោម ឬ ធ្វើឱ្យខូចខាតបូជនីយដ្ឋានដែលបូជាចំពោះព្រះពុទ្ធសាសនា ឬ បូជនីយវត្ថុក្នុងសាសនានេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥១១.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៥១២.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយនូវគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២

## បទល្មើសប្រឆាំងនឹងព្រះសង្ឃ ដូនជី និងតាជី

### កថាភាគទី ១

### អំពើហិង្សា

**មាត្រា ៥១៣.-** បទហិង្សាដោយចេតនា

អំពើហិង្សាដែលប្រព្រឹត្តដោយចេតនា ចំពោះព្រះសង្ឃ ដូនជី ឬ តាជី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥១៤.-** ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព

អំពើហិង្សាដែលប្រព្រឹត្តដោយចេតនា ចំពោះព្រះសង្ឃ ដូនជី ឬ តាជី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧(ប្រាំពីរ) ឆ្នាំ ទៅ ១៥(ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះនាំឱ្យមានការកាត់អវយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ ។

**មាត្រា ៥១៥.–** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

អំពើហិង្សាដែលប្រព្រឹត្តដោយចេតនា ចំពោះព្រះសង្ឃ ដូនជី ឬ តាជី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើនេះបណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់ ។

## កថាភាគទី ២

## ការប្រមាថ

**មាត្រា ៥១៦.–** បទប្រមាថចំពោះព្រះសង្ឃ ដូនជី និងតាជី

ការប្រមាថដូចបញ្ញត្តក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥០២ (បទប្រមាថ) នៃក្រមនេះ ដែលប្រព្រឹត្តឡើងចំពោះព្រះសង្ឃ ដូនជី ឬ តាជី នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬ ក្នុងឱកាសនៃការបំពេញមុខងារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ថ្ងៃ ទៅ ៦ (ប្រាំមួយ) ថ្ងៃ និងពិន័យជាប្រាក់ពី ១.០០០ (មួយពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

## មាតិកាទី ២

## ការប៉ះពាល់ដល់វិស័យយុត្តិធម៌

## ជំពូកទី ១

## ការប៉ះពាល់ដល់ស្ថាប័នយុត្តិធម៌

## ផ្នែកទី ១

## អំពើពុករលួយនៃចៅក្រម

**មាត្រា ៥១៧.–** បទស៊ីសំណូកប្រព្រឹត្តដោយចៅក្រម

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ អំពើរបស់ចៅក្រមដែលទទួលស៊ី ឬ យល់ព្រមដោយគ្មានសិទ្ធិ ដោយផ្ទាល់ ឬ ដោយប្រយោល ទទួលអំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍អ្វីមួយដើម្បី :

១-បំពេញកិច្ចនៅក្នុងមុខងាររបស់ខ្លួន ។

២-មិនបំពេញកិច្ចនៅក្នុងមុខងាររបស់ខ្លួន ។

ROYAUME DU CAMBODGE MINISTERE DU PALAIS ROYAL ក្រសួងព្រះបរមរាជវាំង

**មាត្រា ៥១៨.-** បទស្អកបានចំពោះចៅក្រម

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ បុគ្គលណាដោយគ្មានសិទ្ធិ ដោយផ្ទាល់ ឬ ដោយប្រយោល ប្រគល់ជូនចៅក្រមនូវអំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍អ្វីមួយ ដើម្បីឱ្យចៅក្រមនេះ :

១-បំពេញកិច្ចនៅក្នុងមុខងាររបស់ខ្លួន ។

២-មិនបំពេញកិច្ចនៅក្នុងមុខងាររបស់ខ្លួន ។

**មាត្រា ៥១៩.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៥១៨ (បទស្អកបានចំពោះចៅក្រម) នៃក្រមនេះ ។

នីតិបុគ្គល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចតទៅនេះ :

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ ។

២-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬ ច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤ (ការហាមឃាត់ចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យសន្សំសំចៃ) នៃក្រមនេះ ។

៦-ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះរាជហេត្ថលេខា
75/2011

១៧៩(ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៧-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និង មាត្រា ១៧៩(ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០(ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយនូវគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយនូវគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ផ្នែកទី ២
## ការប៉ះពាល់ដល់សេចក្តីសម្រេចរបស់តុលាការ

**មាត្រា ៥២០.–** បទបដិសេធការអនុវត្តសេចក្តីសម្រេចរបស់តុលាការ

អំពើរបស់អ្នករាជការសាធារណៈ ក្នុងមុខការរបស់ខ្លួន ដែលមិនព្រមអនុវត្តសាលដីកា សាលក្រម ដីកា ឬ រាល់បញ្ជារបស់អាជ្ញាធរតុលាការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥២១.–** បទផ្តល់ដោយខុសច្បាប់នូវបញ្ជាឱ្យឃុំ ឬ ដោះលែង

អំពើរបស់អ្នករាជការសាធារណៈ ឬ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលទោះបីក្រោមរូបភាពណាក៏ដោយ ចេញបញ្ជាដោយខុសច្បាប់ឱ្យឃុំ ឬ ឱ្យដោះលែងជនជាប់ឃុំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន)រៀល ។

**មាត្រា ៥២២.–** បទផ្សព្វផ្សាយនូវការអត្ថាធិប្បាយ ដើម្បីធ្វើសម្ពាធលើយុត្តាធិការ

ការផ្សព្វផ្សាយមុនសេចក្តីសម្រេចជាស្ថាពររបស់តុលាការនូវអត្ថាធិប្បាយ ដោយគោលដៅធ្វើការគាបសង្កត់ទៅលើតុលាការដែលទទួលបណ្តឹង ដើម្បីជះឥទ្ធិពលទៅ

លើសេចក្តីសម្រេចរបស់តុលាការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៥២៣.-** បទធ្វើឱ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ

អំពើរិះគន់លិខិត ឬ សេចក្តីសម្រេចរបស់តុលាការ ក្នុងគោលដៅបង្កឱ្យមានភាពវឹកវរដល់សណ្តាប់ធ្នាប់សាធារណៈ ឬ ក៏បង្កឱ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

អំពើដែលមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ ត្រូវផ្តន្ទាទោសដូចគ្នានឹងទោសដែលមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើ ។

**មាត្រា ៥២៤.-** បទប្តឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការ

អំពើដែលប្តឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការ ឬ អាជ្ញាធររដ្ឋបាលនូវអំពើជាបទល្មើស កាលបើការប្តឹងបរិហារនេះនាំឱ្យធ្វើការស្រាវជ្រាវដោយឥតប្រយោជន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៥២៥.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងមាត្រា ៥២០ (បទបដិសេធការអនុវត្តសេចក្តីសម្រេចរបស់តុលាការ) ដល់មាត្រា ៥២៤ (បទប្តឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៥២៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាង

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត

នៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៤-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៦-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២
## ការប៉ះពាល់ដល់សកម្មភាពរបស់តុលាការ
### ផ្នែកទី ១
### ការរាំងខ្ទប់តុលាការ

**មាត្រា ៥២៧.–** បទសម្លុតកុំឱ្យដាក់ពាក្យបណ្តឹង

អំពើគំរាមកំហែងសម្លុត ដើម្បីបង្ខំជនរងគ្រោះ កុំឱ្យដាក់ពាក្យបណ្តឹង ឬ ដកពាក្យបណ្តឹងរបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ប្រសិនបើបទល្មើសនេះ សម្តែងចេញជាលទ្ធផល ។

**មាត្រា ៥២៨.–** បទមិនប្តឹងបរិហារបទឧក្រិដ្ឋ ឬ បទមជ្ឈិមដោយអ្នករាជការសាធារណៈជាអាទិ៍ [illegible]ពីរបស់អ្នករាជការសាធារណៈ ឬ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការពោះ-[illegible] ដែលមិនបានប្តឹងបរិហារដល់អាជ្ញាធរតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត

ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលខ្លួនបានដឹងនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬ ក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៥២៩.-** បទមិនប្តឹងបរិហារបទឧក្រិដ្ឋ និងការលើកលែង

រាល់បុគ្គលណាដែលបានដឹងពីបទឧក្រិដ្ឋ ដែលអាចនឹងបង្ការ ឬ បន្ថយអានុភាពរបស់បទល្មើសបាន ហើយមិនប្តឹងបរិហារដល់អាជ្ញាធរតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

ប៉ុន្តែ ត្រូវបានលើកលែងឱ្យរួចផុតពីទោស :

១-បុព្វញាតិ និងបច្ឆាញាតិ បងប្អូនប្រុសស្រីរបស់ចារី សហចារី អ្នកផ្តើមគំនិត ឬ អ្នកសមគំនិតនៃបទឧក្រិដ្ឋ ។

២-សហព័ទ្ធរបស់ចារី សហចារី អ្នកផ្តើមគំនិត ឬ អ្នកសមគំនិតនៃបទឧក្រិដ្ឋ ។

៣-បុគ្គលដែលច្បាប់តម្រូវឱ្យរក្សាអាថ៌កំបាំងនៃវិជ្ជាជីវៈ ។

**មាត្រា ៥៣០.-** បទមិនប្តឹងបរិហារការធ្វើបាបអនីតិជន

រាល់បុគ្គលណាដែលបានដឹងពីការធ្វើបាប ឬការបៀតបៀនខាងផ្លូវភេទលើអនីតិជនអាយុក្រោម ១៥ (ដប់ប្រាំ) ឆ្នាំ ហើយមិនបានប្តឹងបរិហារដល់អាជ្ញាធរតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

## ផ្នែកទី ២

## ការស្រាវជ្រាវរកភស្តុតាង

**មាត្រា ៥៣១.-** បទលាក់បំបាំងសាកសព

អំពើដែលធ្វើឱ្យបាត់ ឬ លាក់បំបាំងសាកសពបុគ្គលណាម្នាក់ដែលរងគ្រោះពីបទមនុស្សឃាត ឬ ទទួលមរណភាពបន្ទាប់ពីអំពើហិង្សា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៦ (ប្រាំ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

មួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៣២.-** បទលាក់បំបាំងតម្រុយ

អំពើកែប្រែ លុបបំបាត់ ឬ លាក់បំបាំងតម្រុយ ឬ ស្លាកស្នាមនៅលើទីកន្លែងនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម ក្នុងគោលបំណងធ្វើជាឧបសគ្គដល់ការស្វែងរកឱ្យឃើញនូវការពិត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣(បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៥៣៣.-** បទលុបបំបាត់វត្ថុតាង

អំពើលុបបំបាត់ ឬ ផ្លាស់ប្តូរទីកន្លែង ឬ យកវត្ថុណាមួយក៏ដោយ នៅលើទីកន្លែងនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិមក្នុងគោលបំណងធ្វើជាឧបសគ្គដល់ការស្វែងរកឱ្យឃើញនូវការពិត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៥៣៤.-** បទបំផ្លិចបំផ្លាញឯកសារ

អំពើប្រព្រឹត្តដោយចេតនា បំផ្លិចបំផ្លាញ លួចយក ឬ កែប្រែឯកសារ ឬ វត្ថុអ្វីមួយដែលអាចនាំឱ្យមានការងាយស្រួលដល់ការរកឃើញបទឧក្រិដ្ឋ ឬ បទមជ្ឈិម ការរកឃើញអត្តសញ្ញាណនៃចោរី ឬ ការចាប់ខ្លួនចោរី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៥៣៥.-** បទបំផ្លាញស្លាកដែលបោះត្រា

អំពើបំផ្លាញស្លាកដែលបោះត្រាដោយអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២(ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៣៦.-** បទបំផ្លិចបំផ្លាញ ឬ កែបំបាត់វត្ថុដែលមានបិទស្លាកបោះត្រា

អំពើបំផ្លិចបំផ្លាញ ឬ កែបំបាត់វត្ថុដែលមានបិទស្លាកបោះត្រាដោយអាជ្ញាធរមានសមត្ថ-

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

កិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៣៧.-** បទបដិសេធការផ្តល់ចម្លើយ

រាល់បុគ្គលណាដែលបានប្រកាសជាសាធារណៈថា ខ្លួនស្គាល់ចារី សហចារី អ្នកផ្តើមគំនិត ឬ អ្នកសមគំនិតនៅក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិម ហើយប្រកែកមិនព្រមឆ្លើយនឹងសំណួរដែលចៅក្រមបានសួរពីរឿងនេះដល់ខ្លួននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៥៣៨.-** បទបដិសេធក្នុងការចូលខ្លួន

រាល់បុគ្គលណាដែលត្រូវបានកោះហៅឱ្យមកឆ្លើយជាសាក្សីនៅមុខអយ្យការ ឬ ចៅក្រមស៊ើបសួរ ឬ មុខតុលាការព្រហ្មទណ្ឌ ហើយមិនព្រមចូលខ្លួនតាមដីកាកោះហៅនោះដោយគ្មានមូលហេតុសមស្រប ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៥៣៩.-** បទមិនផ្តល់ភស្តុតាងនៃភាពគ្មានទោស និងការលើកលែង

រាល់បុគ្គលណាដែលមានភស្តុតាងបង្ហាញឱ្យឃើញភាពស្លូតត្រង់របស់ជនត្រូវចោទ ជនជាប់ចោទ ពិរុទ្ធជន ឬ ទណ្ឌិត ហើយមិនផ្តល់ភស្តុតាងនោះដល់អាជ្ញាធរតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតទេ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

ប៉ុន្តែ ត្រូវបានលើកលែងឱ្យរួចផុតពីទោស :

១-ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតនៃបទល្មើសដែលចោទប្រកាន់ ។

២-បុព្វញាតិ និងបច្ឆាញាតិ បងប្អូនប្រុសស្រីរបស់ចារី សហចារី អ្នកផ្តើមគំនិត ឬ អ្នកសមគំនិត ។

៣-សហព័ទ្ធរបស់ចារី សហចារី អ្នកផ្តើមគំនិត ឬ អ្នកសមគំនិត ។

៤-បុគ្គលដែលត្រូវរក្សាអាថ៌កំបាំងខាងវិជ្ជាជីវៈ ។

**មាត្រា ៥៤០.-** បទប្រើប្រាស់អត្តសញ្ញាណរបស់អ្នកដទៃ

អំពើយកឈ្មោះតតិយជនទៅក្នុងកាលៈទេសៈ ដែលនាំឱ្យមាន ឬ ដែលអាចនាំឱ្យមានការចោទប្រកាន់ខាងបទព្រហ្មទណ្ឌចំពោះតតិយជននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៥៤១.-** បទបដិសេធមិនស្តាប់បង្គាប់បញ្ជា

អ្នកបើកបរយានជំនិះណាមួយ ដែលមិនព្រមស្តាប់បង្គាប់បញ្ជាឱ្យឈប់របស់នគរបាល ឬ កងរាជអាវុធហត្ថដែលមានឯកសណ្ឋាន ឬ សញ្ញាសម្គាល់យ៉ាងច្បាស់របស់នគរបាល ឬ កងរាជអាវុធហត្ថ ដើម្បីស្វែងរកភស្តុតាង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

**មាត្រា ៥៤២.-** បទបដិសេធរបស់អ្នកបើកបរក្នុងការទទួលការពិនិត្យ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល អ្នកបើកបរយានជំនិះណាមួយ ដែលមិនព្រមដាក់ខ្លួនឱ្យធ្វើការត្រួតពិនិត្យលើយាន ឬលើខ្លួនទេ កាលបើការត្រួតពិនិត្យនេះ ត្រូវបានធ្វើឡើងដើម្បីស្វែងរកភស្តុតាងដោយនគរបាល ឬ កងរាជអាវុធហត្ថ ដែលមានឯកសណ្ឋាន ឬ សញ្ញាសម្គាល់យ៉ាងច្បាស់របស់នគរបាល ឬ កងរាជអាវុធហត្ថនោះ ។

**មាត្រា ៥៤៣.-** បទរត់គេចខ្លួន

អំពើប្រព្រឹត្តដោយអ្នកបើកបរយានជំនិះផ្លូវគោក ឬ ផ្លូវទឹកដែលបានដឹងច្បាស់ថា ខ្លួនទើបតែបង្កឱ្យមានគ្រោះថ្នាក់ ឬ ការខូចខាត ហើយមិនព្រមឈប់ ដើម្បីគេចខ្លួនពីការទទួលខុសត្រូវព្រហ្មទណ្ឌ ឬ រដ្ឋប្បវេណី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៥៥៤.-** បទផ្តល់ជំនួយដល់ចារី ជាអាទិ៍ និងការលើកលែង

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល អំពើដែលផ្តល់ឱ្យចារី សហចារី អ្នកផ្តើមគំនិត ឬ អ្នកសមគំនិតក្នុងបទឧក្រិដ្ឋនូវ :

១-ទីលំនៅ ។

២-ទីកន្លែងលាក់ខ្លួន ។

៣-មធ្យោបាយសម្រាប់ការរស់នៅ ។

៤-គ្រប់មធ្យោបាយដែលអាចនាំឱ្យមានការងាយស្រួលក្នុងការគេចខ្លួន ឬ ក៏ឱ្យជននោះគេចផុតពីការស្រាវជ្រាវ ។

ប៉ុន្តែ ត្រូវបានលើកលែងឱ្យរួចផុតពីទោស :

១-បុព្វញាតិ និងបច្ឆាញាតិ បងប្អូនប្រុសស្រីរបស់ចារី សហចារី អ្នកផ្តើមគំនិត ឬ អ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ។

២-សហព័ទ្ធរបស់ចារី សហចារី អ្នកផ្តើមគំនិត ឬ អ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ។

**មាត្រា ៥៥៥.-** បទផ្តល់សក្ខីកម្មក្លែងក្លាយ និងការលើកលែង

សក្ខីកម្មភូតកុហក ដែលធ្វើក្រោយពីបានស្បថនៅមុខតុលាការ ឬ នៅមុខមន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើសកម្មភាពនៅក្នុងក្របខ័ណ្ឌនៃដីកាចាត់ឱ្យសួរចម្លើយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

សាក្សីភូតកុហក ត្រូវបានលើកលែងឱ្យរួចផុតពីទោស ប្រសិនបើសាក្សីនេះ ប្រែក្រឡាស់ដោយឯកឯងនូវសក្ខីកម្មរបស់ខ្លួន ហើយនិយាយតែការពិតមុនសេចក្តីសម្រេចបញ្ចប់នីតិវិធីស៊ើបសួរ ឬ នីតិវិធីជំនុំជម្រះ ។

**មាត្រា ៥៥៦.-** បទសម្លុតសាក្សី

គ្រប់អំពើសម្លុត ដែលប្រព្រឹត្តដោយចារីតែម្នាក់ឯង ឬ ដោយមានការព្រមព្រៀងជាមួយតតិយជន ដើម្បីញុំាងឱ្យសាក្សីកុំឆ្លើយ ឬ ឱ្យផ្តល់ដោយផ្ទាល់មាត់ ឬ ដោយលាយលក្ខណ៍អក្សរនូវសក្ខីកម្មភូតកុហក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

LE MINISTRE du PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង
183/LCY



kol

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ប្រសិនបើបទល្មើសនេះ សម្តែងចេញជាលទ្ធផល ។

**មាត្រា ៥៤៧.-** បទស៊ីសំណូករបស់សាក្សី ដើម្បីធ្វើសក្ខីកម្មក្លែងក្លាយ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ អំពើរបស់សាក្សីណាដែលទទូចសុំ ឬ យល់ព្រមទទួលយកដោយផ្ទាល់ ឬ ប្រយោលនូវអំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍អ្វីមួយ ដើម្បី :

១-មិនធ្វើជាសាក្សី ។

២-ផ្តល់សក្ខីកម្មភូតកុហក ។

**មាត្រា ៥៤៨.-** បទសូកប៉ាន់សាក្សី

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ រាល់បុគ្គលណាដែលប្រគល់ឱ្យ សាក្សីដោយផ្ទាល់ ឬ ប្រយោល នូវអំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍អ្វីមួយ ដើម្បី :

១-មិនធ្វើជាសាក្សី ។

២-ផ្តល់សក្ខីកម្មភូតកុហក ។

**មាត្រា ៥៤៩.-** បទផ្សព្វផ្សាយក្នុងគោលបំណងធ្វើការគាបសង្កត់លើសាក្សី

ការផ្សព្វផ្សាយមុនសេចក្តីសម្រេចស្ថាពររបស់តុលាការនូវអត្ថាធិប្បាយដែលមានគោលបំណងធ្វើការគាបសង្កត់លើសាក្សីដើម្បីជះឥទ្ធិពលទៅលើសក្ខីកម្មរបស់សាក្សីនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ១ (មួយ) ខែ និងពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

## ផ្នែកទី ៣
## ការបកប្រែ និងកោសលវិច័យ

**មាត្រា ៥៥០.-** បទបំភ្លៃដោយអ្នកបកប្រែ

អំពើប្រព្រឹត្តដោយអ្នកបកប្រែ ដែលបំភ្លៃដោយចេតនានូវខ្លឹមសារនៃភាសា ឬ ឯកសារដែលខ្លួនបកប្រែ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យ

ជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥៥១.-** បទក្លែងដោយអ្នកជំនាញ

អំពើប្រព្រឹត្តដោយអ្នកជំនាញ ដែលក្លែងនៅក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សរ ឬ សេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់នូវទិន្នន័យ ឬ លទ្ធផលនៃកោសល្យវិច័យ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥៥២.-** បទសម្លុតអ្នកជំនាញ ឬ អ្នកបកប្រែ

គ្រប់អំពើសម្លុតអ្នកជំនាញ ឬ អ្នកបកប្រែ ដើម្បីជះឥទ្ធិពលទៅលើការប្រព្រឹត្តរបស់បុគ្គលនេះនៅក្នុងការបំពេញមុខងាររបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ប្រសិនបើបទល្មើសនេះសម្តែងចេញជាលទ្ធផល ។

**មាត្រា ៥៥៣.-** បទស៊ីសំណូករបស់អ្នកបកប្រែ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ អំពើរបស់អ្នកបកប្រែដែលទទួចសុំ ឬ យល់ព្រមទទួលដោយផ្ទាល់ ឬ ដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍អ្វីមួយ ដើម្បីក្លែងខ្លឹមសារនៃភាសា ឬ ឯកសារដែលបកប្រែ ។

**មាត្រា ៥៥៤.-** បទសូកប៉ាន់អ្នកបកប្រែ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ រាល់បុគ្គលណាដែលប្រគល់ឱ្យអ្នកបកប្រែដោយផ្ទាល់ ឬដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍អ្វីមួយ ដើម្បីក្លែងខ្លឹមសារនៃភាសា ឬ ឯកសារដែលបកប្រែ ។

**មាត្រា ៥៥៥.-** បទស៊ីសំណូករបស់អ្នកជំនាញ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ អំពើរបស់អ្នកជំនាញដែលទទួចសុំ ឬ យល់ព្រមទទួលដោយផ្ទាល់ ឬ ដោយប្រយោលនូវអំណោយ ជំនូន ការសន្យា

ឬ អត្ថប្រយោជន៍អ្វីមួយ ដើម្បីថ្លែងនៅក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សរ ឬ សេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់របស់ខ្លួននូវទិន្នន័យ ឬ លទ្ធផលនៃកោសល្យវិច័យ ។

**មាត្រា ៥៥៦.-** បទសូកប៉ាន់អ្នកជំនាញ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ រាល់បុគ្គលណាដែលប្រគល់ឱ្យអ្នកជំនាញដោយផ្ទាល់ ឬ ដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍អ្វីមួយ ដើម្បីថ្លែងនៅក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សរ ឬ សេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់របស់ខ្លួននូវទិន្នន័យ ឬ លទ្ធផលនៃកោសល្យវិច័យ ។

## ផ្នែកទី ៤
## ការប៉ុនប៉ង និងទោសបន្ថែម

**មាត្រា ៥៥៧.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងក្នុងមាត្រា ៥២៧ (បទសម្លុតកុំឱ្យដាក់ពាក្យបណ្តឹង) មាត្រា ៥៣១ (បទលាក់បំបាំងសាកសព) មាត្រា ៥៣៦ (បទបំផ្លិចបំផ្លាញ ឬ កែបំពាត់វត្ថុដែលមានបិទស្លាកបោះត្រា) មាត្រា ៥៤០ (បទប្រើប្រាស់អត្តសញ្ញាណរបស់អ្នកដទៃ) និង មាត្រា ៥៤៤ (បទផ្តល់ជំនួយដល់ចារីជាអាទិ៍ និងការលើកលែង) នៃក្រមនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៥៥៨.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



Ksl

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៦-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

***មាត្រា ៥៥៩.-*** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៥៤៨(បទស្តុកបាំងសាក្សី) មាត្រា ៥៥៤(បទស្តុកបាំងអ្នកបកប្រែ) និងមាត្រា ៥៥៦(បទស្តុកបាំងអ្នកជំនាញ) នៃក្រមនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ២០០.០០០.០០០ (ពីររយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើនដូចតទៅនេះ :

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០(ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ ។

២-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬ ច្រើន តាមបែបបទកំណត់

ROYAUME DU CAMBODGE * LE MINISTRE du PALAIS ROYAL *

ដោយមាត្រា ១៧២(ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា ១៧៣(ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤(ការហាមឃាត់ចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) នៃក្រមនេះ ។

៦-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨(ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩(ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៧-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨(ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩(ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០(ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ជំពូកទី ៣
## បទល្មើសទាក់ទងដល់ការឃុំឃាំង
### ផ្នែកទី ១
### ការលួចរត់

**មាត្រា ៥៦០.-** និយមន័យនៃការលួចរត់

ការលួចរត់ គឺជាអំពើរបស់ជនជាប់ឃុំ ដែលលួចរត់ចេញពីការឃុំខ្លួន តាមគ្រប់មធ្យោ-

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ការលួចរត់ចេញពីទីឃុំឃាំងត្រូវចាត់ទុកថា គ្រប់លក្ខណៈដែរ ទោះបីជាមធ្យោបាយខាងលើនេះ ជាអំពើរបស់តតិយជនក៏ដោយ ។

ត្រូវចាត់ទុកថាជាជនជាប់ឃុំគឺ :

១-បុគ្គលដែលគេឃាត់ខ្លួនទុក ។

២-បុគ្គលដែលគេហៀបនឹងនាំទៅបង្ហាញខ្លួន ឬ កំពុងតែនាំទៅបង្ហាញខ្លួនដល់អាជ្ញាធរតុលាការក្រោយពីការឃាត់ខ្លួន ឬ ដោយអនុវត្តដីកានាំខ្លួន ឬ ឱ្យចាប់ខ្លួន ។

៣-បុគ្គលដែលបានទទួលលិខិតឱ្យដំណឹងពីដីកាឱ្យឃុំ ឬ ឱ្យចាប់ខ្លួន ។

៤-បុគ្គលដែលអនុវត្តទោសដាក់ពន្ធនាគារ ឬ ដែលត្រូវគេចាប់ខ្លួន ដើម្បីអនុវត្តទោសនេះ ។

៥-បុគ្គលដែលត្រូវគេឃុំខ្លួននៅក្នុងក្របខ័ណ្ឌនៃនីតិវិធីបត្យាប័ន ។

៦-ជនដែលស្ថិតក្នុងរបបពាក់កណ្ដាលសេរីភាពតាមបញ្ញត្តិនៃមាត្រា ១២៧ (លក្ខខណ្ឌនៃរបបពាក់កណ្ដាលសេរីភាព) នៃក្រមនេះ ។

**មាត្រា ៥៦១.-** ទោសដែលត្រូវអនុវត្ត

អំពើលួចរត់ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៥៦២.-** អំពើដែលប្រដូចទៅនឹងអំពើលួចរត់

ត្រូវចាត់ទុកថាជាអំពើលួចរត់ និងត្រូវផ្ដន្ទាទោសដូចគ្នា :

១-អំពើរបស់ជនជាប់ឃុំដែលត្រូវបានដាក់នៅក្នុងគ្រឹះស្ថានសុខាភិបាល ឬ មន្ទីរពេទ្យ ឬ ទីកន្លែងផ្សេងទៀត ដូចជា តុលាការ អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថជាអាទិ៍ ដែលគេចខ្លួនចេញពីការតាមឃ្លាំមើល ។

២-អំពើរបស់ទណ្ឌិតដែលបានទទួលរបបពាក់កណ្ដាលសេរីភាព របបព្យួរទោស ឬ របបបែងជាប្រភាគនៃទោស ឬ នៃការអនុញ្ញាតឱ្យចេញក្រៅពន្ធនាគារ ហើយមិនវិលត្រឡប់មកពន្ធនាគារវិញ នៅពេលផុតរយៈកាលនៃសេរីភាព ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *



Kol

## ផ្នែកទី ២

## ស្ថានទម្ងន់ទោសនៃអំពើលួចរត់ និងការជួយសម្រួលដល់ការលួចរត់

**មាត្រា ៥៦៣.–** បទគំរាមកំហែងដោយអាវុធឬដោយសកម្មភាពដែលមានការព្រមព្រៀង

អំពើលួចរត់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើនេះបានប្រព្រឹត្តនៅក្នុងកាលៈទេសៈណាមួយដូចខាងក្រោម :

១-ដោយមានការគំរាមកំហែងដោយអាវុធ ឬដោយសារជាតិផ្ទុះ ។

២-នៅក្នុងក្របខ័ណ្ឌនៃសកម្មភាពព្រមព្រៀងគ្នារវាងជនជាប់ឃុំច្រើននាក់ ។

**មាត្រា ៥៦៤.–** បទប្រើប្រាស់អាវុធ

អំពើលួចរត់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើមានប្រើប្រាស់អាវុធ ឬ សារជាតិផ្ទុះ ។

**មាត្រា ៥៦៥.–** បទផ្តល់មធ្យោបាយលួចរត់

អំពើផ្តល់ឱ្យជនជាប់ឃុំនូវគ្រប់មធ្យោបាយសម្រាប់លួចរត់ ឬ សម្រាប់សម្រួលការលួចរត់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៥៦៦.–** ស្ថានទម្ងន់ទោសនៃអំពើផ្តល់នូវមធ្យោបាយលួចរត់

អំពើផ្តល់ឱ្យជនជាប់ឃុំនូវអាវុធ សារជាតិផ្ទុះ សារជាតិបង្កអគ្គិភ័យ សារជាតិពុល ឬ អាស៊ីដ ដើម្បីប្រើប្រាស់ជាមធ្យោបាយសម្រាប់លួចរត់ ឬ សម្រាប់សម្រួលការលួចរត់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥៦៧.–** បទជួយសម្រួលដល់ការលួចរត់ដោយអ្នកត្រួតពិនិត្យ

អំពើរបស់បុគ្គលទទួលភារកិច្ចខាងការថែរក្សាដែលសម្រួល ឬ រៀបចំឱ្យជនជាប់ឃុំរត់ចេញ ទោះតាមអំពើអកម្មដោយចេតនាក៏ដោយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៥៦៨.-** ស្ថានទម្ងន់ទោសនៃអំពើជួយសម្រួលដល់ការលួចរត់ដោយអ្នកត្រួតពិនិត្យ

អំពើរបស់បុគ្គលទទួលភារកិច្ចខាងការថែរក្សា ដែលផ្តល់ឱ្យជនជាប់ឃុំនូវអាវុធ សារ-ជាតិផ្ទុះ សារជាតិបង្កអគ្គិភ័យ សារជាតិពុល ឬអាស៊ីដ ដើម្បីប្រើប្រាស់ជាមធ្យោបាយសម្រាប់លួចរត់ ឬសម្រាប់សម្រួលការលួចរត់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ៥៦៩.-** បទជួយសម្រួលការលួចរត់ប្រព្រឹត្តដោយបុគ្គលទទួលនីតិសម្បទាឱ្យចូលទៅក្នុងពន្ធនាគារ

អំពើរបស់បុគ្គលទទួលនីតិសម្បទាឱ្យចូលទៅក្នុងពន្ធនាគារ ដែលសម្រួល ឬរៀបចំឱ្យជនជាប់ឃុំរត់ចេញ ទោះតាមអំពើអកម្មដោយចេតនាក៏ដោយ ត្រូវផ្តន្ទាទោសដាក់ពន្ធនា-គារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៥៧០.-** ស្ថានទម្ងន់ទោសនៃអំពើជួយសម្រួលដល់ការលួចរត់ប្រព្រឹត្តដោយបុគ្គលទទួលនីតិសម្បទាឱ្យចូលទៅក្នុងពន្ធនាគារ

អំពើរបស់បុគ្គលទទួលនីតិសម្បទាឱ្យចូលទៅក្នុងពន្ធនាគារ ដែលផ្តល់ឱ្យជនជាប់ឃុំនូវអាវុធ សារជាតិផ្ទុះ សារជាតិបង្កអគ្គិភ័យ សារជាតិពុល ឬអាស៊ីដ ដើម្បីប្រើប្រាស់ជាមធ្យោបាយសម្រាប់លួចរត់ ឬសម្រាប់សម្រួលការលួចរត់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

## ផ្នែកទី ៣

## ការប្រគល់ដោយខុសច្បាប់នូវទឹកប្រាក់ និងវត្ថុដល់ជនជាប់ឃុំ

**មាត្រា ៥៧១.-** បទប្រគល់ដោយខុសច្បាប់ និងស្ថានទម្ងន់ទោស

អំពើប្រគល់ ឬផ្ញើឱ្យដល់ជនជាប់ឃុំនូវទឹកប្រាក់ លិខិតឆ្លើយឆ្លង វត្ថុ ឬសារជាតិអ្វីមួយ ក្រៅពីករណីដែលបានអនុញ្ញាតដោយបទបញ្ជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

បទល្មើសខាងលើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល កាលបើបទល្មើសនេះត្រូវបានប្រព្រឹត្តដោយ :

១-បុគ្គលទទួលបន្ទុកខាងការថែរក្សាជនជាប់ឃុំ ។

២-បុគ្គលទទួលនីតិសម្បទាឱ្យចូលទៅក្នុងពន្ធនាគារ ។

**មាត្រា ៥៧២.-** បទទទួលដោយខុសច្បាប់ និងស្ថានទម្ងន់ទោស

អំពើទទួលពីជនជាប់ឃុំនូវទឹកប្រាក់ លិខិតឆ្លើយឆ្លង វត្ថុ ឬ សារជាតិអ្វីមួយ ក្រៅពីករណីដែលបានអនុញ្ញាតដោយបទបញ្ជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

បទល្មើសខាងលើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល កាលបើបទល្មើសនេះត្រូវបានប្រព្រឹត្តដោយ :

១-បុគ្គលទទួលបន្ទុកខាងការថែរក្សាជនជាប់ឃុំ ។

២-បុគ្គលទទួលនីតិសម្បទាឱ្យចូលទៅក្នុងពន្ធនាគារ ។

## ផ្នែកទី ៤
## ការប៉ុនប៉ង និងឧបពន្ធកម្ម

**មាត្រា ៥៧៣.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៥៧៤.-** ការលើកលែងឱ្យរួចផុតពីទោស

រាល់បុគ្គលណា ក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬ ជាអ្នកសមគំនិតដែលប៉ុនប៉ងប្រព្រឹត្តបទល្មើសណាមួយដែលកំណត់នៅក្នុងមាត្រា ៥៦១ (ទោសដែលត្រូវអនុវត្ត) មាត្រា ៥៦៣ (បទគំរាមកំហែងដោយអាវុធ ឬ ដោយសកម្មភាពដែលមានការព្រមព្រៀង) និងមាត្រា ៥៧០ (ស្ថានទម្ងន់ទោសនៃអំពើជួយសម្រួលការលួចរត់ប្រព្រឹត្តដោយ

បុគ្គលទទួលជីតិសម្បទាឱ្យចូលទៅក្នុងពន្ធនាគារ) នៃក្រមនេះ នឹងត្រូវលើកលែងឱ្យរួចផុតពីទោស ប្រសិនបើបុគ្គលនេះបានឱ្យដំណឹងដល់អាជ្ញាធរតុលាការ ឬ អាជ្ញាធររដ្ឋបាល ដើម្បីកុំឱ្យការលួចរត់នេះបានសម្រេចលទ្ធផល ។

**មាត្រា ៥៧៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្ត បទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៦-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយនូវគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ៤

## ការបំពានលើសេចក្តីសម្រេចខ្លះៗ របស់តុលាការ

**មាត្រា ៥៧៦.-** បទបំពានលើបម្រាមស្នាក់នៅ

អំពើរបស់ជនដែលត្រូវហាមឃាត់ចំពោះការស្នាក់នៅ ដែលបញ្ញត្តដោយអាជ្ញាធរតុលាការ ហើយមានមុខនៅទីកន្លែងដែលគេហាមឃាត់ដល់ខ្លួននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៧៧.-** បទមិនគោរពតាមវិធានការត្រួតពិនិត្យ

អំពើរបស់ជនដែលត្រូវហាមឃាត់ចំពោះការស្នាក់នៅ ដែលគេចវេះពីវិធានការត្រួតពិនិត្យ ដែលបញ្ញត្តដោយអាជ្ញាធរតុលាការ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៧៨.-** បទបំពានលើទោសបិទផ្សាយ

នៅក្នុងករណីដែលទោសបិទផ្សាយសេចក្តីសម្រេចរបស់តុលាការ ត្រូវបានប្រកាស អំពើបំបាត់ចោល លាក់បំបាំង ឬ ហែកចោលបណ្ណប្រកាស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

**មាត្រា ៥៧៩.-** បទបំពានលើទោសហាមឃាត់ផ្នែកវិជ្ជាជីវៈ

នៅក្នុងករណីដែលទោសហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ ត្រូវបានប្រកាសដោយអាជ្ញាធរតុលាការ អំពើបំពានលើការហាមឃាត់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៨០.-** បទបំពានលើទោសដែលកម្រិតសិទ្ធិខ្លះ

អំពើការបំពានដោយចេតនាទៅលើកាតព្វកិច្ច ឬ ការហាមឃាត់ ដែលជាលទ្ធផលនៃទោសព្យួរប័ណ្ណបើកបរ ទោសហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ

គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ទោសហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ទោសបិទទ្វារគ្រឹះស្ថាន ឬ ទោសបណ្តេញចេញពីលទ្ធកម្មសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៨១.-** បទមិនគោរពការរឹបអូស

អំពើបំផ្លិចបំផ្លាញ លាក់បំបាំង ឬ កែបំបាត់វត្ថុរឹបអូស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៨២.-** បទបដិសេធប្រគល់លិខិតបើកបរ

អំពើមិនព្រមប្រគល់ឱ្យដល់អាជ្ញាធរមានសមត្ថកិច្ច នូវលិខិតបើកបរដែលត្រូវព្យួរ ឬ វត្ថុដែលត្រូវរឹបអូសនោះ ដោយមិនគោរពតាមសេចក្តីសម្រេចរបស់តុលាការ ដែលមានអានុភាពអនុវត្ត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៨៣.-** បទបំពានលើកាតព្វកិច្ចការងារសហគមន៍

អំពើបំពានដោយទណ្ឌិតលើកាតព្វកិច្ច ដែលជាលទ្ធផលនៃទោសការងារសហគមន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ទៅ ២(ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៨៤.-** បទបំពានលើកាតព្វកិច្ចដែលប្រកាសទៅលើនីតិបុគ្គល

កាលបើកាតព្វកិច្ច ឬ ការហាមឃាត់ត្រូវបានប្រកាសទៅលើនីតិបុគ្គល ការបំពានដោយរូបវន្តបុគ្គលដែលត្រូវអនុវត្តកាតព្វកិច្ច ឬ ការហាមឃាត់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន)រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៥៨៥.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបាន

១-ការដកសិទ្ធិខ្លះជាពលរដ្ឋជាស្ថាពរ ឬ សម្រាប់រយៈពេល ៥(ប្រាំ)ឆ្នាំយ៉ាងច្រើន ។

២-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៣-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## មាតិកាទី ៣

## ការប៉ះពាល់ដល់ដំណើរការរបស់រដ្ឋបាលសាធារណៈ

### ជំពូកទី ១

### ការប៉ះពាល់ដល់រដ្ឋបាលសាធារណៈ ដោយអ្នកតំណាងអាជ្ញាធរសាធារណៈ

#### ផ្នែកទី ១

#### ការមិនគោរពភារកិច្ច

##### កថាភាគទី ១

##### ការរំលោភអំណាច

**មាត្រា ៥០៦.-** បទចាត់វិធានការសំដៅរារាំងការអនុវត្តច្បាប់ និងស្ថានទម្ងន់ទោស

អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬ ដោយពលរដ្ឋទទួលអាណត្តិសាធារណៈ ដោយការបោះឆ្នោតនៅក្នុងក្របខណ្ឌនៃមុខងារៈ ឬ នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ចាត់វិធានការសម្រាប់រារាំងការអនុវត្តច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ) ឆ្នាំ ទៅ ១០(ដប់) ឆ្នាំ ប្រសិនបើបទល្មើសនេះសម្តែងចេញជាលទ្ធផល ។

**មាត្រា ៥០៧.-** បទបន្តអនុវត្តមុខងារដោយខុសច្បាប់

អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬ ដោយពលរដ្ឋទទួលអាណត្តិសាធារណៈ ដោយការបោះឆ្នោត ដែលនៅតែបន្តបំពេញមុខងាររបស់ខ្លួន នៅពេលដែលមុខងារ



ត ទៅរាជកិច្ចលេខ ៤

នេះ ត្រូវបានបញ្ចប់ហើយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

## កថាភាគទី ២
## ការរំលោភអំណាចប្រឆាំងនឹងបុគ្គល

**មាត្រា ៥៨៨.–** បទប៉ះពាល់ដល់សេរីភាពបុគ្គល

អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬ ដោយពលរដ្ឋទទួលអាណត្តិសាធារណៈ ដោយការបោះឆ្នោតនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬ នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន នៅតែបំពេញដោយខុសច្បាប់នូវកិច្ចការដែលប៉ះពាល់ដល់សេរីភាពបុគ្គល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៥៨៩.–** បទមិនព្រមដោះលែងបុគ្គលដែលត្រូវបានឃុំដោយខុសច្បាប់

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬ ដោយពលរដ្ឋទទួលអាណត្តិសាធារណៈ ដោយការបោះ-ឆ្នោតដែលបានដឹងនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬ នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួននូវការដកហូតសេរីភាពដោយខុសច្បាប់ ហើយនៅតែមិនព្រមបញ្ចប់ដោយចេតនានូវការដកហូតសេរីភាពនេះទេ ប្រសិនបើខ្លួនជាអ្នកមានអំណាចដើម្បីបញ្ចប់ការដកហូតសេរីភាពនេះ ឬ មិនព្រមសុំឱ្យមានអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច ។

**មាត្រា ៥៩០.–** បទឃុំ ឬ ដោះលែងដោយខុសច្បាប់

អំពើរបស់ភ្នាក់ងាររដ្ឋបាលពន្ធនាគារដែលទទួលឃុំខ្លួន ឬ ដោះលែងបុគ្គលណាមួយដោយគ្មានដីកា សាលដីកា សាលក្រមបញ្ជាឱ្យឃុំខ្លួន ឬ ឱ្យដោះលែង ដែលធ្វើឡើងស្របច្បាប់ទេនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៥៩១.-** បទអូសបន្លាយការឃុំខ្លួនដោយខុសច្បាប់

អំពើរបស់ភ្នាក់ងាររដ្ឋបាលពន្ធនាគារ ដែលពន្យារដោយខុសច្បាប់នូវរយៈពេលនៃការឃុំខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

## ផ្នែកទី ២

## អំពើពុករលួយ និងបទល្មើសប្រហាក់ប្រហែល

### កថាភាគទី ១

### វិតិក្រម

**មាត្រា ៥៩២.-** និយមន័យនៃវិតិក្រម

វិតិក្រម គឺជាអំពើរបស់អ្នករាជការសាធារណៈ ឬ ពលរដ្ឋទទួលអាណត្តិសាធារណៈ ដោយការបោះឆ្នោត ដែល :

១-ទាមទារ ឬ ទទួល ជាសិទ្ធិ ជាពន្ធ ជាអាករ នូវចំនួនប្រាក់ដែលខ្លួនបានដឹងថាមិនត្រូវបង់ ឬ ដែលលើសពីចំនួនដែលគេត្រូវបង់ ។

២-យល់ព្រមក្រោមរូបភាពណាមួយ និងដោយមូលហេតុណាមួយក៏ដោយ ធ្វើការលើកលែង ឬ ការលោះលាចំពោះការបង់ពន្ធ ឬ អាករដែលខ្លួនដឹងថាខុសច្បាប់។

**មាត្រា ៥៩៣.-** ទោសដែលត្រូវអនុវត្ត

បទវិតិក្រម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

### កថាភាគទី ២

### អំពើស៊ីសំណូក

**មាត្រា ៥៩៤.-** បទស៊ីសំណូក

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ អំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬ ដោយពលរដ្ឋទទួលអាណត្តិសាធារណៈ ដោយការបោះឆ្នោត ដែលទទូចសុំ ឬ យល់ព្រមទទួល ដោយគ្មានសិទ្ធិ ដោយផ្ទាល់ ឬ ដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍ណាមួយ ដើម្បី :

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

១-បំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬ កិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន ។

២-មិនបំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬ កិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន ។

## កថាភាគទី ៣
## ជំនួញឥទ្ធិពលអកម្ម

**មាត្រា ៥៩៥.-** និយមន័យនៃជំនួញឥទ្ធិពលអកម្ម

ជំនួញឥទ្ធិពលអកម្ម គឺជាអំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬ ដោយពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលទទូចសុំ ឬ យល់ព្រមទទួលដោយគ្មានសិទ្ធិដោយផ្ទាល់ ឬ ដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍ណាមួយ ដើម្បីទទួលបានពីស្ថាប័នរដ្ឋ ដោយសារឥទ្ធិពលពិតប្រាកដ ឬ ដោយសន្មតនូវការងារលទ្ធកម្មសាធារណៈ គ្រឿងសម្គាល់កិត្តិយស ឬ សេចក្តីសម្រេចអនុគ្រោះផ្សេងៗដទៃទៀត ។

**មាត្រា ៥៩៦.-** ទោសដែលត្រូវអនុវត្ត

ជំនួញឥទ្ធិពលអកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ) ឆ្នាំទៅ ១០(ដប់) ឆ្នាំ ។

## កថាភាគទី ៤
## ការកេងយកផលប្រយោជន៍ដោយខុសច្បាប់

**មាត្រា ៥៩៧.-** និយមន័យនៃការកេងយកផលប្រយោជន៍ដោយខុសច្បាប់

ការកេងយកផលប្រយោជន៍ដោយខុសច្បាប់ គឺជាអំពើប្រព្រឹត្តដោយអ្នករាជការសាធារណៈ ឬ ដោយពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដែលយកទទួល ឬ រក្សាទុកដោយផ្ទាល់ ឬ ដោយប្រយោលនូវផលប្រយោជន៍អ្វីមួយ នៅក្នុង ៖

១-សហគ្រាសណាមួយ ដែលអ្នករាជការ ឬ ពលរដ្ឋនោះមានភារកិច្ចភិបាលទាំងស្រុង ឬ មួយផ្នែកនូវការឃ្លាំមើល ការគ្រប់គ្រង ឬ ការជម្រះបញ្ជី ។

២-ប្រតិបត្តិការណាមួយ ដែលអ្នករាជការ ឬ ពលរដ្ឋនោះមានភារកិច្ចភិបាលទាំងស្រុង ឬ មួយផ្នែកនូវការឃ្លាំមើល ឬ ការទូទាត់ ។

**មាត្រា ៥៩៨.-** ទោសដែលត្រូវអនុវត្ត

ការកេងយកផលប្រយោជន៍ដោយខុសច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

### កថាភាគទី ៥
### បក្ខានុគ្រោះ

**មាត្រា ៥៩៩.-** និយមន័យនៃបក្ខានុគ្រោះ

បក្ខានុគ្រោះ គឺជាអំពើរបស់អ្នករាជការសាធារណៈ ឬ ពលរដ្ឋទទួលអាណត្តិសាធារណៈ ដោយការបោះឆ្នោត ដែលផ្តល់ឱ្យដោយខុសច្បាប់នូវអត្ថប្រយោជន៍ដល់អ្នកដទៃ នៅក្នុងឱកាសនៃការធ្វើលទ្ធកម្មសាធារណៈ ។

**មាត្រា ៦០០.-** ទោសដែលត្រូវអនុវត្ត

បក្ខានុគ្រោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

## ជំពូកទី ៣
## ការបំផ្លាញ និងការកែបំបាត់

**មាត្រា ៦០១.-** បទបំផ្លាញដោយចេតនា និងកែបំបាត់ដោយទុច្ចរិត

អ្នករាជការសាធារណៈ ឬ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតដែលគ្រប់គ្រងលិខិត បណ្ណ មូលនិធិសាធារណៈ មូលនិធិឯកជន ឬ វត្ថុផ្សេងៗទៀត ដោយសារមុខងាររបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ប្រសិនបើអ្នករាជការ ឬ ពលរដ្ឋនោះបំផ្លាញចោលដោយចេតនា ឬ កែបំបាត់ដោយទុច្ចរិតនូវលិខិត បណ្ណ មូលនិធិសាធារណៈ មូលនិធិឯកជន ឬ វត្ថុផ្សេងៗទៀតនោះ ។

**មាត្រា ៦០២.-** បទធ្វើឱ្យខូចខាត ឬ ឱ្យបាត់បង់ដោយអចេតនា

អ្នករាជការសាធារណៈ ឬ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតដែលគ្រប់គ្រងលិខិត បណ្ណ មូលនិធិសាធារណៈ មូលនិធិឯកជន ឬ វត្ថុផ្សេងៗទៀត ដោយសារ

មុខងាររបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និង ពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ប្រសិនបើអ្នករាជការ ឬ ពលរដ្ឋនោះធ្វើឱ្យខូចខាត ឬ ធ្វើឱ្យបាត់បង់ដោយអចេតនានូវលិខិតបណ្ណ មូលនិធិសាធារណៈ មូលនិធិឯកជន ឬ វត្ថុអ្វីផ្សេងៗទៀតនោះ ។

## ផ្នែកទី ៤
## ការប៉ុនប៉ង និងទណ្ឌកម្ម

**មាត្រា ៦០៣.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ លើកលែងតែបទមជ្ឈិមដែលមានចែងក្នុងមាត្រា ៥៨៩ (បទមិនព្រមដោះលែងបុគ្គលដែលត្រូវបានឃុំដោយខុសច្បាប់) និងមាត្រា ៦០២(បទធ្វើឱ្យខូចខាត ឬ ឱ្យបាត់បង់ដោយអចេតនា) នៃក្រមនេះ ។

**មាត្រា ៦០៤.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងជំពូកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំយ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៤-ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៥-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៦-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៧-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ

និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២

## ការប៉ះពាល់ដល់រដ្ឋបាលសាធារណៈ ធ្វើឡើងដោយបុគ្គលឯកជន

### ផ្នែកទី ១

### អំពើពុករលួយ និងបទល្មើសប្រហាក់ប្រហែល

#### កថាភាគទី ១

#### អំពើសូកប៉ាន់

**មាត្រា ៦០៥.-** បទសូកប៉ាន់

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ បុគ្គលណា ដោយគ្មានសិទ្ធិដោយផ្ទាល់ ឬ ដោយប្រយោល ប្រគល់អំណោយ ឬ ជំនូន ធ្វើការសន្យាជាមួយ ឬ ផ្តល់អត្ថប្រយោជន៍អ្វីមួយដល់អ្នករាជការសាធារណៈ ឬ ពលរដ្ឋទទួលអាណត្តិសាធារណៈ ដោយការបោះឆ្នោត ដើម្បីឱ្យអ្នករាជការ ឬ ពលរដ្ឋនោះ :

១-បំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬកិច្ចដែលសម្រួលដោយសារមុខងាររបស់ខ្លួន ។

២-មិនបំពេញកិច្ចនៃមុខងាររបស់ខ្លួន ឬ កិច្ចដែលសម្រួលដោយសារមុខងាររបស់ខ្លួន ។

#### កថាភាគទី ២

#### ជំនួញឥទ្ធិពលសកម្ម

**មាត្រា ៦០៦.-** បទជំនួញឥទ្ធិពលសកម្ម

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី

៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល បុគ្គលណាដោយគ្មានសិទ្ធិ ដោយផ្ទាល់ ឬដោយប្រយោល ប្រគល់អំណោយ ឬ ជំនូន ធ្វើការសន្យាជាមួយ ឬ ផ្តល់អត្ថប្រយោជន៍អ្វីមួយដល់អ្នករាជការសាធារណៈ ឬ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីទទួលបានពីស្ថាប័នរដ្ឋ ដោយសារឥទ្ធិពលពិតប្រាកដ ឬ ដោយសន្មតរបស់អ្នករាជការ ឬ ពលរដ្ឋនោះ នូវការងារលទ្ធកម្មសាធារណៈ គ្រឿងសម្គាល់កិត្តិយស ឬ សេចក្តីសម្រេចអនុគ្រោះផ្សេងទៀត ។

## កថាភាគទី ៣
## អំពើសម្លុតគំរាម

**មាត្រា ៦០៧.-** បទសម្លុតគំរាម

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល អំពើសម្លុតគំរាមដែលអនុវត្តទៅលើអ្នករាជការសាធារណៈ ឬ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បី :

១-ឱ្យអ្នករាជការ ឬ ពលរដ្ឋនោះបំពេញកិច្ចនៃមុខងាររបស់ខ្លួន ។

២-កុំឱ្យអ្នករាជការ ឬ ពលរដ្ឋនោះបំពេញកិច្ចនៃមុខងាររបស់ខ្លួន ។

៣-ឱ្យអ្នករាជការ ឬពលរដ្ឋនោះរំលោភឥទ្ធិពលរបស់ខ្លួនដែលមានពិតប្រាកដ ឬ ដោយសន្មត ដើម្បីនឹងទទួលបានពីរាជការនូវការងារលទ្ធកម្មសាធារណៈ គ្រឿងសម្គាល់កិត្តិយស ឬ សេចក្តីសម្រេចអនុគ្រោះផ្សេងទៀត ។

## ផ្នែកទី ២
## ការបំផ្លាញ និងការកែបំបាត់

**មាត្រា ៦០៨.-** បទបំផ្លាញ និងកែបំបាត់

អំពើបំផ្លាញ កែបំបាត់ ឬ ដកយកលិខិត បណ្ណ មូលនិធិសាធារណៈ មូលនិធិឯកជន ឬ វត្ថុផ្សេងៗទៀត ដែលរក្សាទុកដោយអ្នករាជការសាធារណៈ ឬ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដោយសារមុខងាររបស់ខ្លួននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធ-

នាគារពី ២(ពីរ) ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

## ផ្នែកទី ៣

## ការជ្រៀតជ្រែកក្នុងមុខងារសាធារណៈ និងតំណែងផ្លូវការ

**មាត្រា ៦០៩.–** បទជ្រៀតជ្រែកដោយខុសច្បាប់ទៅក្នុងការបំពេញមុខងារសាធារណៈ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល អំពើជ្រៀតជ្រែកដោយខុសច្បាប់ក្នុងការអនុវត្តមុខងារសាធារណៈណាមួយ ដោយបំពេញកិច្ចណាមួយក្នុងចំណោមកិច្ចទាំងឡាយ ដែលសម្រាប់តែអ្នកមានសិទ្ធិក្នុងមុខងារនេះ ។

**មាត្រា ៦១០.–** បទធ្វើសកម្មភាពបង្កើតឱ្យមានការយល់ច្រឡំជាមួយការបំពេញមុខងារសាធារណៈ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០(មួយសែន) រៀល ទៅ ២.០០០.០០០(ពីរលាន) រៀល បុគ្គលដែលធ្វើសកម្មភាពនៅក្នុងលក្ខខណ្ឌ ដែលអាចនាំឱ្យសាធារណជនយល់ច្រឡំថា ជាការបំពេញមុខងារសាធារណៈ ។

**មាត្រា ៦១១.–** បទប្រើប្រាស់លិខិត ឬឯកសារដែលបង្កើតឱ្យមានការភ័ន្តច្រឡំ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើប្រើប្រាស់ដោយគ្មានសិទ្ធិនូវលិខិត ឬឯកសារដែលមានភាពប្រហាក់ប្រហែលគ្នានឹងលិខិតរដ្ឋបាលសាធារណៈ ឬតុលាការ ដែលអាចបង្កើតឱ្យមានការភ័ន្តច្រឡំនៅក្នុងស្មារតីនៃសាធារណជន ។

**មាត្រា ៦១២.–** បទប្រើប្រាស់ដោយខុសច្បាប់ នូវសំលៀកបំពាក់ជាអាទិ៍ សម្រាប់អាជ្ញាធរសាធារណៈ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើស្លៀកពាក់ជា

សាធារណៈ ដោយគ្មានសិទ្ធិស្លៀកពាក់នូវសំលៀកបំពាក់ ឯកសណ្ឋាន ឬ គ្រឿងឥស្សរិយយស សម្រាប់អាជ្ញាធរសាធារណៈ ។

**មាត្រា ៦១៣.-** បទប្រើប្រាស់ដោយខុសច្បាប់នូវឯកសារបញ្ជាក់វិជ្ជាជីវៈ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ខែ ទៅ ១(មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើប្រើប្រាស់ជាសាធារណៈ ដោយគ្មានសិទ្ធិ នូវឯកសារបញ្ជាក់វិជ្ជាជីវៈដែលកំណត់ដោយអាជ្ញាធរសាធារណៈ ។

**មាត្រា ៦១៤.-** បទប្រើប្រាស់ដោយគ្មានសិទ្ធិនូវសញ្ញាសម្គាល់ដែលកំណត់ដោយអាជ្ញាធរសាធារណៈ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើប្រើប្រាស់ជាសាធារណៈ ដោយគ្មានសិទ្ធិនូវសញ្ញាសម្គាល់ដែលកំណត់ដោយអាជ្ញាធរសាធារណៈ ។

**មាត្រា ៦១៥.-** បទប្រើប្រាស់ដោយគ្មានសិទ្ធិនូវយានយន្តដែលមានសញ្ញាសម្គាល់ប្រើប្រាស់ដោយនគរបាល ឬ យោធា

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើប្រើប្រាស់ដោយគ្មានសិទ្ធិនូវយានយន្ត ដែលមានសញ្ញាសម្គាល់ខាងក្រៅប្រើប្រាស់ដោយភ្នាក់ងារនគរបាល ឬ យោធិន ។

**មាត្រា ៦១៦.-** បទប្រើប្រាស់នូវឯកសណ្ឋានជាអាទិ៍ ដែលមានភាពប្រហាក់ប្រហែលគ្នានឹងនគរបាល ឬ យោធា

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ខែ ទៅ ៦(ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀលអំពើប្រើប្រាស់ជាសាធារណៈ ដោយគ្មានសិទ្ធិនូវសំលៀកបំពាក់ ឯកសណ្ឋាន អត្តសញ្ញាណបណ្ណ សញ្ញាសម្គាល់ ឬ យានយន្តនគរបាល ឬ យោធា មានភាពប្រហាក់ប្រហែលគ្នានឹងសំលៀកបំពាក់ ឯកសណ្ឋាន អត្តសញ្ញាណបណ្ណ សញ្ញាសម្គាល់ ឬ យានយន្តរបស់នគរបាល ឬ យោធា ដែលអាចធ្វើឱ្យមានការភ័ន្តច្រឡំក្នុងស្មារតីនៃសាធារណជន ។

**មាត្រា ៦១៧.–** ស្ថានទម្ងន់ទោសដោយសារមានការត្រៀមរៀបចំបទឧក្រិដ្ឋ ឬ បទមជ្ឈិម

បទល្មើសដែលមានចែងនៅក្នុងមាត្រា ៦១១ (បទប្រើប្រាស់លិខិត ឬ ឯកសារដែលបង្កើតឱ្យមានការកំណត់ប្រឡំ) ដល់មាត្រា ៦១៦ (បទប្រើប្រាស់នូវឯកសណ្ឋាន ជាអាទិ៍ដែលមានភាពប្រហាក់ប្រហែលគ្នានឹងនគរបាល ឬ យោធា) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល កាលបើបទល្មើសនោះមានគោលដៅដើម្បីរៀបចំ ឬ សម្រួលដល់ការប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិម ។

**មាត្រា ៦១៨.–** បទប្រើប្រាស់ដោយគ្មានសិទ្ធិនូវបណ្ណបញ្ជាក់តួនាទីក្នុងវិជ្ជាជីវៈកំណត់ដោយអាជ្ញាធរសាធារណៈ

អំពើប្រើប្រាស់ ដោយគ្មានសិទ្ធិ នូវបណ្ណបញ្ជាក់តួនាទីក្នុងវិជ្ជាជីវៈណាមួយដែលកំណត់ដោយអាជ្ញាធរសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៦១៩.–** បទប្រើប្រាស់ដោយគ្មានសិទ្ធិនូវសញ្ញាបត្រ

អំពើប្រើប្រាស់ ដោយគ្មានសិទ្ធិនូវសញ្ញាបត្រ ឬ គុណសម្បត្តិ ដែលលក្ខខណ្ឌនៃការប្រគល់ត្រូវបានកំណត់ដោយអាជ្ញាធរសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៦២០.–** បទប្រើប្រាស់ដោយមិនប្រក្រតីនូវឋានៈណាមួយ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល អំពើប្រព្រឹត្តដោយអ្នកដឹកនាំសហគ្រាសណាមួយ ដែលធ្វើឱ្យមាន ឬ ទុកឱ្យមាននៅក្នុងការផ្សព្វផ្សាយជាសាធារណៈ ដើម្បីជាអត្ថប្រយោជន៍នៃសហគ្រាសនេះ នូវឈ្មោះ និងឋានៈរបស់សមាជិក ឬ អតីតសមាជិករបស់រាជរដ្ឋាភិបាល សមាជិក ឬ អតីតសមាជិករបស់រដ្ឋសភា ឬ ព្រឹទ្ធសភា និងចៅក្រម ឬ អតីតចៅក្រម ។

**មាត្រា ៦២១.–** បទប្រើប្រាស់អត្តសញ្ញាណខុសពីអត្តសញ្ញាណផ្លូវការក្នុងកិច្ចសាធារណៈ

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់

ROYAUME DU CAMBODGE * SECRÉTARIAT DU PALAIS ROYAL
ព្រះបរមរាជវាំង
206/204



Ksl

៥-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៦-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៧-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ៦២៥.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៦០៥ (បទស្លុកប៉ាន់) មាត្រា ៦០៦ (បទជំនួញឥទ្ធិពលសកម្ម) និងមាត្រា ៦០៧ (បទសម្លុតគំរាម) នៃក្រមនេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចតទៅនេះ :

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ ។

២-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬ ច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា ១៧៣ (ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃតាម

បែបបទកំណត់ដោយមាត្រា ១៧៤ (ការហាមឃាត់ចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) នៃក្រមនេះ ។

៦-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៧-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសតាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៨-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្ដីសម្រេច) នៃក្រមនេះ ។

៩-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្ដីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## មាតិកាទី ៤
## ការប៉ះពាល់ដល់ទំនុកចិត្តសាធារណៈ
## ជំពូកទី ១
## ការក្លែងបន្លំ
### ផ្នែកទី ១
### ការក្លែងបន្លំឯកសារ

**មាត្រា ៦២៦.-** និយមន័យនៃការក្លែងបន្លំ

ការក្លែងបន្លំ គឺជាការធ្វើឱ្យខូចខាតដោយចេតនានូវការពិត ដែលសម្ដែងចេញជាក់ស្ដែងនៅក្នុងលិខិត ឬ តាមមធ្យោបាយផ្សេងទៀតនៃការសម្ដែងនូវគំនិត កាលបើមានគ្រប់លក្ខខណ្ឌដូចតទៅ :

១-ការធ្វើឱ្យខូចខាតនេះមានកម្មវត្ថុ ឬ អាចមានអានុភាពធ្វើជាភស្តុតាងនៃសិទ្ធិ

ឬ នៃអំពើដែលមានផលវិបាកគតិយុត្ត ។

២-ការធ្វើឱ្យខូចខាតនេះអាចបណ្តាលឱ្យមានព្យសនកម្ម ។

**មាត្រា ៦២៧.-** ទោសដែលត្រូវអនុវត្ត

ការក្លែងបន្លំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ទៅ ៣(បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៦២៨.-** បទប្រើប្រាស់លិខិតក្លែង

ការប្រើប្រាស់លិខិតក្លែង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៦២៩.-** បទក្លែងបន្លំឯកសារសាធារណៈ

ការក្លែងបន្លំប្រព្រឹត្តនៅក្នុងលិខិតយថាភូត ឬ ការក្លែងបន្លំប្រព្រឹត្តនៅក្នុងឯកសារដែលចេញឱ្យដោយរាជការសាធារណៈ ដើម្បីធ្វើការកត់សម្គាល់សិទ្ធិ អត្តសញ្ញាណ ឬ ឋានៈ ឬ ដើម្បីយល់ព្រមផ្តល់ការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៦៣០.-** បទប្រើប្រាស់ឯកសារសាធារណៈក្លែង

ការប្រើប្រាស់ឯកសារក្លែងដែលមានចែងក្នុងមាត្រា ៦២៩(បទក្លែងបន្លំឯកសារសាធារណៈ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦៣១.-** បទផ្តល់ឯកសារដោយទុច្ចរិត

អំពើផ្តល់ដល់អ្នកដទៃដោយទុច្ចរិត នូវឯកសារដែលចេញដោយរាជការសាធារណៈ ដើម្បីធ្វើការកត់សម្គាល់សិទ្ធិ អត្តសញ្ញាណ ឬ ឋានៈ ឬ ដើម្បីយល់ព្រមផ្តល់ការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ROYAUME DU CAMBODGE * LE SECRETARIAT DU PALAIS ROYAL

**មាត្រា ៦៣២.–** បទសុំឱ្យផ្តល់ឯកសារដោយទុច្ចរិត

អំពើដែលសុំដោយទុច្ចរិតឱ្យរាជការសាធារណៈចេញ នូវឯកសារសម្រាប់ធ្វើការកត់សម្គាល់សិទ្ធិ អត្តសញ្ញាណ ឬ ឋានៈ ឬ យល់ព្រមផ្តល់ការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៦៣៣.–** បទផ្តល់សេចក្តីប្រកាសដោយភូតកុហក

អំពើផ្តល់សេចក្តីប្រកាសដោយភូតកុហកដល់រាជការសាធារណៈ ដើម្បីទទួលបានវិភាជន៍ ការបើកប្រាក់ ឬ អត្ថប្រយោជន៍ដោយខុសច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២(ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

**មាត្រា ៦៣៤.–** បទផ្តល់លិខិតបញ្ជាក់មិនពិត

ក្រៅពីករណីដែលបញ្ញត្តក្នុងផ្នែកនេះ អំពើដែលធ្វើលិខិតបញ្ជាក់ ឬ វិញ្ញាបនបត្រ ដែលរៀបរាប់ពីការណភាព ដែលតាមជាក់ស្តែងមិនមែនជាការពិត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ខែ ទៅ ១(មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៦៣៥.–** បទក្លែងលិខិតបញ្ជាក់

អំពើក្លែងបន្លំលិខិតបញ្ជាក់ ឬ វិញ្ញាបនបត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ខែ ទៅ ១(មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៦៣៦.–** បទប្រើប្រាស់លិខិតបញ្ជាក់មិនពិត ឬ លិខិតបញ្ជាក់ក្លែងក្លាយ

ការប្រើប្រាស់លិខិតបញ្ជាក់មិនពិត ឬ ក្លែងក្លាយ ឬ វិញ្ញាបនបត្រមិនពិត ឬ ក្លែងក្លាយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៦៣៧.-** បទស៊ីសំណូកដោយអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល អំពើរបស់បុគ្គលដែលប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួនដោយទទួចសុំ ឬ យល់ព្រមទទួលអំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍អ្វីមួយ ដើម្បីធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនបត្ររៀបរាប់ពីការណភាព ដែលតាមជាក់ស្តែង មិនមែនជាការពិត ។

**មាត្រា ៦៣៨.-** បទសូកប៉ាន់ចំពោះអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល អំពើប្រគល់អំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍អ្វីមួយ ឱ្យបុគ្គលណាម្នាក់ ដើម្បីធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនបត្ររៀបរាប់ពីការណភាព ដែលតាមជាក់ស្តែងមិនមែនជាការពិត ។

**មាត្រា ៦៣៩.-** បទស៊ីសំណូកដោយសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រដើម្បីធ្វើលិខិតបញ្ជាក់មិនពិត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល អំពើរបស់គ្រូពេទ្យ ឬ បុគ្គលដែលជាសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រ ដែលទទួចសុំ ឬ យល់ព្រមទទួលអំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍អ្វីមួយ ដើម្បីធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនបត្ររៀបរាប់ពីការណភាព ដែលតាមជាក់ស្តែងមិនមែនជាការពិត ។

**មាត្រា ៦៤០.-** បទសូកប៉ាន់ចំពោះសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រដើម្បីធ្វើលិខិតបញ្ជាក់មិនពិត

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល អំពើប្រគល់អំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍អ្វីមួយ ដល់គ្រូពេទ្យ ឬ បុគ្គល ដែលជាសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រ ដើម្បីធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនបត្រ រៀបរាប់ពីការណភាព ដែលតាមជាក់ស្តែងមិនមែនជាការពិត ។

**មាត្រា ៦៤១.-** ការអនុវត្តបទមជ្ឈិមនៃមាត្រា ៦៣៩ និងមាត្រា ៦៤០ ចំពោះគ្រប់វិជ្ជាជីវៈខាងវេជ្ជសាស្ត្រ

បទប្បញ្ញត្តិនៃមាត្រា ៦៣៩(បទសុំសំណូកដោយសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជ-សាស្ត្រដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) និងមាត្រា ៦៤០(បទសូកប៉ាន់ចំពោះសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) នៃក្រមនេះ ត្រូវអនុវត្តទៅលើគ្រប់បុគ្គលដែលប្រកបវិជ្ជាជីវៈខាងវេជ្ជសាស្ត្រ ។

**មាត្រា ៦៤២.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងក្នុងមាត្រា ៦៣២ (បទសុំឱ្យផ្តល់ឯកសារដោយទុច្ចរិត) មាត្រា ៦៣៨(បទសូកប៉ាន់ចំពោះអ្នកមាននីតិសម្បទា ដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) និងមាត្រា ៦៤០(បទសូកប៉ាន់ចំពោះសមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) នៃក្រមនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៦៤៣.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៦-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

**មាត្រា ៦៤៤.- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៦៣៨(បទសូកប៉ាន់ចំពោះអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) និងមាត្រា ៦៤០(បទសូកប៉ាន់ចំពោះ សមាជិកនៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រដើម្បីធ្វើលិខិតបញ្ជាក់មិនពិត) នៃក្រមនេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ១០០.០០០.០០០ (មួយរយលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬ ច្រើន ដូចតទៅនេះ :

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០(ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ ។

២-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬ ច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២(ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា ១៧៣(ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈ ដល់ការសន្សំសំចៃ តាមបែបបទកំណត់ដោយមាត្រា ១៧៤(ការហាមឃាត់ចំពោះការធ្វើអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ) នៃក្រមនេះ ។

៦-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨(ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩(ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៧-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨(ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩(ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ ។

៨-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០(ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ផ្នែកទី ២
## រូបិយវត្ថុ និងរូបិយបណ្ណក្លែង

**មាត្រា ៦៤៥.–** បទក្លែងបន្លំរូបិយវត្ថុដែលមានតម្លៃនីត្យានុកូល

ការក្លែងបន្លំក្រដាសប្រាក់ ឬ កាសដែលជារូបិយវត្ថុមានតម្លៃនីត្យានុកូលនៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០(សាមសិប) ឆ្នាំ ឬ អស់មួយជីវិត ។

**មាត្រា ៦៤៦.–** បទក្លែងបន្លំរូបិយបណ្ណដែលមានតម្លៃនីត្យានុកូល

ការក្លែងបន្លំរូបិយបណ្ណដែលមានតម្លៃនីត្យានុកូល ដែលបោះពុម្ពផ្សាយដោយស្ថាប័នបរទេស ឬអន្តរជាតិ ដែលមាននីតិសម្បទា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ។

**មាត្រា ៦៤៧.–** បទដាក់ឱ្យធ្វើចរាចរណ៍រូបិយវត្ថុ និងរូបិយបណ្ណក្លែង

ការដាក់ឱ្យធ្វើចរាចរណ៍រូបិយវត្ថុ ឬរូបិយបណ្ណក្លែងដែលមានចែងក្នុងមាត្រា ៦៤៥ (បទក្លែងបន្លំរូបិយវត្ថុដែលមានតម្លៃនីត្យានុកូល) និងមាត្រា ៦៤៦(បទក្លែងបន្លំរូបិយបណ្ណ

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL * ក្រសួងព្រះបរមរាជវាំង

ដែលមានតម្លៃនីត្យានុកូល) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្តជាក្រុមមានការចាត់តាំង ។

**មាត្រា ៦៤៨.-** បទសន្និធិរូបិយវត្ថុ និងរូបិយបណ្ណក្លែង

អំពើដឹកជញ្ជូន ឬ សន្និធិរូបិយវត្ថុ ឬរូបិយបណ្ណក្លែងដែលមានចែងក្នុងមាត្រា ៦៤៥ (បទក្លែងបន្លំរូបិយវត្ថុដែលមានតម្លៃនីត្យានុកូល) និងមាត្រា ៦៤៦(បទក្លែងបន្លំរូបិយបណ្ណដែលមានតម្លៃនីត្យានុកូល) នៃក្រមនេះ ដើម្បីយកទៅដាក់ឱ្យធ្វើចរាចរណ៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្តជាក្រុមមានការចាត់តាំង ។

**មាត្រា ៦៤៩.-** បទក្លែងបន្លំរូបិយវត្ថុ និងរូបិយបណ្ណដែលអស់តម្លៃនីត្យានុកូល

ការក្លែងបន្លំរូបិយវត្ថុ ឬរូបិយបណ្ណដែលអស់តម្លៃនីត្យានុកូលនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៦៥០.-** បទកាន់កាប់ដោយខុសច្បាប់នូវសម្ភារៈផលិតរូបិយវត្ថុនិងរូបិយបណ្ណ

ការកាន់កាប់ដោយគ្មានការអនុញ្ញាតនូវឧបករណ៍ និងសម្ភារៈដែលជាពិសេសសម្រាប់ធ្វើរូបិយវត្ថុ ឬរូបិយបណ្ណ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ) ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ ។

**មាត្រា ៦៥១.-** បទដាក់ឱ្យធ្វើចរាចរណ៍ជាថ្មីនូវរូបិយវត្ថុ និងរូបិយបណ្ណក្លែង

អំពើរបស់បុគ្គលណាដែលបានទទួលរូបិយវត្ថុ ឬរូបិយបណ្ណក្លែងដែលមានចែងក្នុងមាត្រា ៦៤៥(បទក្លែងបន្លំរូបិយវត្ថុដែលមានតម្លៃនីត្យានុកូល) និងមាត្រា ៦៤៦ (បទក្លែងបន្លំរូបិយបណ្ណដែលមានតម្លៃនីត្យានុកូល) នៃក្រមនេះ ដោយគិតថាជារូបិយវត្ថុ ឬរូបិយបណ្ណពិត ហើយយកទៅដាក់ឱ្យធ្វើចរាចរណ៍ជាថ្មី ក្រោយពីបានដឹងថាជារបស់ក្លែងនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ថ្ងៃ ទៅ ៦(ប្រាំមួយ) ថ្ងៃ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦៥២.-** ការលើកលែងឱ្យរួចផុតពីទោស

បុគ្គលណាដែលបានប៉ុនប៉ងប្រព្រឹត្តបទល្មើសណាមួយ ក្នុងចំណោមបទល្មើសដែលមានចែងក្នុងផ្នែកនេះ នឹងត្រូវបានលើកលែងឱ្យរួចផុតពីទោស ប្រសិនបើបុគ្គលនោះ បានធ្វើឱ្យបទល្មើសនោះមិនបានសម្រេច និងនាំឱ្យដឹងពីអត្តសញ្ញាណជាយថាហេតុរបស់ជនល្មើសផ្សេងៗទៀត ដោយបានឱ្យដំណឹងដល់អាជ្ញាធររដ្ឋបាល ឬ តុលាការ ។

**មាត្រា ៦៥៣.-** ទោសបន្ថែម: ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៦-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៩-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ជំពូកទី ២

## ការក្លែងឯកសាររបស់អាជ្ញាធរសាធារណៈ

### ផ្នែកទី ១

### ការក្លែងមូលបត្ររដ្ឋ និងតែមប្រៃសណីយ៍

**មាត្រា ៦៥៤.-** បទក្លែងបន្លំមូលបត្ររដ្ឋនៃព្រះរាជាណាចក្រកម្ពុជា

ការក្លែងបន្លំមូលបត្ររដ្ឋដែលបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ។

**មាត្រា ៦៥៥.-** បទក្លែងបន្លំមូលបត្ររដ្ឋបរទេស

ការក្លែងបន្លំមូលបត្ររដ្ឋបរទេស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៦៥៦.-** បទប្រើប្រាស់មូលបត្ររដ្ឋក្លែង

ការប្រើប្រាស់មូលបត្ររដ្ឋក្លែង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦៥៧.-** បទក្លែងបន្លំតែមប្រៃសណីយ៍ជាអាទិ៍

ការក្លែងបន្លំតែមប្រៃសណីយ៍ ឬ ផលិតផលដែលមានតម្លៃហិរញ្ញវត្ថុផ្សេងទៀត ដែលបោះពុម្ពផ្សាយដោយព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំទៅ ៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ។

**មាត្រា ៦៥៨.-** បទប្រើប្រាស់តែមប្រៃសណីយ៍ក្លែងជាអាទិ៍

ការប្រើប្រាស់តែមប្រៃសណីយ៍ ឬ ផលិតផលដែលមានតម្លៃហិរញ្ញវត្ថុផ្សេងទៀត ដែលក្លែង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល។

**មាត្រា ៦៥៩.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៦៦០.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៦-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

13/2014



ksl

## ផ្នែកទី ២

## ការក្លែងបន្លំសញ្ញាសម្គាល់របស់អាជ្ញាធរ

**មាត្រា ៦៦១.-** បទក្លែងត្រាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជា

ការក្លែងបន្លំត្រាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦៦២.-** បទប្រើប្រាស់ត្រាក្លែង

ការប្រើប្រាស់ត្រាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជាដែលក្លែង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦៦៣.-** បទក្លែងក្រដាសដែលមានក្បាលលិខិតផ្លូវការ

ការក្លែងបន្លំក្រដាសដែលមានក្បាលលិខិតផ្លូវការ ប្រើប្រាស់ដោយអាជ្ញាធរសាធារណៈនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល។

**មាត្រា ៦៦៤.-** បទប្រើប្រាស់ក្រដាសក្លែងដែលមានក្បាលលិខិតផ្លូវការ

ការប្រើប្រាស់ក្រដាសក្លែងដែលមានក្បាលលិខិតផ្លូវការ ប្រើប្រាស់ដោយអាជ្ញាធរសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល។

**មាត្រា ៦៦៥.-** បទផលិតជាអាទិ៍ ក្រដាសពុម្ពដែលបង្កើតឱ្យមានការភ័ន្តច្រឡំ

ការធ្វើ ការលក់ ការចែកចាយ ឬការប្រើប្រាស់ក្រដាសពុម្ពជាមួយនឹងក្រដាសដែលមានក្បាលលិខិតផ្លូវការ ប្រើប្រាស់ដោយអាជ្ញាធរសាធារណៈដែលមានភាពប្រហាក់ប្រហែលគ្នា ដែលអាចបង្កើតឱ្យមានការភ័ន្តច្រឡំនៅក្នុងស្មារតីរបស់សាធារណជន ត្រូវផ្តន្ទាទោស

ROYAUME DU CAMBODGE PALAIS ROYAL

# គន្ថីទី ៦
# អវសានប្បញ្ញត្តិ
# ជំពូកតែមួយ
# អវសានប្បញ្ញត្តិ

**មាត្រា ៦៧១.-** និរាករណ៍ និងអានុភាពនៃបទប្បញ្ញត្តិព្រហ្មទណ្ឌពីមុន

ច្បាប់និងបទប្បញ្ញត្តិព្រហ្មទណ្ឌពីមុនដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវបាត់បង់អានុភាពចាប់ពីថ្ងៃដែលក្រមនេះ ត្រូវបានអនុវត្ត ៖

១-រាល់បទប្បញ្ញត្តិព្រហ្មទណ្ឌមុនឆ្នាំ ១៩៩២ ។

២-បទប្បញ្ញត្តិព្រហ្មទណ្ឌនៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

៣-ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០២/០០៤ ចុះថ្ងៃទី ៧ ខែ មករា ឆ្នាំ ២០០២ ។

បទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀតដែលមានអានុភាពនៅពេលក្រមនេះ ត្រូវបានអនុវត្ត ហើយផ្ទុយនឹងបទប្បញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកថា គ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងក្រមនេះ ចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត ។

ប៉ុន្តែ បទប្បញ្ញត្តិព្រហ្មទណ្ឌពីមុនដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើត្រូវបន្តមានអានុភាពអនុវត្តក្រោយការអនុវត្តនៃក្រមនេះ ចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តមុនពេលក្រមនេះត្រូវបានអនុវត្ត លើកលែងតែបទប្បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៦៦៨ (ការអនុវត្តបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក) នៃក្រមនេះ ។

**មាត្រា ៦៧២.-** ការអនុវត្តក្រមនេះ

លើកលែងតែបទប្បញ្ញត្តិទូទៅនៃគន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមនេះ ដែលត្រូវ

ROYAUME DU CAMBODGE — LE MINISTRE DU PALAIS ROYAL — ក្រសួងព្រះបរមរាជវាំង



223/264

ដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល។

**មាត្រា ៦៦៦.-** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ៦៦៧.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅសម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ចំពោះបទឧក្រិដ្ឋ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម ។

៤-ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្ត បទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

៥-ការរឹបអូសវត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៦-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៧-ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង ។

៨-ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៩-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង
2/264

១០-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

១១-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

# គន្ថីទី ៥

## អន្តរប្បញ្ញត្តិ

## ជំពូកតោល

## អន្តរប្បញ្ញត្តិ

**មាត្រា ៦៦៨.–** ការអនុវត្តបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក

ចំពោះបទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសដោយច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែកផ្សេងទៀតដែលកំពុងនៅជាធរមាន ត្រូវអនុវត្តដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌទាំងនោះ ។

នៅក្នុងករណីដែលមានទំនាស់រវាងច្បាប់និងបទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែក និងបទប្បញ្ញត្តិនៃក្រមនេះ ត្រូវអនុវត្តដោយអនុលោមតាមវិធានដែលមានចែងក្នុងគន្ថីទី ១(បទប្បញ្ញត្តិទូទៅ) នៃក្រមនេះ ។

បទប្បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើ មិនត្រូវយកមកអនុវត្ត ចំពោះច្បាប់ព្រហ្មទណ្ឌដែលមានចរិតពិសេស។

**មាត្រា ៦៦៩.–** ការអនុវត្តនៅក្នុងពេលវេលានូវវិធានស្តីពីអាជ្ញាយុកាលនៃទោស

អាជ្ញាយុកាលនៃទោសចំពោះបទល្មើសដែលត្រូវបានផ្តន្ទាទោស ក្រោយការចូលជាធរមាននៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា ៦៧០.–** ការពន្យាតការអនុវត្តគន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមនេះ

គន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមនេះ ត្រូវយកទៅអនុវត្តចំពោះគ្រប់បទប្បញ្ញត្តិព្រហ្មទណ្ឌដោយឡែកដទៃទៀត លើកលែងតែមានបទប្បញ្ញត្តិផ្សេងចែងផ្ទុយពីនេះ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



22/2014 Ksl

## មាតិកាពិស្តារ

ទំព័រ


**គន្ថីទី ១ បទប្បញ្ញត្តិទូទៅ** ---------------------------------------- ១

**មាតិកាទី ១ ច្បាប់ព្រហ្មទណ្ឌ** ---------------------------------------- ១

**ជំពូកទី ១ គោលការណ៍ទូទៅ** ---------------------------------------- ១

**មាត្រា ១.-** ដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ -------------------------------- ១

**មាត្រា ២.-** និយមន័យ និង ចំណាត់ថ្នាក់នៃបទល្មើស ------------------------ ១

**មាត្រា ៣.-** គោលការណ៍នីត្យានុកូលភាព -------------------------------- ១

**មាត្រា ៤.-** ចេតនាប្រព្រឹត្តបទល្មើស -------------------------------- ១

**មាត្រា ៥.-** ការបកស្រាយច្បាប់ព្រហ្មទណ្ឌ -------------------------------- ២

**មាត្រា ៦.-** ការប្រកាសទោស -------------------------------- ២

**មាត្រា ៧.-** លក្ខខណ្ឌនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា ---------------- ២

**មាត្រា ៨.-** អវត្តមាននៃនិទណ្ឌភាពក្នុងបទល្មើសធ្ងន់ធ្ងរខាងនីតិមនុស្សធម៌អន្តរជាតិ -------------------------------- ២

**ជំពូកទី ២ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា** ---------------- ២

**មាត្រា ៩.-** ការអនុវត្តច្បាប់ដែលលុបចោលបទល្មើស ---------------- ២

**មាត្រា ១០.-** ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ឬ ធ្ងន់ជាង ------ ២

**មាត្រា ១១.-** សុពលភាពនៃកិច្ចនីតិវិធី -------------------------------- ៣

**ជំពូកទី ៣ ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជានៅក្នុងលំហ** ---------------- ៣

**ផ្នែកទី ១ បទល្មើសដែលបានប្រព្រឹត្ត ឬ ចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា** -------------------------------- ៣

**មាត្រា ១២.-** គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា ---- ៣

**មាត្រា ១៣.-** ទីកន្លែងប្រព្រឹត្តបទល្មើស -------------------------------- ៣

**មាត្រា ១៤.-** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជា ------------ ៣

**មាត្រា ១៥.-** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាបរទេស ------------ ៤

មាត្រា ១៦.- បទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយានកម្ពុជា ------ ៤
មាត្រា ១៧.- ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាចំពោះអំពើដែលបានចាប់ផ្តើមប្រព្រឹត្តនៅកម្ពុជា ------ ៤
មាត្រា ១៨.- ការកំណត់បទល្មើសប្រព្រឹត្តដោយនីតិបុគ្គល ------ ៤
ផ្នែកទី ២ បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ------ ៤
មាត្រា ១៩.- បទឧក្រិដ្ឋ ឬ បទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ ------ ៤
មាត្រា ២០.- ជនរងគ្រោះជាជនជាតិខ្មែរ ------ ៥
មាត្រា ២១.- ការធ្វើបណ្តឹងចោទប្រកាន់ ------ ៥
មាត្រា ២២.- សមត្ថកិច្ចដោយឡែកចំពោះបទឧក្រិដ្ឋដោយឡែក ------ ៥
មាត្រា ២៣.- ការមិនចោទប្រកាន់ត្រួតគ្នា និង ទោស ------ ៦
មាតិកាទី ២ ការទទួលខុសត្រូវព្រហ្មទណ្ឌ ------ ៦
ជំពូកទី ១ បទប្បញ្ញត្តិទូទៅ ------ ៦
មាត្រា ២៤.- គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ------ ៦
មាត្រា ២៥.- និយមន័យនៃចារី ------ ៦
មាត្រា ២៦.- និយមន័យនៃសហចារី ------ ៦
មាត្រា ២៧.- និយមន័យនៃការប៉ុនប៉ង ------ ៦
មាត្រា ២៨.- និយមន័យនៃអ្នកផ្តើមគំនិត ------ ៧
មាត្រា ២៩.- និយមន័យនៃអ្នកសមគំនិត ------ ៧
មាត្រា ៣០.- និយមន័យនៃអ្នករាជការសាធារណៈ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ------ ៧
ជំពូកទី ២ មូលហេតុនៃការមិនទទួលខុសត្រូវ ឬ ការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ ------ ៨
មាត្រា ៣១.- ការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតី ------ ៨
មាត្រា ៣២.- ការអនុញ្ញាតដោយច្បាប់ ឬ អាជ្ញាធរ ------ ៨
មាត្រា ៣៣.- ការការពារស្របច្បាប់ ------ ៩

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ក្រសួងព្រះបរមរាជវាំង
27/264

មាត្រា ៣៤.- សច្ចធារណ៍នៃការការពារស្របច្បាប់ ---------- ៩
មាត្រា ៣៥.- ស្ថានភាពចាំបាច់ ---------- ១០
មាត្រា ៣៦.- អានុភាពនៃកម្លាំង ឬ ការបង្ខំ ---------- ១០
មាត្រា ៣៧.- ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ---------- ១០
ជំពូកទី ៣ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ---------- ១០
មាត្រា ៣៨.- នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ---------- ១០
មាត្រា ៣៩.- វិធានការអនុវត្តចំពោះអនីតិជន ---------- ១០
មាត្រា ៤០.- ប្រភេទនៃវិធានការ ---------- ១១
មាត្រា ៤១.- ការដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ ---------- ១១
ជំពូកទី ៤ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ---------- ១១
មាត្រា ៤២.- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ---------- ១១
មាតិកាទី ៣ ទោស ---------- ១២
ជំពូកទី ១ ប្រភេទនៃទោស ---------- ១២
ផ្នែកទី ១ មូលទោស ---------- ១២
មាត្រា ៤៣.- មូលទោស ---------- ១២
មាត្រា ៤៤.- អប្បបរមា និង អតិបរមានៃមូលទោស ---------- ១២
មាត្រា ៤៥.- ការទម្ងន់ទោស និង ការសម្រាលទោស ---------- ១២
មាត្រា ៤៦.- និយមន័យនៃបទឧក្រិដ្ឋ ---------- ១២
មាត្រា ៤៧.- និយមន័យនៃបទមជ្ឈិម ---------- ១៣
មាត្រា ៤៨.- និយមន័យនៃបទលហុ ---------- ១៣
មាត្រា ៤៩.- ការគណនាអំពីថិរវេលានៃទោសដាក់ពន្ធនាគារ ---------- ១៣
មាត្រា ៥០.- លក្ខខណ្ឌដោយឡែកនៃការបញ្ចប់ទោស ---------- ១៣
មាត្រា ៥១.- ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ---------- ១៤
មាត្រា ៥២.- ផលនៃទោសពិន័យ ---------- ១៤
ផ្នែកទី ២ ទោសបន្ថែម ---------- ១៤

មាត្រា ៥៣.- ប្រភេទនៃទោសបន្ថែម ---------------------------- ១៤

មាត្រា ៥៤.- លក្ខខណ្ឌនៃការប្រកាសទោសបន្ថែម ------------------ ១៥

មាត្រា ៥៥.- សិទ្ធិពលរដ្ឋដែលអាចដកបាន ---------------------- ១៥

មាត្រា ៥៦.- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ ---------------- ១៦

មាត្រា ៥៧.- ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ----- ១៦

មាត្រា ៥៨.- ការព្យួរលិខិតបើកបរ ---------------------------- ១៦

មាត្រា ៥៩.- ការហាមឃាត់ចំពោះការស្នាក់នៅទីកន្លែងមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា ---------------------------------- ១៦

មាត្រា ៦០.- ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ---------------------------------- ១៧

មាត្រា ៦១.- ការហាមឃាត់ចំពោះការចូល និង ស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាដល់ទណ្ឌិតដែលជាជនបរទេស ----- ១៧

មាត្រា ៦២.- ការរឹបអូស ------------------------------------ ១៧

មាត្រា ៦៣.- ការចាត់ចែងទ្រព្យសម្បត្តិរឹបអូស -------------------- ១៨

មាត្រា ៦៤.- ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទ ------------------ ១៨

មាត្រា ៦៥.- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ---------------- ១៨

មាត្រា ៦៦.- ការបិទគ្រឹះស្ថាន ---------------------------------- ១៨

មាត្រា ៦៧.- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន -------- ១៩

មាត្រា ៦៨.- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ---------------- ១៩

មាត្រា ៦៩.- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ------------------------------------------ ១៩

មាត្រា ៧០.- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ------------------------- ១៩

មាត្រា ៧១.- ពេលនៃការអនុវត្តទោសបន្ថែម ---------------------- ២០

ផ្នែកទី ៣ ទោសជំនួស ---------------------------------------- ២០

កថាភាគទី ១ ការងារសហគមន៍ ---------------------------------- ២០

មាត្រា ៧២.- និយមន័យនៃការងារសហគមន៍ ---------------------- ២០

មាត្រា ៧៣.- អ្នកមិនទទួលប្រយោជន៍នៃការងារសហគមន៍ ------------ ២០

មាត្រា ៧៤.- របបគតិយុត្តនៃការងារសហគមន៍ -------------------- ២០

មាត្រា ៧៥.- គោលការណ៍ជួសជុលការខូចខាតដល់អ្នកដទៃ ------------ ២០

កថាភាគទី ២ ការស្តីបន្ទោស ---------------------------------- ២១

មាត្រា ៧៦.- របបគតិយុត្តនៃការស្តីបន្ទោស ---------------------- ២១

ជំពូកទី ២ ស្ថានទម្ងន់ទោស និង ស្ថានសម្រាលទោស ------------------ ២១

ផ្នែកទី ១ ស្ថានទម្ងន់ទោស ------------------------------------ ២១

កថាភាគទី ១ និយមន័យនៃស្ថានទម្ងន់ទោសដោយឡែកខ្លះៗ -------------- ២១

មាត្រា ៧៧.- ក្រុមមានការចាត់តាំង ------------------------------ ២១

មាត្រា ៧៨.- ការគិតទុកជាមុន ---------------------------------- ២១

មាត្រា ៧៩.- ការកាប់គាស់ទម្លុះទម្លាយ --------------------------- ២១

មាត្រា ៨០.- ការផ្លោះរបងចូល ---------------------------------- ២២

មាត្រា ៨១.- អាវុធ និង វត្ថុដែលត្រូវបានចាត់ទុកដូចអាវុធ ----------- ២២

មាត្រា ៨២.- ការពួនស្ទាក់ ------------------------------------- ២២

កថាភាគទី ២ ការមិនរាងចាល ---------------------------------- ២២

មាត្រា ៨៣.- អានុភាពនៃការមិនរាងចាល -------------------------- ២២

មាត្រា ៨៤.- លក្ខខណ្ឌនៃការមិនរាងចាល ------------------------- ២៣

មាត្រា ៨៥.- ការមិនរាងចាលក្នុងបទឧក្រិដ្ឋ ------------------------ ២៣

មាត្រា ៨៦.- ការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្តន្ទាទោស
បទឧក្រិដ្ឋ ---------------------------------------------- ២៣

មាត្រា ៨៧.- ការមិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីការផ្តន្ទាទោស
បទមជ្ឈិម ---------------------------------------------- ២៤

**មាត្រា ៨៨.-** ការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិម ---------- ២៤

**មាត្រា ៨៩.-** ការប្រដូចបទល្មើស ដើម្បីបង្កើតឱ្យមានការមិនរាងចាល ---- ២៤

**មាត្រា ៩០.-** ការមិនរាងចាល និង កិច្ចនៃការចោទប្រកាន់ ---------- ២៥

**មាត្រា ៩១.-** ការមិនរាងចាល និង សេចក្តីសម្រេចស្ថាពរ ---------- ២៥

**មាត្រា ៩២.-** បទប្បញ្ញត្តិដោយឡែក ---------- ២៥

**ផ្នែកទី ២ ស្ថានសម្រាលទោស** ---------- ២៥

**មាត្រា ៩៣.-** និយមន័យនៃស្ថានសម្រាលទោស ---------- ២៥

**មាត្រា ៩៤.-** អានុភាពនៃស្ថានសម្រាលទោស ---------- ២៥

**មាត្រា ៩៥.-** ទោសដាក់ពន្ធនាគារអស់មួយជីវិត និង ស្ថានសម្រាលទោស -- ២៦

**ជំពូកទី ៣ របបនៃការប្រកាសទោស** ---------- ២៦

**ផ្នែកទី ១ របបទូទៅ** ---------- ២៦

**មាត្រា ៩៦.-** គោលការណ៍ឯកត្តកម្មនៃទោស ---------- ២៦

**មាត្រា ៩៧.-** ការប្រកាសមូលទោស ---------- ២៦

**មាត្រា ៩៨.-** ការប្រកាសទោសជំនួស ---------- ២៧

**មាត្រា ៩៩.-** ការប្រកាសទោសបន្ថែមលើមូលទោស ---------- ២៧

**មាត្រា ១០០.-** ការជំនួសមូលទោសដោយទោសបន្ថែម ---------- ២៧

**មាត្រា ១០១.-** វិធានដោយឡែកសម្រាប់ការប្រកាសទោសការងារសហគមន៍ ---------- ២៧

**មាត្រា ១០២.-** ចិរវេលា និង អំឡុងពេលនៃការងារសហគមន៍ ---------- ២៨

**មាត្រា ១០៣.-** បែបបទនៃការអនុវត្តទោសការងារសហគមន៍ ---------- ២៨

**ផ្នែកទី ២ ការព្យួរទោសធម្មតា** ---------- ២៨

**កថាភាគទី ១ បទប្បញ្ញត្តិរួម** ---------- ២៨

**មាត្រា ១០៤.-** ការប្រកាសការព្យួរទោស ---------- ២៨

**មាត្រា ១០៥.-** របបនៃការព្យួរទោស ---------- ២៨

**កថាភាគទី ២ ការទោលប្រកាន់ចំពោះបទឧក្រិដ្ឋ ឬ បទមជ្ឈិម** ---------- ២៨

**មាត្រា ១០៦.–** លក្ខខណ្ឌទាក់ទងនឹងការផ្តន្ទាទោសពីមុន ---------- ២៨

**មាត្រា ១០៧.–** ទោសអាចនាំឱ្យមានការព្យួរទោស ---------- ២៩

**មាត្រា ១០៨.–** ការព្យួរទោសមួយផ្នែក ---------- ២៩

**មាត្រា ១០៩.–** ការដកហូតការព្យួរទោស ---------- ២៩

**មាត្រា ១១០.–** ការមិនដកហូតការព្យួរទោស ---------- ២៩

**មាត្រា ១១១.–** ការទុកជាអសារបង់នូវការផ្តន្ទាទោស ---------- ២៩

**កថាភាគទី ៣ ការទោលប្រកាន់ចំពោះបទលហុ** ---------- ៣០

**មាត្រា ១១២.–** លក្ខខណ្ឌទាក់ទងទៅនឹងការផ្តន្ទាទោសពីមុន ---------- ៣០

**មាត្រា ១១៣.–** ទោសអាចនាំឱ្យមានការព្យួរទោស ---------- ៣០

**មាត្រា ១១៤.–** ការដកហូតការព្យួរទោស ---------- ៣០

**មាត្រា ១១៥.–** ការមិនដកហូតការព្យួរទោស ---------- ៣០

**មាត្រា ១១៦.–** ការចាត់ទុកជាអសារបង់នូវការផ្តន្ទាទោស ---------- ៣០

**ផ្នែកទី ៣ ការព្យួរទោសសាកល្បង** ---------- ៣១

**មាត្រា ១១៧.–** និយមន័យ និង លក្ខខណ្ឌនៃការព្យួរទោសសាកល្បង ---------- ៣១

**មាត្រា ១១៨.–** រយៈពេលនៃការសាកល្បង ---------- ៣១

**មាត្រា ១១៩.–** វិធានការត្រួតពិនិត្យ ---------- ៣១

**មាត្រា ១២០.–** កាតព្វកិច្ចដោយឡែកដែលអាចដាក់ទៅលើទណ្ឌិត ---------- ៣២

**មាត្រា ១២១.–** ការកែប្រែកាតព្វកិច្ចដោយឡែកដោយយុត្តាធិការ ---------- ៣៣

**មាត្រា ១២២.–** ការដកហូតការព្យួរទោសសាកល្បង ---------- ៣៣

**មាត្រា ១២៣.–** ការផ្តន្ទាទោសដែលត្រូវចាត់ទុកជាអសារបង់ ---------- ៣៣

**ផ្នែកទី ៤ ការផ្អាកការប្រកាសទោស** ---------- ៣៣

**មាត្រា ១២៤.–** លក្ខខណ្ឌនៃការផ្អាកការប្រកាសទោស ---------- ៣៣

**មាត្រា ១២៥.–** សេចក្តីសម្រេចនៃការផ្អាកការប្រកាសទោស ---------- ៣៤

**មាត្រា ១២៦.–** សវនាការពិនិត្យរឿងដែលបង្អង់ ---------- ៣៤


ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ផ្នែកទី ៥ របបពាក់កណ្តាលសេរីភាព ---------- ៣៤
មាត្រា ១២៧.- លក្ខខណ្ឌនៃរបបពាក់កណ្តាលសេរីភាព ---------- ៣៤
មាត្រា ១២៨.- បែបបទនៃរបបពាក់កណ្តាលសេរីភាព ---------- ៣៤
មាត្រា ១២៩.- ការគិតបញ្ចូលរយៈពេលនៃពាក់កណ្តាលសេរីភាពទៅក្នុងទោស ---------- ៣៥
មាត្រា ១៣០.- ការរៀបចំ និង ការលុបចោលនៃរបបពាក់កណ្តាលសេរីភាព ---------- ៣៥
មាត្រា ១៣១.- ការចាប់ខ្លួន និង ការឃុំខ្លួនទណ្ឌិត ---------- ៣៥
ផ្នែកទី ៦ ការបែងចែកទោសជាប្រភាគ ---------- ៣៥
មាត្រា ១៣២.- លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ ---------- ៣៥
មាត្រា ១៣៣.- បែបបទនៃការបែងចែកទោសជាប្រភាគ ---------- ៣៥
មាត្រា ១៣៤.- ការកែប្រែរបបនៃការបែងចែកទោសជាប្រភាគ ---------- ៣៥
មាត្រា ១៣៥.- ការចាប់ខ្លួន និង ការឃុំខ្លួនទណ្ឌិត ---------- ៣៦
ជំពូកទី ៤ វិធានអនុវត្តនៅក្នុងករណីបទល្មើសត្រួតគ្នា ---------- ៣៦
ផ្នែកទី ១ វិធានទូទៅ ---------- ៣៦
មាត្រា ១៣៦.- បទល្មើសត្រួតគ្នា ---------- ៣៦
មាត្រា ១៣៧.- ការចោទប្រកាន់តែមួយ ---------- ៣៦
មាត្រា ១៣៨.- ការចោទប្រកាន់ដាច់ពីគ្នា ---------- ៣៦
ផ្នែកទី ២ វិធានដោយឡែក ---------- ៣៧
មាត្រា ១៣៩.- អានុភាពនៃការលើកលែងទោស និង ការបន្ធូរបន្ថយទោសលើការស្រូបទោស ---------- ៣៧
មាត្រា ១៤០.- ការបូកបញ្ចូលគ្នានៃទោសពិន័យ ---------- ៣៧
មាត្រា ១៤១.- ការមិនស្រូបចូលនៃទោសដែលត្រូវបានប្រកាសចំពោះករណីរត់ចេញពីពន្ធនាគារ ---------- ៣៧

ជំពូកទី ៥ មូលហេតុទូទៅដែលមានផលប៉ះពាល់ដល់ការអនុវត្តទោស -------- ៣៨
ផ្នែកទី ១ អាជ្ញាយុកាលនៃទោស ------------------------------------ ៣៨
មាត្រា ១៤២.- អានុភាពនៃអាជ្ញាយុកាល ------------------------ ៣៨
មាត្រា ១៤៣.- ភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋមួយចំនួន ---------------------- ៣៨
មាត្រា ១៤៤.- អាជ្ញាយុកាលនៃទោស ----------------------------- ៣៨
មាត្រា ១៤៥.- ចំណុចចាប់ផ្តើមនៃចិរវេលា ----------------------- ៣៨
មាត្រា ១៤៦.- អាជ្ញាយុកាលនៃកាតព្វកិច្ចរដ្ឋប្បវេណីដែលកើតចេញពីសេចក្តីសម្រេចព្រហ្មទណ្ឌ -------------------------- ៣៨
ផ្នែកទី ២ ការអនុគ្រោះទោស -------------------------------------- ៣៩
មាត្រា ១៤៧.- អានុភាពនៃការអនុគ្រោះទោស ----------------------- ៣៩
មាត្រា ១៤៨.- ការជួសជុលការខូចខាតដល់ជនរងគ្រោះក្នុងករណីនៃការអនុគ្រោះទោស ------------------------------- ៣៩
ផ្នែកទី ៣ ការលើកលែងទោសជាទូទៅ ------------------------------ ៣៩
មាត្រា ១៤៩.- អានុភាពនៃការលើកលែងទោសជាទូទៅ ------------- ៣៩
មាត្រា ១៥០.- ការលើកលែងទោសជាទូទៅ និង ការដកការព្យួរទោស --- ៣៩
មាត្រា ១៥១.- ការជួសជុលការខូចខាតដល់ជនរងគ្រោះក្នុងករណីនៃការលើកលែងទោសជាទូទៅ ----------------------------- ៤០
ផ្នែកទី ៤ ការរៀបចំទោស និង ការលុបចោលទោសបន្ថែមខ្លះៗ --------------- ៤០
មាត្រា ១៥២.- លក្ខខណ្ឌនៃការកែប្រែទោសបន្ថែមខ្លះៗ ---------------- ៤០
មាត្រា ១៥៣.- ការធ្វើឱ្យមានឡើងវិញនូវសិទ្ធិពលរដ្ឋទាំងអស់ ឬ ខ្លះៗ ----- ៤០
មាត្រា ១៥៤.- ការរៀបចំកែប្រែ ឬ ការលុបចោលនូវការហាមឃាត់ ------ ៤០
មាត្រា ១៥៥.- ការប្រគល់ឱ្យវិញនូវលិខិតបើកបរ ------------------ ៤១
មាត្រា ១៥៦.- ការកែប្រែវិធានការនៃការហាមឃាត់ចំពោះការស្នាក់នៅ -- ៤១

**មាត្រា ១៥៧.-** ការកែប្រែការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ----------------------------------៤១

**មាត្រា ១៥៨.-** ការកែប្រែការហាមឃាត់ការចូលមកក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ----------------------------------------------៤១

**មាត្រា ១៥៩.-** ការកែប្រែការបណ្តេញចេញ ការបិទ ការហាមឃាត់ការធ្វើអាជីវកម្ម ----------------------------------------------៤១

**ជំពូកទី ៦ ទោសដែលអាចអនុវត្តចំពោះអនីតិជន** --------------------------៤២

**ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ** ----------------------------------------------៤២

**មាត្រា ១៦០.-** មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើងទៅ--------------------------------------------------៤២

**មាត្រា ១៦១.-** ទោសបន្ថែម ----------------------------------------------៤២

**មាត្រា ១៦២.-** ទោសការងារសហគមន៍------------------------------- ៤៣

**មាត្រា ១៦៣.-** ការមិនអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល --------- ៤៣

**មាត្រា ១៦៤.-** ការទទួលប្រយោជន៍នៃស្ថានសម្រាលទោស----------- ៤៣

**មាត្រា ១៦៥.-** កាតព្វកិច្ចដោយឡែកក្នុងករណីនៃការព្យួរទោសសាកល្បង--- ៤៤

**ផ្នែកទី ២ បទប្បញ្ញត្តិដោយឡែក** ----------------------------------------៤៤

**មាត្រា ១៦៦.-** លក្ខខណ្ឌនៃការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារ ----------- ៤៤

**ជំពូកទី ៧ ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល** ------------------------៤៥

**ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ** --------------------------------------------៤៥

**មាត្រា ១៦៧.-** ទោសដែលត្រូវរងដោយនីតិបុគ្គល ------------------ ៤៥

**ផ្នែកទី ២ ទោសបន្ថែម** ------------------------------------------------៤៥

**មាត្រា ១៦៨.-** ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល ------------------៤៥

**មាត្រា ១៦៩.-** លក្ខខណ្ឌនៃការសម្រេចអំពីទោសបន្ថែម --------------៤៦

**មាត្រា ១៧០.-** ការរំលាយ និង ការជម្រះបញ្ជីនៃនីតិបុគ្គល ------------៤៦

ROYAUME DU CAMBODGE
MINISTÈRE DU PALAIS ROYAL

មាត្រា ១៧១.- ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ ---------------------------------------- ៤៦
មាត្រា ១៧២.- ការហាមឃាត់ចំពោះការធ្វើសកម្មភាព ---------------- ៤៧
មាត្រា ១៧៣.- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ---------------- ៤៧
មាត្រា ១៧៤.- ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ ---------------------------------------- ៤៧
មាត្រា ១៧៥.- ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន -- ៤៧
មាត្រា ១៧៦.- ការបិទគ្រឹះស្ថាន ---------------------------------- ៤៨
មាត្រា ១៧៧.- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន-------- ៤៨
មាត្រា ១៧៨.- ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស -- ៤៨
មាត្រា ១៧៩.- ការរឹបអូស និង សិទ្ធិតតិយជន ---------------------- ៤៨
មាត្រា ១៨០.- ការបិទផ្សាយសេចក្តីសម្រេច------------------------ ៤៩
មាត្រា ១៨១.- ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍ -------------------------------- ៤៩
មាត្រា ១៨២.- ការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងរូបវន្តបុគ្គល និងនីតិបុគ្គល -- ៤៩
គន្ថីទី ២ បទល្មើសប្រឆាំងនឹងបុគ្គល ---------------------------------------- ៥០
មាតិកាទី ១ បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋសង្គ្រាម ---------------------------------------- ៥០
ជំពូកទី ១ បទឧក្រិដ្ឋប្រល័យពូជសាសន៍ ---------------------------- ៥០
មាត្រា ១៨៣.- បទឧក្រិដ្ឋប្រល័យពូជសាសន៍ ------------------------ ៥០
មាត្រា ១៨៤.- ទោសដែលត្រូវទទួល ---------------------------- ៥០
មាត្រា ១៨៥.- បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋប្រល័យពូជសាសន៍-------- ៥០
មាត្រា ១៨៦.- ទោសបន្ថែម : ប្រភេទ និង រយៈពេល ------------------ ៥១
មាត្រា ១៨៧.- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ----------- ៥១

**ជំពូកទី ២ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ** ---------- ៥៣

**មាត្រា ១៨៨.-** បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ---------- ៥៣

**មាត្រា ១៨៩.-** ទោសដែលត្រូវទទួល ---------- ៥៣

**មាត្រា ១៩០.-** បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ---------- ៥៣

**មាត្រា ១៩១.-** ទោសបន្ថែម : ប្រភេទ និង រយៈពេល ---------- ៥៤

**មាត្រា ១៩២.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ---------- ៥៥

**ជំពូកទី ៣ បទឧក្រិដ្ឋសង្គ្រាម** ---------- ៥៦

**មាត្រា ១៩៣.-** បទឧក្រិដ្ឋសង្គ្រាម ---------- ៥៦

**មាត្រា ១៩៤.-** បទឧក្រិដ្ឋសង្គ្រាមផ្សេងទៀត ---------- ៥៦

**មាត្រា ១៩៥.-** ទោសដែលត្រូវទទួល ---------- ៥៧

**មាត្រា ១៩៦.-** បទត្រៀមរៀបចំក្នុងបទឧក្រិដ្ឋសង្គ្រាម ---------- ៥៧

**មាត្រា ១៩៧.-** ទោសបន្ថែម : ប្រភេទ និង រយៈពេល ---------- ៥៧

**មាត្រា ១៩៨.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ---------- ៥៨

**មាតិកាទី ២ ការប៉ះពាល់ដល់មនុស្ស** ---------- ៥៩

**ជំពូកទី ១ ការប៉ះពាល់ដល់ជីវិតមនុស្ស** ---------- ៥៩

**ផ្នែកទី ១ ការប៉ះពាល់ដោយចេតនាដល់ជីវិតមនុស្ស** ---------- ៥៩

**មាត្រា ១៩៩.-** បទឃាតកម្ម ---------- ៥៩

**មាត្រា ២០០.-** បទឃាតកម្មគិតទុកជាមុន ---------- ៦០

**មាត្រា ២០១.-** បទឃាតកម្មដោយការប្រើថ្នាំពុល ---------- ៦០

**មាត្រា ២០២.-** បទឃាតកម្មដែលមានស្ថានទម្ងន់ទោសទាក់ទងនឹង ជនរងគ្រោះ ---------- ៦០

**មាត្រា ២០៣.-** បទឃាតកម្មដែលមានស្ថានទម្ងន់ទោសដោយសារ គោលដៅ ---------- ៦១

**មាត្រា ២០៤.-** បទឃាតកម្មប្រព្រឹត្តដោយអ្នករាជការសាធារណៈ ---------- ៦១

**មាត្រា ២០៥.-** បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬ អំពើរំលោភសេពសន្ថវៈ ---------- ៦១

**មាត្រា ២០៦.-** ទោសបន្ថែម : ប្រភេទ និង រយៈពេល ---------- ៦១

**ផ្នែកទី ២ ការប៉ះពាល់ដោយអចេតនាដល់ជីវិតមនុស្ស** ---------- ៦២

**មាត្រា ២០៧.-** បទមនុស្សឃាតដោយអចេតនា ---------- ៦២

**មាត្រា ២០៨.-** ទោសបន្ថែម : ប្រភេទ និង រយៈពេល ---------- ៦២

**មាត្រា ២០៩.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ---------- ៦៣

**ជំពូកទី ២ ការប៉ះពាល់ដល់បូរណភាពនៃបុគ្គល** ---------- ៦៤

**ផ្នែកទី ១ ទារុណកម្ម និងអំពើឃោរឃៅ** ---------- ៦៤

**មាត្រា ២១០.-** បទទារុណកម្ម និង អំពើឃោរឃៅ ---------- ៦៤

**មាត្រា ២១១.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ---------- ៦៤

**មាត្រា ២១២.-** ស្ថានទម្ងន់ទោសដោយសារគោលដៅ ---------- ៦៥

**មាត្រា ២១៣.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងចារី ---------- ៦៥

**មាត្រា ២១៤.-** ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬ ពិការភាព -- ៦៥

**មាត្រា ២១៥.-** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ----- ៦៦

**មាត្រា ២១៦.-** ទោសបន្ថែម : ប្រភេទ និង រយៈពេល ---------- ៦៦

**ផ្នែកទី ២ អំពើហិង្សា** ---------- ៦៧

**មាត្រា ២១៧.-** បទហិង្សាដោយចេតនា ---------- ៦៧

**មាត្រា ២១៨.-** ស្ថានទម្ងន់ទោស ---------- ៦៧

**មាត្រា ២១៩.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ---------- ៦៧

**មាត្រា ២២០.-** ស្ថានទម្ងន់ទោសដោយសារគោលដៅ ---------- ៦៨

**មាត្រា ២២១.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនល្មើស ---------- ៦៨

**មាត្រា ២២២.-** អំពើហិង្សាប្រព្រឹត្តដោយសហពន្ធ ឬ អនីតិសង្វាសជន ---- ៦៨

**មាត្រា ២២៣.-** ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬ ពិការភាព -- ៦៨

**មាត្រា ២២៤.-** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ---- ៦៩

មាត្រា ២២៥.- ការចាត់ទុកការប្រើសារធាតុពុលដូចជាអំពើហិង្សាដោយចេតនា ------------------------------------------- ៦៩

មាត្រា ២២៦.- ការចាត់ទុកការផ្តល់អាហារដែលមានសារធាតុពុលដូចជាអំពើហិង្សាដោយចេតនា ------------------------------ ៦៩

មាត្រា ២២៧.- ការចាត់ទុកការបញ្ចូលសារធាតុពុលក្នុងទឹកសម្រាប់បរិភោគដូចជាអំពើហិង្សាដោយចេតនា -------------------- ៦៩

មាត្រា ២២៨.- បទហិង្សាស្រាល------------------------------------------ ៦៩

មាត្រា ២២៩.- ទោសបន្ថែម : ប្រភេទ និង រយៈពេល ----------------- ៦៩

មាត្រា ២៣០.- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល -----------៧០

ផ្នែកទី ៣ ការគំរាមកំហែង ------------------------------------------------ ៧២

មាត្រា ២៣១.- បទគំរាមកំហែង ----------------------------------- ៧២

មាត្រា ២៣២.- បទគំរាមកំហែងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ ៧២

មាត្រា ២៣៣.- បទគំរាមកំហែងថានឹងសម្លាប់ --------------------- ៧២

មាត្រា ២៣៤.- បទគំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ ---------------------------------- ៧២

មាត្រា ២៣៥.- ទោសបន្ថែម : ប្រភេទ និង រយៈពេល --------------- ៧២

ផ្នែកទី ៤ ការបង្កឱ្យមានរបួសដោយអចេតនា --------------------------- ៧៣

មាត្រា ២៣៦.- បទបង្កឱ្យមានរបួសដោយអចេតនា ----------------- ៧៣

មាត្រា ២៣៧.- ទោសបន្ថែម : ប្រភេទ និង រយៈពេល ----------------៧៤

មាត្រា ២៣៨.- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ------------៧៤

ជំពូកទី ៣ ការបំពានខាងផ្លូវភេទ ---------------------------------------------៧៥

ផ្នែកទី ១ ការរំលោភសេពសន្ថវៈ -----------------------------------------៧៥

មាត្រា ២៣៩.- បទរំលោភសេពសន្ថវៈ ------------------------------៧៥

មាត្រា ២៤០.- ស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬ ទាក់ទងនឹងជនល្មើស----------------------------------------៧៦




ROYAUME DU CAMBODGE * SECRÉTARIAT DU PALAIS ROYAL *
39/264

មាត្រា ២៤១.- ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ----------- ៧៦

មាត្រា ២៤២.- ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬ ពិការភាព -- ៧៦

មាត្រា ២៤៣.- ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬ អំពើឃោរឃៅ ------------------------------------- ៧៦

មាត្រា ២៤៤.- ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ---- ៧៧

មាត្រា ២៤៥.- ទោសបន្ថែម: ប្រភេទ និង រយៈពេល--------------- ៧៧

ផ្នែកទី ២ ការបំពានខាងផ្លូវភេទដទៃទៀត ----------------------------៧៨

មាត្រា ២៤៦.- បទប្រទូស្តកេរខ្មាស ------------------------------៧៨

មាត្រា ២៤៧.- ស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬ ទាក់ទងនឹងចារី ------------------------------------៧៨

មាត្រា ២៤៨.- ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ -----------៧៨

មាត្រា ២៤៩.- បទបង្ហាញកេរភេទ------------------------------៧៩

មាត្រា ២៥០.- បទរុកកួនខាងផ្លូវភេទ ---------------------------៧៩

